**Declassified to Public**
**06 September 2012**

សំណុំរឿងលេខ ០១/១៨-០៧-២០០៧-អវតក/អជសដ

# ការវិភាគសម្ដីសាក្សី(ស្លាប់)សម្រាប់សវនាការ

## មាតិកា

I. **ជនរងគ្រោះនៅមន្ទីរ ស-២១** ....................3

1. ស្រេង ធី ....................3

ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង ....................3

II. **កងការពារ ឬបុគ្គលិកនៅមន្ទីរ ស-២១** ....................6

2. អែម ឈិន ....................6

ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង ....................6

3. ឈឹម ធាង ....................11

4. អៀម ហន ហៅម៉ឹង ....................14

5. ហ៊ឹម ខេង ....................19

6. អៀម ឈុនគី ....................22

7. កែស ព្រីក ....................25

10. ប៉ែន ហេង ....................33

11. ព្រំ ឈឿន ....................38

12. ព្រំ សុខ ....................41

14. គុប សឿន ហៅ គុប ព្រាប ហៅ ច្រឹក ....................48

15. ទុំ សាត ....................50

16. យ៉ែម យាន ....................54

17. យិន ឡូញ ....................58

III. **ជនជាប់ឃុំឃាំងស-២៤** ....................61

18. ហ៊ុយ ប៉ាន់ ហៅ កាំង ប៉ាន់ ....................61

19. លក ម៉េងស៊ាន ....................65

20. ណាំ សុខា ....................67

21. សោម ម៉ុន ....................69

IV. **កងការពារ ឬបុគ្គលិកស-២៤** ....................72

22. ហាម សេង ....72

V. **អ្នកជាប់ឃុំឃាំងម-១៣ ....75**

23. BIZOT FRANÇOIS ....75

VI. **កន្លែងកើតហេតុនៅមន្ទីរ ស-២១ ....78**

24. LESIC ZORAN ....78
25. ប៉ែន អេន ....80

VII. **អ្នករស់រានមានជីវិតនៅមន្ទីរ ស-២១ ....82**

26. អាយ ស៊ីមលី ....82
27. ជេត សុខា ....84
28. ឆាយ ស្រៀវ ....85
29. មុំ ទៃ ....87
30. ង៉ែត ប៊ុនថា ....88
31. ប៉ែន ផល្លា ....90
32. អ៊ុង សាមឿន ....92
33. សៀង ដានី ....94
34. ទេស សំបុន ....96
35. វណ្ណ សុភា ....97
36. មាស យ៉ែម ....99

VIII. **ការវិភាគឯកសារមន្ទីរ ស-២១ ....101**

37. ឆាំង យុ ....101
38. ឃួយ វិសាលមុនី ....102
39. គិត សេរី ....104
40. ឡាច វរល័ក្ខកល្យាណ ....106
41. អ៊ូច ប៊ុន ....108
42. តាត លក្ខិណា ....110
43. វ៉ាន់ថាន់ ពៅដារ៉ា ....111
44. យិន នាន ....115

# I. ជនរងគ្រោះនៅមន្ទីរ ស-២១

## 1. ស្រេង ធី

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីផ្តល់នូវភស្តុតាងអំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* និងគោលនយោបាយ ព្រមទាំងរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ចំពោះមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពីការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* ការធ្វើទារុណកម្ម និងការធ្វើបាបបែបអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាលមនុស្សឃាត និងមនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមាន ប៉ុន្តែមិនមែនកម្រិតត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីនេះមានអាយុប្រមាណ ១៩ឆ្នាំ នៅខែមេសា ឆ្នាំ១៩៧៥ ភេទប្រុស ជនជាតិខ្មែរ រៀនដល់ថ្នាក់ទី៨។ សាក្សីរូបនេះបានបម្រើក្នុងកងទ័ពកម្ពុជាប្រជាធិបតេយ្យនៅក្នុងកងពល និងតំបន់ជាច្រើន ចាប់ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៩។ សាក្សីរូបនេះគឺជាសមាជិកនៃកងពលធំ១១ ក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងបានជួយប្រយុទ្ធប្រឆាំងនឹងកងទ័ពសាធារណរដ្ឋ។ បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ សាក្សីរូបនេះបានបម្រើក្នុងកងពលធំ៥០២។ ក្នុងខែមីនា ឬខែមេសា ឆ្នាំ១៩៧៧ សាក្សីរូបនេះត្រូវបានគេចោទថាក្បត់ជាតិ ហើយត្រូវបានគេបញ្ជូនទៅមន្ទីរសន្តិសុខ ស-២២។ បន្ទាប់ពីនៅមន្ទីរ ស-២២ បានបីឬបួនខែ សាក្សីត្រូវបានគេបញ្ជូនទៅកន្លែងដែលគាត់ជឿជាក់ថាជាមន្ទីរសន្តិសុខ ស-២១។ សាក្សីត្រូវបានគេដោះលែងពីមន្ទីរ ស-២១ ប្រមាណជាពីរខែបន្ទាប់ និងត្រូវ បានគេបញ្ជូនត្រលប់ទៅ មន្ទីរស-២២ វិញ។ សាក្សីនេះត្រូវបានគេដោះលែងពីមន្ទីរ ស-២២ ប្រហែលជា ក្នុងខែកក្កដា ឆ្នាំ១៩៧៧។ នៅចុងឆ្នាំ១៩៧៧សាក្សីនេះត្រូវបានគេបញ្ជូនទៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងរយៈពេល មួយខែ។ បន្ទាប់ពីត្រូវបានគេដោះលែងពីការដ្ឋាននោះមក សាក្សីនេះបានចូលបម្រើទ័ពជាថ្មី។ នៅពេលរបបខ្មែរក្រហមជិតរដ្ឋលរលំ សាក្សីនេះត្រូវបានគេបញ្ជូនទៅខេត្តស្វាយរៀង ដែលរូបគាត់ជាសមាជិក នៃអង្គភាព

មួយដែលបានវាយប្រហារចូលទឹកដីវៀតណាម។ សាក្សីនេះ នៅបម្រើជាទ័ពរហូតដល់ការដួលរលំនៃរបបខ្មែរក្រហម។

## ជម្លោះប្រដាប់អាវុធ

3. សាក្សីរូបនេះផ្តល់ភស្តុតាងអំពី តួនាទីរបស់គាត់ជាទាហានកម្ពុជាប្រជាធិបតេយ្យនៅក្នុង ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥[1]។ សាក្សីនេះផ្តល់ភស្តុតាងថា គាត់ត្រូវបានគេផ្តល់ការណែនាំស្តីអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញប្រហែលជាមួយសប្តាហ៍មុនការចាប់ផ្តើមសកម្មភាពជម្លៀសនោះ[2]។ សាក្សីនេះនឹងពិពណ៌នាអំពីលក្ខណៈផ្តាច់ការនៃការជម្លៀសនោះ ហើយអះអាងថាគ្មានការលើកលែងឡើយ[3]។ សាក្សីផ្តល់ភស្តុតាងថាអង្គភាពរបស់គាត់ត្រូវបានគេបញ្ជូនទៅខេត្តស្វាយរៀង ភ្លាមមុនពេលការចូលលុកលុយរបស់វៀតណាមនៅតំបន់នោះក្នុងឆ្នាំ១៩៧៨ និងត្រូវបានគេបញ្ជាឲ្យវាយប្រហារចូលទឹកដីវៀតណាម[4]។ សាក្សីនេះនឹងពិពណ៌នាអំពីរបៀបដែលអង្គភាពរបស់គាត់បានដុតបំផ្លាញផ្ទះសំបែង និងវាយប្រហារទៅលើជនស៊ីវិលវៀតណាមនៅលើទឹកដីវៀតណាមក្នុងឆ្នាំ ១៩៧៨[5]។

## រចនាសម្ព័ន្ធ និងគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ

4. សាក្សីនេះផ្តល់ភស្តុតាងអំពីរចនាសម្ព័ន្ធរបស់កងពលធំកងទ័ពកម្ពុជាប្រជាធិបតេយ្យ។ សាក្សីនេះផ្តល់ភស្តុតាងអំពីរចនាសម្ព័ន្ធនៃកងពលធំ ១១ និងកងពលធំ ៥០២ និងកងពលធំ ៨០១ របស់កងទ័ពភូមិភាគពិសេស។ សាក្សីនេះផ្តល់ព័ត៌មានស្តីអំពីកងពលធំចំនួនបីនៅក្នុងភូមិភាគពិសេស[6]។ សាក្សីនេះផ្តល់ភស្តុតាងថា បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ កងពលធំទាំងបីនៃកងទ័ពភូមិភាគពិសេស ត្រូវបានគេរំលាយចោល[7]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

5. សាក្សីនេះផ្តល់ភស្តុតាងថាគាត់ត្រូវបានគេឃុំឃាំង ប៉ុន្តែមិនត្រូវបានគេចាប់ខ្លួនទេ នៅឯព្រៃសរជាមួយយុទ្ធជនធម្មតាចំនួន ៣២នាក់ ផ្សេងទៀត[8]។ សាក្សីនេះផ្តល់ភស្តុតាងថាគាត់ត្រូវបានគេឃុំឃាំងនៅមន្ទីរ ស-២១ អស់រយៈពេល ២ខែ ក្នុងចន្លោះរយៈពេលដែលគាត់នៅមន្ទីរ ស-២២ ប្រហែលពីខែមេសា ឆ្នាំ១៩៧៧ ដល់ខែកក្កដា ឆ្នាំ១៩៧៧[9]។ សាក្សីនេះផ្តល់ភស្តុតាង ដោយផ្អែកទៅលើការចុះទៅធ្វើទស្សនៈកិច្ចសារមន្ទីរទួលស្លែងក្រោយឆ្នាំ១៩៧៩ ថា គាត់ជឿថាគាត់មិនត្រូវបានគេឃុំខ្លួន នៅខាងក្នុងបរិវេណ អគារធំទេ ប៉ុន្តែនៅបរិវេណជុំវិញទីនោះ[10]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

6. សាក្សីនេះផ្តល់ភស្តុតាងថា គាត់ស្ថិតក្នុងចំណោមមនុស្ស ៥ ឬ៦នាក់ ដែលត្រូវបានគេបញ្ជូនទៅមន្ទីរ ស-២១[11]។ សាក្សីនឹងបង្ហាញផងដែរថា ក្នុងអំឡុងគាត់ជាប់ឃុំឃាំងនៅមន្ទីរ ស-២១ គាត់បានឃើញរថយន្តពីរគ្រឿងផ្ទុកទៅដោយអ្នកទោសពេញ ដែលត្រូវបានដោះលែងពីមន្ទីរ ស-២១ រួចដឹកទៅកាន់មន្ទីរ ស-២២វិញ[12]។ សាក្សីរូបនេះសន្និដ្ឋានថា អ្នកទោសប្រមាណ ៥០នាក់ ត្រូវបានគេបញ្ជូនពីមន្ទីរ ស-២១ ទៅកាន់ មន្ទីរ ស-២២[13]។

## ការដាក់ជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

7. សាក្សីនេះផ្តល់ភស្តុតាងថា គាត់ត្រូវបានគេប្រាប់ឱ្យជីកប្រឡាយនៅព្រៃស[14]។ សាក្សីនេះផ្តល់ភស្តុតាងថា នៅមន្ទីរ ស-២១ គាត់ត្រូវបានគេឃុំខ្លួននៅក្នុងបន្ទប់តូចមួយ ហើយគាត់ត្រូវបានគេដាក់ខ្នោះជើង និងខ្នោះដៃ[15]។ សាក្សីនេះផ្តល់ភស្តុតាងថា គាត់ទទួលបានបាយមួយកូនចានតូចក្នុងមួយថ្ងៃក្នុងខណៈពេលដែលគាត់ជាប់ឃុំ[16]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

8. សាក្សីនេះផ្តល់ភស្តុតាងថា គាត់មិនដែលឃើញការប្រហារជីវិតប្រជាជនកម្ពុជាឡើយ ប៉ុន្តែថា គាត់បានឃើញគេយកមនុស្សទៅប្រហារជីវិត[17]។ សាក្សីនេះនិយាយយោងទៅលើឧទាហរណ៍ជាក់ស្តែងមួយនៅខេត្តកំពង់ឆ្នាំងដែលនៅទីនោះមនុស្សត្រូវបានគេយកទៅប្រហារជីវិតនៅទីតាំងមួយខាងលិចរមាស[18]។

## សក្ខីកម្មមុនៗ

9. សាក្សីនេះបានផ្តល់ចម្លើយមួយ តាមការដឹងរបស់សហព្រះរាជអាជ្ញា:

(1) បទសម្ភាសន៍របស់ ស្រេង ធី ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី24 ខែតុលា ឆ្នាំ2003, ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, ឧបសម្ព័ន្ធ លេខ19.189, ERN 00052235-00052285 (ភាសាខ្មែរ); អត្ថបទសង្ខេប ជាភាសាអង់គ្លេស (ERN 00183942-00183946)។

## ឯកសារពាក់ព័ន្ធដទៃទៀត

10. មិនមានឯកសារពាក់ព័ន្ធជាក់លាក់ផ្សេងទៀតដែលចម្លើយរបស់សាក្សីបាននិយាយយោងដល់ឡើយ។

## II. តំណការពារ ឬបុគ្គលិកនៅមន្ទីរ ស-២១

## 2. ម៉ែម ឈិន

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីរូបនេះផ្តល់ភស្តុតាងអំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)*។ ចំពោះមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161),* ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ*(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច*(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងមនុស្សខុសច្បាប់ កង្វះខាតការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ប្រជាជនឲ្យទៅជាទាសករ ការឈឺចាប់ធ្ងន់ធ្ងរ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបយ៉ាង អមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល និងមនុស្សឃាត និងការសម្លាប់ជនជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនកម្រិតត្រឹមតែ អង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុ ៤៩ឆ្នាំ (កើតនៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៥៨) ភេទប្រុស ជនជាតិខ្មែរ។ មុនឆ្នាំ១៩៧៣ សាក្សីនេះជាព្រះសង្ឃមកពីខេត្តកណ្តាល[19]។ ក្នុងឆ្នាំ១៩៧៣ គាត់បានចូលបម្រើកងទ័ពនៅភូមិកុកទិលក្នុងស្រុកកណ្តាលស្ទឹង ហើយក្រោយមកគាត់ក៏ត្រូវបានគេចាត់តាំងឲ្យទៅនៅ កងពលធំ១២ នៃភូមិភាគពិសេស ដែលមាន តាណាត និង តាពីន ជាប្រធាន[20]។ សាក្សីនេះបានចូលប្រឡូកក្នុងការវាយប្រយុទ្ធនៅតាមផ្លូវជាតិលេខ២១ ពីភ្នំពេញ ទៅកោះធំ និងនៅតាម ដងទន្លេមេគង្គ[21]។ បន្ទាប់ពីទីក្រុងភ្នំពេញបានធ្លាក់ក្នុងកណ្តាប់ដៃពួកខ្មែរក្រហមមក សាក្សីនេះបានធ្វើស្រែមួយរយៈនៅខាងកើតព្រៃស មុនពេលគាត់ត្រូវបានគេបញ្ជូនឲ្យទៅធ្វើជាអ្នកយាមនៅមន្ទីរ ស-២១ ក្នុងខែកក្កដា ឆ្នាំ១៩៧៥ រហូតដល់យ៉ាងហោចណាស់ឆ្នាំ១៩៧៧[22]។សាក្សីនេះក៏បានបញ្ជាក់ ផងដែរថា គាត់ត្រូវបានគេចាត់ឲ្យយាមមួយរយៈនៅតាខ្មៅ

ដើម្បីឃ្លាំមើលអ្នកទោស ប៉ុន្តែត្រូវបានគេផ្ទេរទៅមន្ទីរ ស-២១ វិញ[23]។ នៅពាក់កណ្តាលឆ្នាំ១៩៧៨ សាក្សីនេះ ត្រូវបានគេបញ្ជូនទៅធ្វើស្រែនៅព្រៃស[24]។

## ជម្លោះប្រដាប់អាវុធ

3. សាក្សីនេះអាចផ្តល់ភស្តុតាងអំពីការប្រយុទ្ធគ្នាមុនសម័យកម្ពុជាប្រជាធិបតេយ្យ ដែលបានកើតឡើងនៅតាមផ្លូវជាតិលេខ២១ តាមបណ្តោយទន្លេមេគង្គក្នុងអំឡុងឆ្នាំ១៩៧៥[25]។ សាក្សីនេះក៏បានប្រយុទ្ធក្នុងសមរភូមិទន្លេបាសាក់ផងដែរ[26]។ សាក្សីនេះមិនបានចូលរួមក្នុងការវាយប្រយុទ្ធចុងក្រោយទេ ពីព្រោះគាត់បានរងរបួស ហើយបានសម្រាកនៅមន្ទីរពេទ្យព្រៃតាតុក ក្នុងស្រុកកោះធំ[27]។

## តួនាទីរបស់ជនជាប់ចោទ

4. សាក្សីនេះអាចបង្ហាញភស្តុតាងថា **ឌុច** គឺជាប្រធានមន្ទីរ ស-២១[28]។ ហើយសាក្សីក៏បានចូលរួម ផងដែរ ក្នុងការប្រជុំកងទ័ពដ៏ធំមួយ ដែលមានទិសដៅ "ពង្រឹងគោលជំហរនយោបាយ និងការអនុវត្ត ការងារឱ្យបានល្អ" ដែលរួមទាំងការឡើងថ្លែងរបស់ **ឌុច** ដែលពិភាក្សាអំពី "បញ្ហាដូចជាការតស៊ូវណ្ណៈ ការកម្ទេចពួកសក្តិភូមិ និងពង្រឹងវណ្ណៈអធន"[29]។ នៅក្នុងពាក់កណ្តាលឆ្នាំ១៩៧៨ សាក្សីនេះបានឃើញ**ឌុច**ទៅពិនិត្យ មើលព្រៃសយូរៗម្តងដើម្បីដាក់បញ្ជាដល់អ្នកក្រោមបង្គាប់របស់គាត់នៅទីនោះ[30]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

5. សាក្សីនេះបានធ្វើការនៅមន្ទីរ ស-២១ ពីខែកក្កដា ឆ្នាំ១៩៧៥ ដល់ពាក់កណ្តាលឆ្នាំ១៩៧៨ ដោយមួយរយៈពេលខ្លីគាត់ត្រូវបានគេផ្ទេរទៅព្រៃសក្នុងឆ្នាំ១៩៧៦[31]។ នៅពេលដែលសាក្សីចាប់ផ្តើមធ្វើការងារជា អ្នកយាម គុកទួលស្លែងមិនទាន់ត្រូវបានសង់រួចរាល់នៅឡើយទេ ហើយអ្នកទោសត្រូវបានគេឃុំឃាំងក្នុងផ្ទះ ឈើស្ថិតនៅខាងលិចទួលស្លែង[32]។ មានអ្នកទោសបី ទៅបួននាក់ក្នុងផ្ទះនីមួយៗ ហើយមានផ្ទះទាំងអស់បី ទៅបួនផ្ទះ[33]។ ក្នុងពេលយាមផ្ទះទាំងនោះ មានវេនយាមថ្ងៃ និងវេនយាមយប់ចាប់ពីល្ងាចដល់ពាក់កណ្តាល យប់ និងពីពាក់កណ្តាលយប់ ដល់ម៉ោងប្រាំមួយព្រឹក ផ្លាស់វេនគ្នា[34]។ អ្នកយាមទាំងអស់ត្រូវបានគេប្រាប់ឱ្យ ប្រុងប្រយ័ត្ន និងមិនត្រូវអនុញ្ញាតឱ្យអ្នកទោសលួចរត់ឡើយ ហើយត្រូវបានគេហាមឃាត់មិនឱ្យទាក់ទងគ្នា ជាមួយអ្នកទោសឡើយ[35]។ អ្នកយាមទាំងអស់ដែលមានកំហុសត្រូវបានគេចោទថាជាខ្មាំង ហើយសាក្សីនេះ មានអារម្មណ៍ថាគាត់ធ្លាក់ក្នុងអន្ទាក់របស់គេ ក្នុងការធ្វើជាអ្នកយាម គាត់ចង់រត់ចេញពីទីនោះ ប៉ុន្តែគាត់ខ្លាច គេសម្លាប់ប្រសិនបើគាត់ពិតជារត់ចេញមែន[36]។ ការអនុវត្តបែបនេះបាន

បន្តរហូតដល់ឆ្នាំ១៩៧៦ នៅពេលដែលទួលស្លែងត្រូវបានសាងសង់ចប់សព្វគ្រប់ហើយ អ្នកទោសត្រូវបានគេផ្ទេរពីផ្ទះទាំងនោះចូលទៅក្នុងគុក ដែលបានសាងសង់រួចនោះ[37]។ សាក្សីនេះត្រូវបានគេដាក់ភារកិច្ចឱ្យយាមជាន់ទីមួយនៃអគារកណ្តាល ដែល មានបន្ទប់ឃុំខ្លួនតូចៗ សម្រាប់ដាក់អ្នកទោសម្នាក់ៗ[38]។ មន្ទីរ ស-២១ មានអង្គភាពនាំសារ អង្គភាពសួរ ចម្លើយ និងអង្គភាពការពារ[39]។ នៅពេលណាដែលអ្នកទោសបានមកដល់ ឬក៏ចាកចេញពីមន្ទីរ ស-២១ អ្នកទោសត្រូវបានគេចងមុខ និងដាក់ខ្នោះដៃ[40]។

## រចនាសម្ព័ន្ធសិទ្ធិអំណាច

6. សាក្សីនេះអាចផ្តល់ភស្តុតាងថា **ឌុច** គឺជាប្រធានមន្ទីរ ស-២១។ សាក្សីនេះបានឃើញថា **ប៉េង, ហ៊ុយ** និង**ស៊្រី/ទ្រី** ជាសមាជិកជាន់ខ្ពស់បីនាក់ទៀតនៃមន្ទីរ ស-២១ ដែលទទួលបន្ទុកអ្នកយាមទាំងអស់[41]។ សាក្សីនេះ បានពិពណ៌នាថា គាត់បានឃើញ **ឌុច** និង **ហ៊ី** ធ្វើជាប្រធានក្នុងពេលមានការប្រជុំធំមួយ[42]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

7. សាក្សីនេះអាចបង្ហាញភស្តុតាងអំពីវត្តមាននៃបុរស ស្ត្រី និងកុមារនៅមន្ទីរ ស-២១[43]។ នៅពេលដែលគុកនោះស្ថិតនៅក្នុងផ្ទះជុំវិញទួលស្លែង អ្នកទោសទាំងនោះគឺជា "កម្មាភិបាល និងយុទ្ធជន"[44]។ នៅក្នុងគុកដែលទើបតែបង្កើតថ្មី សាក្សីនេះបានចាំថា មានទាហានវៀតណាមបួន ទៅប្រាំនាក់ ត្រូវបានគេឃុំឃាំងនៅ ទីនោះដែរ[45]។ សាក្សីនេះក៏បានបញ្ជាក់ថា មានអ្នកយាមចំនួនបីកងអនុសេនាតូច ដែលបង្កើតចេញជា៩ក្រុម។ "បន្ទាប់ពីមានការចម្រាញ់រួចមក នៅសល់តែប្រាំក្រុមប៉ុណ្ណោះ។ ក្នុងចំណោមអ្នកដែលបានបាត់ខ្លួន មានអ្នកខ្លះ ត្រូវបានចាប់ខ្លួន ហើយឃុំឃាំងនៅក្នុងគុក ស-២១ និងអ្នកខ្លះទៀតត្រូវបានបញ្ជូនទៅព្រៃសដើម្បីធ្វើស្រែ ហើយក្រោយមកក៏ត្រូវបញ្ជូនត្រលប់ទៅមន្ទីរ ស-២១ វិញ"[46]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

8. សាក្សីនេះអាចបង្ហាញភស្តុតាងអំពីអ្នកទោសដែលត្រូវបានគេដាក់ខ្នោះជើងក្នុងពេលជាប់ឃុំឃាំង[47]។ អ្នកទោសត្រូវបានគេផ្តល់អាហារពីរដងក្នុងមួយថ្ងៃប៉ុណ្ណោះ ដែលមានបាយមួយចាន និងសម្លមួយចាន ដែលរបបអាហារនេះសាក្សីរូបនេះយល់ថា "មិនគ្រប់គ្រាន់ឡើយ"[48]។ អ្នកទោសត្រូវបានគេងូតទឹកឱ្យក្នុងរយៈពេលពីរទៅបីថ្ងៃម្តងដោយបាញ់នឹងទុយោទឹក ក្នុងខណៈដែលអ្នកទោសទាំងនោះនៅជាប់ខ្នោះជើង ហើយគេឱ្យអ្នកយាមធ្វើការសំអាតបន្ទប់ឃុំឃាំងនៅពេលនោះផងដែរ[49]។ សាក្សីនេះ បញ្ជាក់ថា

មានពេទ្យ[50]។ សាក្សីនេះបាននឹកឃើញអ្នកទោសម្នាក់ដែលបានស្លាប់នៅក្នុងបន្ទប់ឃុំខ្លួន ដោយសារតែជំងឺរាកមួល[51]។

## ការសួរចម្លើយ

9. សាក្សីនេះបានដឹងថា មានការសួរចម្លើយនៅមន្ទីរ ស-២១ ប៉ុន្តែគាត់មិនត្រូវបានគេសួរចម្លើយ និងមិនបានឃើញការសួរចម្លើយណាមួយទេ[52]។

## ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

10. សាក្សីជឿថា ការធ្វើទារុណកម្ម និង ការប្រើហិង្សាលើរាងកាយបានកើតមាននៅមន្ទីរ ស-២១ ពីព្រោះ "នៅពេលដែលពួកគេយកអ្នកទោសត្រលប់មកវិញ ខ្ញុំបានឃើញសភាពទ្រុឌទ្រោម។ នៅពេលដែលពួកគេដោះខោអាវដើម្បីងូតទឹក ខ្ញុំបានឃើញស្នាមរបួសនៅលើខ្នងរបស់ពួកគេ ស្នាមរំពាត់ដែលពួកគេត្រូវបានគេវាយ"[53]។ សាក្សីនេះបានឮសម្រែកចេញពីបន្ទប់សួរចម្លើយ[54]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

11. សាក្សីនេះបានឃើញការសម្លាប់ផ្ទាល់ភ្នែកនៅបរិវេណមន្ទីរ ស-២១។ ក្នុងឆ្នាំ១៩៧៧ នៅពេលល្ងាចថ្ងៃមួយ មានការដឹកអ្នកទោសមកមន្ទីរ ស-២១ ហើយសាក្សីនេះត្រូវបានគេណែនាំឱ្យនាំយកអ្នកទោសទៅ "កន្លែងប្រហារជីវិត" ដែលមានចម្ងាយ ៣០ម ពី "ផ្ទះនោះ"[55]។ បទបញ្ជានេះចេញមកពី ប៉េង[56] និង ហ៊ុយ[57]។ នៅពេលដែលសាក្សីនេះបានយកអ្នកទោសមកដល់ គាត់បានឃើញគេជីករណ្តៅទុករួចជាស្រេចហើយ[58]។ អ្នកទោសត្រូវបានគេដាក់នៅជិតមាត់រណ្តៅ "សម្លាប់ (ពួកគេ) ដោយប្រើដំបង ដែកវាយគល់កពីក្រោយ" "បន្ទាប់មកពួកគេបានធាក់អ្នកទោសទម្លាក់ចូលរណ្តៅ ដោះខ្នោះដៃចេញ វះពោះពួកគេដោយប្រើកាំបិត ហើយបន្ទាប់មកក៏បានកប់រណ្តៅទាំងនោះ"[59]។ សាក្សីនេះបញ្ជាក់ថា មានសាកសពប្រហែល ៥ប់នាក់ ក្នុងរណ្តៅនីមួយៗមុនពេលដែលរណ្តៅទាំងនោះត្រូវបានគេកប់[60]។ លើកលែងករណីនេះចេញ សាក្សីនេះជឿថាការប្រហារជីវិតភាគច្រើនបានកើតឡើងនៅកន្លែងផ្សេងទៀត នៅពេលដែលអ្នកទោសត្រូវបានគេដឹកយកចេញទៅ[61]។

## សក្ខីកម្មមុនៗ

12. សាក្សីរូបនេះបានផ្តល់ចម្លើយមុនចំនួនពីរតាមការដឹងរបស់សហព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់ ផែម ឈិន ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី11 ខែមករា ឆ្នាំ2008, D28/13, ERN 00163790-00163795 (ភាសាអង់គ្លេស), 00163785-00163789 (ភាសាខ្មែរ)។

(2) បទសម្ភាសន៍របស់ ផែម ឈិន ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី4 ខែធ្នូ ឆ្នាំ2002, ដីកាសន្និដ្ឋាន បញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, 19.22, ERN 00054320-00054370 (ភាសាខ្មែរ); ខ្លឹមសារសង្ខេប ជាភាសាអង់គ្លេស (ERN 00184106-00184107)។

## ឯកសារពាក់ព័ន្ធដទៃទៀត

13. មិនមានឯកសារពាក់ព័ន្ធជាក់លាក់ផ្សេងទៀតដែលចម្លើយរបស់សាក្សីបាននិយាយយោងដល់ឡើយ។

## 3. ឈឹម ផាង

## ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីរូបនេះផ្តល់ភស្តុតាងអំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145*។ ចំពោះមន្ទីរ ស-២១ សាក្សីនេះនឹងបង្ហាញភស្តុតាងចំពោះតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច*(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងមនុស្សខុសច្បាប់ កង្វះខាតការជំនុំជម្រះទោសប្រកបដោយភាព យុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ប្រជាជនឱ្យទៅជាទាសករ ការទទួលរងការឈឺចាប់ ធ្ងន់ធ្ងរ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការធ្វើទារុណកម្ម និងការធ្វើបាបយ៉ាងអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល មនុស្សឃាត ការសម្លាប់អ្នកជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140 & 151)*។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹង បទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនកម្រិតត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីរូបនេះ ភេទប្រុស ជនជាតិខ្មែរ អាយុប្រមាណ ២៤ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[62]។ មុនឆ្នាំ1975 គាត់គឺជាកងឈ្លបស្រុកព្រៃមូល[63]។ គាត់បានទទួលការហ្វឹកហាត់យោធានៅមណ្ឌលមួយខាងលិចតាខ្មៅអស់រយៈពេលជាងបីខែ និងជាអ្នកយាមនៅមន្ទីរ ស-២១ ពីឆ្នាំ1975 ដល់ ឆ្នាំ1979[64]។ ប៉េង និង ហ៊ី បានចោទគាត់ថាបានលួចឯកសារ ហើយពួកគេក៏បានចាប់ខ្លួនគាត់[65]។ បន្ទាប់ពីនៅក្នុងគុកអស់រយៈពេល ១៥ថ្ងៃ គាត់ត្រូវបានដោះលែងវិញ[66]។

## ជម្លោះប្រដាប់អាវុធ

3. សាក្សីនេះផ្តល់ភស្តុតាងថា ឈ្លើយសឹកត្រូវបាននាំយកមកមន្ទីរ ស-២១ តាមរថយន្តធំៗ។ គាត់មិនបានបញ្ជាក់ថាតើអ្នកទោសទាំងនោះជាជនជាតិវៀតណាម ឬមិនមែននោះទេ[67]។

## តួនាទីរបស់ជនជាប់ចោទ

4. សាក្សីនេះផ្តល់ភស្តុតាងថា **ឌុច** គឺជាប្រធានមន្ទីរ ស-២១[68]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

5. សាក្សីនេះផ្តល់ភស្តុតាងថា ប៊ុន គឺជាប្រធានក្រុមរបស់គាត់នៅមន្ទីរ ស-២១[69]។ ប៉េង ទទួលបន្ទុកអង្គភាព៥០[70]។ ហ៊ី ជាមេរបស់ ប៉េង[71]។

6. សាក្សីនេះផ្តល់ភស្តុតាងថា គាត់គឺជាអ្នកយាមនៅខាងក្នុង និងខាងក្រៅគុក[72]។ នៅពេលយាមខាងក្នុង គាត់បានយកអាហារឱ្យអ្នកទោស[73]។ សាក្សីនេះផ្តល់ភស្តុតាងថា គាត់ត្រូវបានគេឱ្យកងមួយ ហើយគេបញ្ជាឱ្យយាមនៅកន្លែងមួយខាងត្បូងវត្តមហាមន្ត្រីនៅតាមផ្លូវជិតស្ថានទូតចិន និងនៅវិមានឯករាជ្យនៅពេលយប់[74]។ នៅពេលថ្ងៃ គេឱ្យគាត់ដាំបន្លែ និងដើររកឧស[75]។

7. សាក្សីនេះផ្តល់ភស្តុតាងថា មានវេនយាមមួយនៅពេលថ្ងៃត្រង់ និងវេនយាមមួយទៀតនៅពាក់កណ្តាលយប់[76]។

## វចនាសម្ព័ន្ធសិទ្ធិអំណាច

8. សាក្សីនេះនឹងបង្ហាញភស្តុតាងថា ឌុច ជាប្រធានមន្ទីរ ស-២១ ហើយ ហ៊ី, ប៉េង និង ចាន់ សម្រែង គឺជាថ្នាក់ដឹកនាំនៅមន្ទីរ ស-២១[77]។ សាក្សីនេះផ្តល់ភស្តុតាងថា ឌុច បានចូលទៅក្នុងគុកម្តងជារៀងរាល់ពីរសប្តាហ៍[78]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

9. សាក្សីនេះផ្តល់ភស្តុតាងថា គាត់ត្រូវបានគេដាក់គុករយៈពេល ១៥ថ្ងៃ ដោយសារគាត់ត្រូវបានគេចោទថាលួចឯកសារ[79]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

10. សាក្សីនេះផ្តល់ភស្តុតាងថា អ្នកទោសស្រាលត្រូវបានគេឱ្យធ្វើស៊ុមទ្វារ និងបង្អួច[80]។

## ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

11. សាក្សីនេះផ្តល់ភស្តុតាងថា ប្រសិនបើអ្នកទោសស្លាប់ក្នុងបន្ទប់ អ្នកយាមប្រចាំការនោះត្រូវយកអ្នកទោសនោះទៅកប់[81]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

12. សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានឃើញការសម្លាប់អ្នកទោសនៅកន្លែងជាច្រើន ដូចជានៅភូមិចិក ខាងត្បូងរោងចក្រកែវ។ អ្នកទោសត្រូវបានគេនាំយកទៅទីនោះតាមរថយន្តធំៗ ហើយត្រូវបានគេសម្លាប់ចោល[82]។

## សក្ខីកម្មមុនៗ

13. សាក្សីរូបនេះបានផ្តល់ចម្លើយមុនមួយដល់ព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់ ឈឹម ផាង ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី16 ខែមីនា ឆ្នាំ2002, D59, ERN 00057140-00057180 (ភាសាខ្មែរ)។

## ឯកសារពាក់ព័ន្ធដទៃទៀត

14. មិនមានឯកសារពាក់ព័ន្ធជាក់លាក់ផ្សេងទៀតដែលចម្លើយនិយាយយោងដល់ឡើយ។

## 4. អៀម ហាន ហៅម៉ឹង

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីរូបនេះផ្តល់ភស្តុតាងអំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* និងគោលនយោបាយព្រមទាំងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ចំពោះមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161),* ការបង្កើតរយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច*(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំមនុស្សខុសច្បាប់ កង្វះខាតការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ឱ្យទៅជាទាសករ ការទទួលរងការឈឺចាប់ធ្ងន់ធ្ងរ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបយ៉ាងអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល និងមនុស្សឃាតនិងការសម្លាប់ ជនជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយ សាក្សីរូបនេះ រួមមាន ប៉ុន្តែមិនមែនកម្រិតត្រឹមតែ អង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីអាយុប្រមាណ ២២ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភេទប្រុស ជនជាតិខ្មែរ កើតនៅឆ្នាំ១៩៥៣[83]មិនចាំខែ។ ក្នុងឆ្នាំ១៩៧៥ សាក្សីនេះបានចូលធ្វើទាហានក្នុងកងវរសេនាធំ១១២ នៃកងពលធំ៧០៣[84]។ គាត់គឺជាអ្នកយាមនៅកន្លែងផ្សេងៗគ្នា ហើយចុងក្រោយគាត់ត្រូវបានគេផ្ទេរទៅទួលស្លែងដើម្បីធ្វើជាអ្នកយាមក្នុងឆ្នាំ១៩៧៦[85]។ ចុងក្រោយ សាក្សីនេះត្រូវបានចាប់ខ្លួនដោយ ហ៊ុយ ដោយគាត់មិនបានដឹងអំពីមូលហេតុក្នុងការចាប់ខ្លួនគាត់ឡើយ ប៉ុន្តែគាត់ជឿថា វាបណ្តាលមកពីគាត់ដេកនៅពេលបំពេញការងារ[86]។ ចុងក្រោយ គាត់ក៏ត្រូវបានគេដោះលែង[87]។

### ជម្លោះប្រដាប់អាវុធ

3. សាក្សីនេះផ្តល់ភស្តុតាងថា ក្នុងឆ្នាំ១៩៧៦ ចំនួនដ៏ច្រើននៃអ្នកទោសថ្មីបានមកដល់មន្ទីរ ស-២១ ដែលមានទាំងទាហាន អ្នកសហករណ៍ និងជនជាតិវៀតណាម។ ជនជាតិវៀតណាមនិយាយតែភាសាវៀតណាម

អត់ចេះនិយាយខ្មែរឡើយ[88]។ សាក្សីនេះផ្តល់ភស្តុតាងថា អ្នកទោសវៀតណាមទាំងនេះ មានវ័យក្មេង និងវ័យចំណាស់ ប៉ុន្តែជា "យួន"[89] ទាំងអស់។ ពួកគេពាក់ឯកសណ្ឋានកងទ័ពវៀតណាម ជាមួយនឹងមួក ហើយត្រូវបានគេដាក់ខ្នោះដៃ និងចងមុខ[90]។ សាក្សីនេះផ្តល់ភស្តុតាងថា សរុបមាន "យួន" រាប់រយនាក់[91]។

4. សាក្សីនេះផ្តល់ភស្តុតាងថា ទាហានវៀតណាមទាំងអស់ត្រូវបានគេសួរចម្លើយ ហើយអ្នកខ្លះបានទទួលរងរបួស[92]។

## វចនាសម្ព័ន្ធ និងគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ

5. សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានឃើញ **ឌុច** និង ប៉េង មានវត្តមាននៅក្នុងវគ្គអប់រំនៅមន្ទីរ ស-២១ ហើយសិស្សដែលចូលរួមផងទៃទៀតក៏បានឃើញ ប៊ុល ពត, ខៀវ សំផន និង នួន ជា នៅក្នុងវគ្គអប់រំនោះផងដែរ[93]។ របបនេះបានដាក់ចេញនូវពាក្យស្លោកមួយថា "បំបាក់កម្លាំងខ្មាំង ឪពុកម្តាយ [របស់យើង] ក៏ជាខ្មាំងដែរ ហើយពួកគេក៏ត្រូវប្រហារជីវិតដែរ មានតែមនុស្សល្អទេដែលអាចធ្វើជាឪពុកម្តាយ"[94]។

## តួនាទីរបស់ជនជាប់ចោទ

6. សាក្សីនេះផ្តល់ភស្តុតាងថា មនុស្សជាច្រើនគិតថា ប្រធានមន្ទីរ ស-២១ គឺជា **ឌុច**[95]។ សាក្សីនេះក៏បានផ្តល់ភស្តុតាងថា គាត់បានឃើញ ហ៊ី, ហ៊ុយ និង **ឌុច** នៅព្រៃស[96]។ **ឌុច** តែងតែនៅព្រៃស ជាពិសេសនៅពេលដែលអ្នកទោសត្រូវបានគេយកចេញទៅនៅពេលយប់[97]។ **ឌុច** បានប្រាប់អ្នកដែលដឹកអ្នកទោសទាំងនោះថា ពួកគេគួរតែដឹងពីចំនួនអ្នកទោសដែលដឹកយកទៅមន្ទីរ ស-២១[98]។ បន្ទាប់ពីផ្ទេរអ្នកទោសរួចហើយ **ឌុច** បានចាកចេញទៅវិញតាមរថយន្តតូច ដែលអមរថយន្តធំដឹកអ្នកទោស[99]។ សាក្សីនេះផ្តល់ភស្តុតាងថា នៅពេលដែលគាត់យាមនៅខាងក្នុងមន្ទីរ ស-២១ គាត់បានឃើញ **ឌុច** ប៉ុន្តែមិនដែលបាននិយាយជាមួយគាត់ទេ[100]។ សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានឃើញ **ឌុច** នៅក្នុងវគ្គសិក្សានយោបាយនានាអំពីកម្ពុជា ដែលវគ្គសិក្សានោះបង្រៀនអំពីរបៀបកសាងកម្ពុជាឲ្យកាន់តែក្លាយទៅជារបបសង្គមនិយម[101]។ សាក្សីនេះផ្តល់ភស្តុតាងថា **ឌុច** គឺជាប្រធាន ប៉ុន្តែមិនដែលបានដាក់វិន័យដល់រូបគាត់ទេ[102]។ គាត់ក៏មិនដែលបានឃើញ **ឌុច** ធ្វើទារុណកម្មនរណាម្នាក់ដែរ[103]។ សាក្សីនេះបាននិយាយថា ឌុច បានជួបជាមួយ ប៉េង នៅពេលដែលមានបញ្ហានៅមន្ទីរ ស-២១[104]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

7. សាក្សីនេះផ្តល់ភស្តុតាងថា ប្រធានក្រុមរបស់គាត់នៅមន្ទីរ ស-២១ គឺឈ្មោះ ចំរើន ហើយមានអ្នកយាមចំនួន១២នាក់ ក្នុងមួយកងអនុសេនាតូច ហើយក្នុងមួយក្រុមមានអ្នកយាមបួននាក់[105]។ ក្រោយមក ចំរើនក៏ត្រូវបានចាប់ខ្លួន[106]។

8. សាក្សីនេះផ្តល់ភស្តុតាងថា នៅពេលដែលគាត់យាមនៅខាងក្នុង ប្រសិនបើមានបន្ទប់ទំនេរ គាត់បាននាំយកអ្នកទោសថ្មីៗទៅបន្ទប់នោះ ដោយស្រាយមុខចេញ ដោះខ្នោះដៃចេញ ហើយឃុំពួកគេដោយដាក់ខ្នោះជើង[107]។ សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានយល់អំពីវិន័យនៅក្នុងមន្ទីរ ស-២១ ដែលថា តួនាទីអ្នកយាមគឺយាម គិតតែពីភារកិច្ចរបស់ខ្លួនប៉ុណ្ណោះ ហើយត្រូវបានគេហាមប្រាមមិនឲ្យនិយាយជាមួយអ្នកដទៃឡើយ[108]។

9. សម្រាប់អ្នកយាម មានវេនយាមមួយនៅពេលព្រឹក និងវេនយាមមួយនៅពេលថ្ងៃត្រង់[109]។ មានវេនយាមដូចគ្នានេះដែរនៅពេលយប់[110]។ សាក្សីនេះត្រូវយាមពីរវេន ក្នុងមួយថ្ងៃមួយយប់[111]។

10. អ្នកទោសនៅខាងក្នុងត្រូវបានគេផ្តល់អាហារពីរដងក្នុងមួយថ្ងៃ ហើយអ្នកទោសទទួលបានបាយមួយចាននិងសម្លមួយចានក្នុងរបបអាហារមួយពេល[112]។

11. សាក្សីនេះផ្តល់ភស្តុតាងថា មានអ្នកទោសទាំងស្រីទាំងប្រុសនៅមន្ទីរ ស-២១ ប៉ុន្តែគាត់មិនដែលបានឃើញកុមារទេ[113]។

## រចនាសម្ព័ន្ធសិទ្ធិអំណាច

12. សាក្សីនេះផ្តល់ភស្តុតាងថា **ឌុច** គឺជាប្រធានមន្ទីរ ស-២១ ហ៊ី គឺជាអនុប្រធាន និង ប៉េង នៅក្នុងកងវរសេនាធំក្រោម ហ៊ី និង **ឌុច**[114]។

## ការដាក់មន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

13. សាក្សីនេះផ្តល់ភស្តុតាងថា អ្នកទោសទាំងអស់ត្រូវបានចងមុខ និងដាក់ខ្នោះដៃ នៅពេលដែលពួកគេត្រូវផ្ទេរតាមរថយន្តធំៗទៅកាន់មន្ទីរ ស-២១[115]។ អ្នកទោសភាគច្រើន បានមកដល់មន្ទីរ ស-២១ ក្នុង

អំឡុងពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨[116]។ គាត់មិនបានដឹងថាតើអ្នកទោសទាំងនោះត្រូវបានគេនាំយកមកសួរចម្លើយឬយ៉ាងណានោះទេ[117]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

14. សាក្សីនេះផ្តល់ភស្តុតាងថា ប្រសិនបើអ្នកទោសមានមាឌធំ នោះជើងទាំងពីររបស់គេត្រូវដាក់ខ្នោះ[118]។ សាក្សីនេះផ្តល់ភស្តុតាងថា អ្នកទោសស្ត្រីជាច្រើនបានឆ្លងទន្លេក្នុងខណៈដែលពួកគេជាប់ឃុំឃាំង[119]។ ជាធម្មតាស្ត្រីមានផ្ទៃពោះត្រូវបានគេដាក់ច្រវាក់កជើង ហើយស្ត្រីនោះត្រូវបានគេ "ដាក់ខ្នោះជើង" ប្រសិនបើស្ត្រីនោះបង្កបញ្ហាជាមួយអ្នកយាម[120]។

15. សាក្សីនោះក៏បានផ្តល់ភស្តុតាងថា នៅពេលដែលគាត់ត្រូវគេចាប់ខ្លួន គាត់ត្រូវបានគេដាក់ច្រវាក់ ហើយមិនត្រូវបានគេអនុញ្ញាតឱ្យនិយាយឡើយ[121]។ គាត់មិន [បានដឹងអំពី] មូលហេតុនៃការចាប់ខ្លួនគាត់ឡើយ ហើយត្រូវបានគេបង្អត់បាយ និងទឹករយៈពេលមួយសប្តាហ៍[122]។

16. សាក្សីនេះផ្តល់ភស្តុតាងថា អ្នកយាមបានឱ្យទុយោទឹកដល់អ្នកទោសបុរស ដើម្បីឱ្យពួកគេអាចងូតទឹក និងប្តូរសំលៀកបំពាក់ពួកគេ ប៉ុន្តែមិនអនុញ្ញាតឱ្យដោះខ្នោះជើងរបស់ពួកគេឡើយ[123]។ អ្នកទោសបន្ទោបង់ដាក់ក្នុងកេះគ្រាប់នៅក្នុងបន្ទប់ឃុំខ្លួនរបស់ពួកគេ ហើយអ្នកទោស "ស្រាល" បានដើរប្រមូលកេះនោះម្តងក្នុងមួយថ្ងៃ[124]។ អ្នកទោសស្ត្រីត្រូវបានគេអនុញ្ញាតឱ្យដោះច្រវាក់ចេញ ហើយស្លៀកពាក់ដោយខ្លួនឯង[125]។

## ការសួរចម្លើយ

17. សាក្សីនេះផ្តល់ភស្តុតាងថា អ្នកទោសខ្លះមានស្នាមរលាត់នៅលើខ្នងរបស់ពួកគេ ហើយសុខភាពរបស់អ្នកទោសដទៃទៀតបានចុះខ្សោយបន្ទាប់ពីការសួរចម្លើយ[126]។

## ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

18. សាក្សីនេះផ្តល់ភស្តុតាងថា គាត់មិនដែលបានឃើញ **ឌុច** ធ្វើទារុណកម្មនរណាម្នាក់ឡើយ[127]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

19. សាក្សីនេះផ្តល់ភស្តុតាងថា នៅពេលដែលគាត់ និងអ្នកយាមជាមួយគ្នាសួរអំពីទីកន្លែងឃុំខ្លួនអ្នកទោសសំខាន់ៗ ពួកគេត្រូវបានគេប្រាប់ឱ្យបំពេញតែភារកិច្ចរបស់ពួកគេជាអ្នកយាមទៅបានហើយ[128]។

20. សាក្សីនេះផ្តល់ភស្តុតាងថា អ្នកទោសខ្លះត្រូវបានគេឃើញស្លាប់នៅក្នុងបន្ទប់ឃុំខ្លួនរបស់ពួកគេបន្ទាប់ពីការសួរចម្លើយ[129]។ គាត់បានឃើញអ្នកទោសស្លាប់ជារៀងរាល់ថ្ងៃដោយសារតែរបួសធ្ងន់ធ្ងរបន្ទាប់ពីការសួរចម្លើយ[130]។ ជួនកាលក្នុងមួយថ្ងៃមានអ្នកទោសពីរនាក់ស្លាប់[131]។

## សក្ខីកម្មមុនៗ

21. សាក្សីរូបនេះបានផ្តល់ចម្លើយមុនពីរតាមការដឹងរបស់សហព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់ អៀម ហាន ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧, D28/5, ERN 00163679-00163685 (ភាសាអង់គ្លេស)។

(2) បទសម្ភាសន៍របស់ អៀម ហាន ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២, ERN 00062423-00062427 (ភាសាខ្មែរ); ខ្លឹមសារសង្ខេប ជាភាសាអង់គ្លេស (ERN 00184114-00184116)។

## ឯកសារពាក់ព័ន្ធដទៃទៀត

22. មិនមានឯកសារពាក់ព័ន្ធជាក់លាក់ផ្សេងទៀតដែលចម្លើយរបស់សាក្សីបាននិយាយយោងដល់ឡើយ។

## 5. ហ៊ីម ហេង

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ **ឌុច** *(55-59, 90-99, 107-111 & 153 [ថ្មី]-161),* ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច*(20-25)* ចំនួន និងប្រភេទនៃអ្នកជាប់ឃុំឃាំង ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំមនុស្សខុសច្បាប់ កង្វះខាតការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ប្រជាជនឱ្យទៅជាទាសករ ការទទួលរងការឈឺចាប់ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបយ៉ាងអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល និងមនុស្សឃាត និងការសម្លាប់ជនជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])* ដែលបានកើតឡើងនៅមន្ទីរ ស-២១។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនកម្រិតត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះ ទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីនេះជាអ្នកស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង អាយុប្រមាណ១២ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភេទប្រុស ជនជាតិខ្មែរ ប្រហែលកើតក្នុងឆ្នាំ១៩៦៣។ ក្នុងពាក់កណ្តាលឆ្នាំ១៩៧៦ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានក្តាប់អំណាច សាក្សីនេះត្រូវបានគេបញ្ជូនទៅតាខ្មៅដើម្បីហ្វឹកហាត់យោធាជាមួយអ្នកហ្វឹកហាត់មួយក្រុមមានចំនួន ១.០០០នាក់។ បន្ទាប់ពីការហ្វឹកហាត់រយៈពេលបីខែ គាត់ត្រូវបានគេបញ្ជូនឱ្យទៅធ្វើស្រែនៅព្រៃស និងទន្ទឹមពេលគ្នានោះដែរគាត់ធ្វើជាអ្នកយាមនៅមន្ទីរ ស-២១ រហូតដល់របបនោះដួលរលំ។

### ការបង្កើត រយៈពេល និងប្រតិបត្តិការ

3. សាក្សីនេះផ្តល់ភស្តុតាងថា គាត់បម្រើការនៅមន្ទីរ ស-២១ និងនៅព្រៃស ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៩។ គាត់បានចេញចូលមន្ទីរ ស-២១ ម្តងម្កាលក្នុងអំឡុងរយៈពេលគាត់នៅមន្ទីរ ស-២១។ សាក្សីនេះបញ្ជាក់ថា មានអគារបួនក្នុងមន្ទីរ ស-២១ និងមានច្រកចូលពីរ[132]។ មានរបងបីជាន់។ ខ្សែភ្លើងត្រូវបានគេដាក់នៅផ្នែកកណ្តាលដើម្បីការពារកុំឱ្យអ្នកទោសលួចរត់[133]។ សមាជិកក្រុមអ្នកសួរចម្លើយ

ភាគច្រើនមានវ័យចំណាស់ជាងសមាជិកនៃក្រុមអ្នកចាប់ចង[134]។ អ្នកទោសស្ត្រីខ្លះត្រូវបានគេឱ្យធ្វើជាចុងភៅ[135]។ ពេទ្យក៏មានដែរនៅទីនោះ ប៉ុន្តែពេទ្យទាំងនោះមិនបានយកចិត្តទុកដាក់ ដល់អ្នកដែលត្រូវបានគេសួរចម្លើយឡើយ[136]។ អ្នកទោសបុរសត្រូវបានគេឃុំខ្លួនដោយឡែកពីអ្នកទោសស្ត្រី[137]។

## វចនាសម្ព័ន្ធសិទ្ធិអំណាច

4. សាក្សីនេះផ្តល់ភស្តុតាងថា ឌុច គឺជាអាជ្ញាធរជាន់ខ្ពស់បំផុតនៃមន្ទីរ ស-២១ ហើយថា ហ៊ី គឺជាអនុ និង ប៉េង គឺជា [ប្រធាន] កងរយ។ សាក្សីនេះផ្តល់ភស្តុតាងថា អ្នកយាមត្រូវបានគេរៀបចំជាបីក្រុមដែលទទួលបន្ទុកក្នុងការចាប់ចង ការពារ និងសួរចម្លើយ[138]។ ក្រុមការពាររបស់គាត់មានគ្នា ១២នាក់។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

5. សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានឃើញស្ត្រីជាមួយនឹងទារក ជនបរទេស រួមមាន ជនជាតិអាមេរិកពីររូប និងទាហានវៀតណាមជាច្រើនត្រូវបានគេឃុំខ្លួនដោយខុសច្បាប់នៅមន្ទីរ ស-២១។ គាត់ក៏បានឃើញមន្ត្រីថ្នាក់ខ្ពស់ និងថ្នាក់កណ្តាលរបស់ខ្មែរក្រហម រួមទាំងមេក្រុមរបស់គាត់ខ្លះត្រូវបានគេចាប់ដាក់គុកនៅមន្ទីរ ស-២១ ផងដែរ។ គាត់បញ្ជាក់ថា ក្រុមរបស់គាត់ និងក្រុមដទៃទៀតមិនត្រូវបានគេអនុញ្ញាតឱ្យមើលកន្លែង ដែលគេឃុំខ្លួនអ្នកទោសខ្មែរក្រហមជាន់ខ្ពស់ឡើយ[139]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

6. សាក្សីនេះផ្តល់ភស្តុតាងថា អ្នកទោសបុរសៗត្រូវបានគេដាក់ខ្នោះជាជួរ ពី ១០-១៥នាក់[140]។ ក្នុងករណីភាគច្រើន អ្នកទោសស្ត្រីជាធម្មតាត្រូវបានគេដាក់ក្នុងបន្ទប់ចាក់សោរ[141]។ អ្នកទោសមិនត្រូវបានគេអនុញ្ញាតឱ្យស្លៀកខោជើងវែងឡើយ ដើម្បីការពារកុំឱ្យធ្វើអត្តឃាតដោយចងក។ អ្នកជាប់ឃុំឃាំងរស់នៅក្នុងលក្ខណៈថោកទាបយ៉ាងខ្លាំង[142]។ គាត់ត្រូវបានគេផ្តល់អាហារពីរពេលប៉ុណ្ណោះ (បបរ ឬបាយ) ក្នុងមួយថ្ងៃ : អាហារពេលព្រឹកនៅម៉ោង ១១ និងអាហារមួយពេលទៀតនៅម៉ោង ៥ល្ងាច[143]។ អត់មានបង្គន់ទេនៅក្នុងបន្ទប់ឃុំឃាំង។ អ្នកទោសត្រូវបន្ទោបង់ដាក់ក្នុងប្រអប់ប្លាស្ទីក និងត្រូវសុំប្រអប់ដាក់លាមកទាំងនេះពីអ្នកយាម[144]។

## ការសួរចម្លើយ

7. អ្នកទោសផ្ដល់ភស្ដុតាងថា អ្នកយាមតែងតែចាប់ផ្ដើមសួរចម្លើយអ្នកទោសបន្ទាប់ពីពួកគេត្រូវបានគេឃុំខ្លួននៅមន្ទីរ ស-២១ បានរយៈពេលមួយសប្ដាហ៍[145]។ គាត់បញ្ជាក់ថា គោលបំណងនៃការសួរចម្លើយនេះគឺដើម្បីស្វែងរក "ខ្មាំងស៊ីរូងផ្ទៃក្នុង" ហើយការសួរចម្លើយនេះគឺធ្វើឡើងនៅខាងក្រៅរបងមន្ទីរ ស-២១[146]។

## ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

8. សាក្សីនេះផ្ដល់ភស្ដុតាងថា អ្នកទោសជាធម្មតាត្រូវបានគេវាយ ហើយឃើញមានឈាមបន្ទាប់ពីត្រូវបានគេសួរចម្លើយរួច[147]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

9. សាក្សីនេះផ្ដល់ភស្ដុតាងថា គាត់បានឃើញអ្នកទោសដែលគេរុំមុខជិត ត្រូវបានគេយកដាក់បញ្ចូល រថយន្ត ហើយដឹកយកចេញទៅដោយក្រុមអ្នកចាប់ចង ពេលខ្លះមានចំនួនពីរ បី ទៅប្រាំនាក់[148]។ គាត់ បញ្ជាក់ថា អ្នកទោសវៀតណាមក៏ត្រូវបានគេយកទៅសួរចម្លើយដូចអ្នកទោសដទៃទៀតផងដែរ[149]។ជួនកាលអ្នកទោសបាត់ខ្លួនក្នុងរយៈពេលមួយខែ[150]។ សាក្សីនេះផ្ដល់ភស្ដុតាងថា គាត់បានឃើញកុមារម្នាក់បានបាត់ខ្លួនពីបន្ទប់ឃុំឃាំងនៅពេលដែលគាត់បានប្ដូរវេនយាម ហើយនៅពេលដែលគាត់បានសួរសំណួរទៅអ្នកយាមដែលប្រចាំការ គេឆ្លើយថាកុមារនោះត្រូវបានគេយកទៅបាត់ហើយ[151]។

## សក្ខីកម្មមុនៗ

10. សាក្សីបានផ្ដល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា :

    (1) បទសម្ភាសន៍របស់ ហ៊ឹម ខេង ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៥, D/59, ERN00088838-00088875 (ភាសាខ្មែរ)។

## ឯកសារពាក់ព័ន្ធដទៃទៀត

11. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយនៅក្នុងចម្លើយរបស់សាក្សី។

## 6. អៀម ឈុនគី

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីរូបនេះផ្ដល់ភស្តុតាងអំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* និងគោលនយោបាយព្រមទាំងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ចំពោះមន្ទីរ ស-២១ សាក្សីនេះផ្ដល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161)*, ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច*(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំមនុស្សខុសច្បាប់ កង្វះខាតការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ឱ្យទៅជាទាសករ ការទទួលរងការឈឺចាប់ធ្ងន់ធ្ងរ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបយ៉ាងអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល និងមនុស្សឃាត និងការសម្លាប់ជនជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្ដល់ដោយសាក្សីរូបនេះរួមមានប៉ុន្តែមិនមែនកម្រិតត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីនេះមានអាយុប្រមាណ ១៩ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភេទស្រី ជនជាតិខ្មែរ កើតឆ្នាំ១៩៥៦[152] មិនចាំខែ។ ក្នុងឆ្នាំ១៩៧៣ គាត់បានចូលបម្រើកងទ័ពក្នុងខេត្តកំពង់ឆ្នាំង ហើយបន្ទាប់មកក្នុងឆ្នាំ១៩៧៤ គាត់ត្រូវបានគេផ្ទេរទៅភូមិភាគចល័តក្នុងកងពលធំ៣១០[153]។ បន្ទាប់ពីភ្នំពេញត្រូវបានរំដោះ សាក្សីនេះបានបម្រើការនៅក្នុងអង្គភាពកាត់ដេរ ហើយក៏បានកាន់ទូរស័ព្ទ និងកត់ឈ្មោះ អ្នកដែលត្រូវបានគេចាប់ខ្លួនក្នុងកងពលធំនោះផងដែរ[154]។ សាក្សីនេះផ្ដល់ភស្តុតាងថា បន្ទាប់ពីបញ្ចប់ការសរសេរប្រវត្តិរូបក្នុងឆ្នាំ១៩៧៧ គាត់ក៏ត្រូវបានគេហៅឱ្យទៅប្រជុំ ប្រគល់សៀវភៅទៅឱ្យគេ បន្ទាប់មកក៏ត្រូវបានគេចាប់ខ្លួន ហើយយកទៅព្រៃស[155]។ នៅចុងឆ្នាំ១៩៧៨ គាត់ត្រូវបានគេបញ្ជូនទៅមន្ទីរ ស-២១ ដើម្បីរៀនអំពីរបៀបជួសជុលម៉ាស៊ីនបូមទឹកអស់រយៈពេលជិតបីខែ ជាមួយស្ត្រីប្រាំនាក់ដទៃទៀតមកពីព្រៃស រហូតដល់វៀតណាមបានវាយលុកចូលក្នុងខែមករា ឆ្នាំ១៩៧៩[156]។

## តួនាទីរបស់ជនជាប់ចោទ

3. សាក្សីនេះផ្តល់ភស្តុតាងថា ឌុច គឺជាប្រធានមន្ទីរ ស-២១[157]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

4. សាក្សីនេះផ្តល់ភស្តុតាងថា អ្នកបង្អាត់គឺជាអ្នកទោសជនជាតិវៀតណាមម្នាក់ និងអ្នកទោសជនជាតិខ្មែរម្នាក់[158]។ សាក្សីនេះបាននិយាយថា អ្នកសួរចម្លើយចំនួន ៣០នាក់ នៅមន្ទីរ ស-២១ ក៏បានចូលរៀនផងដែរ[159]។

## រចនាសម្ព័ន្ធសិទ្ធិអំណាច

5. សាក្សីនេះផ្តល់ភស្តុតាងថា ឌុច គឺជាប្រធានមន្ទីរ ស-២១ ដោយមាន ហ៊ី ជាអនុប្រធាន និង ហ៊ុយ គឺជាប្រធានព្រៃស[160]។ ផល គឺជាប្រធានអង្គភាពនារីនៅព្រៃស និង ខឿន គឺជាប្រធានក្រុម[161]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

6. សាក្សីនេះផ្តល់ភស្តុតាងថា ប្រជាជនត្រូវបានគេចោទថាក្បត់ជាតិ ឬក៏មានសីលធម៌មិនល្អ ហើយពួកគេត្រូវបានចាប់ខ្លួន និងបញ្ជូនទៅព្រៃស ឬក៏ទៅទួលស្លែង[162]។ សាក្សីនេះផ្តល់ភស្តុតាងថា មានអ្នកទោសជាង៤០០នាក់ ដែលមកពីភូមិភាគឧត្តរ និងនិរតី[163]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

7. សាក្សីនេះផ្តល់ភស្តុតាងថា នៅព្រៃស គាត់ត្រូវបានគេបង្ខំឱ្យធ្វើការជាទម្ងន់ ចាប់ពីម៉ោង ៣ព្រឹក រហូតដល់ម៉ោង ១១យប់ ហើយទទួលបានអាហារមិនគ្រប់គ្រាន់ឡើយ[164]។

8. សាក្សីនេះផ្តល់ភស្តុតាងថា ក្នុងខណៈគាត់រៀននៅមន្ទីរ ស-២១ អស់រយៈពេលជិតបីខែ គាត់បានទទួលអាហារឆ្ងាញ់បរិភោគ ផ្ទុយពីអ្នកទោសដែលត្រូវបានគេធ្វើបាប[165]។

## ការសួរចម្លើយ

9. សាក្សីនេះផ្តល់ភស្តុតាងថា អ្នកសួរចម្លើយ៣០នាក់ នៅមន្ទីរ ស-២១ បានចូលរៀនជាមួយគាត់[166]។ សាក្សីនេះផ្តល់ភស្តុតាងថា បន្ទាប់ពីពួកគេរៀនចប់នៅថ្ងៃនោះភ្លាម ពួកគេក៏បានទៅសួរចម្លើយអ្នកទោស[167]។

## ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

10. សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានឃើញអ្នកទោសនៅព្រៃសត្រូវបានគេទាត់ និងវាយ ក្នុងខណៈដែលអ្នកទោសដើររកអាហារហូបនៅក្នុងវាលស្រែ[168]។ នៅពេលរៀននៅមន្ទីរ ស-២១ សាក្សីនេះបានឃើញគេធ្វើទារុណកម្ម និងឆក់ខ្សែភ្លើងអ្នកទោស[169]។

## សក្ខីកម្មមុនៗ

11. សាក្សីនេះបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា:

(1) បទសម្ភាសន៍របស់ អៀម ឈុនគី ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៣, D59, ERN 00056411- 00056460(ភាសាខ្មែរ)។

## ឯកសារពាក់ព័ន្ធដទៃទៀត

12. មិនមានឯកសារពាក់ព័ន្ធជាក់លាក់ផ្សេងទៀតដែលចម្លើយរបស់សាក្សីបាននិយាយយោងដល់ឡើយ។

## 7. កែស ព្រឹក

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ចំពោះមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* និងរចនាសម្ព័ន្ធសិទ្ធិអំណាច *(20-25)*។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងឱ្យទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនកម្រិតត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីនេះមានអាយុប្រហែល ១៧ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភេទប្រុស ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៥៨។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីនេះបានធ្វើការជាកសិករនៅមន្ទីរតំបន់២៥។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានក្តាប់អំណាច សាក្សីនេះត្រូវបានគេចាត់តាំងឱ្យចូលរៀនវគ្គអប់រំនយោបាយនៅវត្តកោះខែល ក្នុងស្រុកស្អាង។ នៅចុងឆ្នាំ១៩៧៦ សាក្សីនេះត្រូវបានគេផ្ទេរឱ្យទៅធ្វើជាកងការពារនៅមន្ទីរ ស-២១ ជាមួយក្រុមចំនួនបីផ្សេងទៀតរបស់គាត់ដែលមានគ្នាប្រហែល ៣០នាក់។ មុនពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ គាត់បានវាយប្រយុទ្ធជាមួយវៀតណាម ហើយបានរងរបួស។ គាត់បានត្រលប់មកផ្ទះវិញក្នុងឆ្នាំ១៩៧៩ មួយឆ្នាំមុនពេលគាត់រៀបការ។

### តួនាទីរបស់ជនជាប់ចោទ

3. ជាអ្នកយាមនៅមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងថា ឌុច ដែលជាប្រធានគុក បានធ្វើជាប្រធានអង្គប្រជុំតែនៅពេលដែលអង្គភាពបញ្ចូលគ្នាទាំងអស់នៅក្នុងរចនាសម្ព័ន្ធមន្ទីរ ស-២១ ធ្វើការពិភាក្សា និងវាយតម្លៃអំពីការងាររបស់គេប៉ុណ្ណោះ[170]។

### រចនាសម្ព័ន្ធសិទ្ធិអំណាច

4. សាក្សីនេះផ្តល់ភស្តុតាងថា ឌុច គឺជាប្រធានមន្ទីរ ស-២១ ហើយថាអ្នកយាមទាំងអស់ត្រូវបានគេរៀបចំជាក្រុម។ ជាពិសេស ហ៊ី ទទួលបន្ទុកអង្គភាពការពារ នៅក្រោម ហ៊ុយ និង ស្រ៊ី ដែលជាប្រធានក្រុមការពារ[171]។ ប្រាក់ ខន ជាអ្នកសួរចម្លើយ ហើយ ចាន់ ទទួលបន្ទុកក្នុងការសួរ ចម្លើយ[172]។ សាក្សីនេះបញ្ជាក់ថា ការសួរចម្លើយត្រូវបានគេធ្វើឡើងនៅក្នុងផ្ទះខាងក្រៅរបងមន្ទីរ ស-២១[173]។ ហ៊ុយ

ស្រែ ទទួលបន្ទុកផ្នែកសេដ្ឋកិច្ចរបស់មន្ទីរ ស-២១ នៅមណ្ឌលលត់ដំព្រៃស ដែលជាទីកន្លែងគាត់គ្រប់គ្រងអ្នកទោសស្រាលៗ[174] ដែលស្ថិតនៅក្រោមការចោទប្រកាន់ក្នុងអំឡុងពេល សង្គ្រាម។

## សក្ខីកម្មមុនៗ

5. សាក្សីនេះបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់កែស ព្រីក ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៤, ERN00058430-00058467(ភាសាខ្មែរ) (មិនត្រូវបានបញ្ចេញឲ្យដឹងគិតមកត្រឹម ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨)។

## ឯកសារពាក់ព័ន្ធដទៃទៀត

6. មានវត្ថុតាងជាក់លាក់មួយដែលចម្លើយរបស់សាក្សីរូបនេះបាននិយាយដល់គឺ :

(1) ជីវប្រវត្តិរបស់ កែស ព្រីក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៦៦, ERN 00058133-00058134 (ភាសាខ្មែរ)។

## 8. ញ៉ែម នី ហៅ ភា

## ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161),* ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច*(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំមនុស្សខុសច្បាប់ កង្វះខាតការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ឱ្យទៅជាទាសករ ការទទួលរងការឈឺចាប់ធ្ងន់ធ្ងរ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបយ៉ាងអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល និងមនុស្សឃាត និងការសម្លាប់ជនជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនកម្រិត ត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីនេះភេទស្រី ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៥៥ និងមានអាយុប្រហែល ២០ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[175]។ ក្នុងឆ្នាំ១៩៧៣ សាក្សីនេះបានចូលបដិវត្តនៅស្រុកគរ ដោយបម្រើការជាអ្នកនាំសារឱ្យតាបួន ជាមេស្រុកព្រៃឈរ[176]។ គាត់បានក្លាយជាអ្នកនាំសារម្នាក់ឱ្យកងទ័ពក្នុងកងពលធំ ៣១០ ស្ថិតក្នុងខេត្តកំពង់ចាម ដោយបានជួយចែកចាយម្ហូបអាហារ និងជួយកិច្ចការភស្តុភារហូតដល់ខ្មែរក្រហមបានក្តាប់អំណាច[177]។ ក្នុងឆ្នាំ១៩៧៥ សាក្សីនេះបានធ្វើការក្នុងមន្ទីរពេទ្យអង្គឌួង ដែលដឹកនាំដោយភរិយារបស់ អឿន ជាមេបញ្ជាការកងពលធំ៣១០[178]។ ក្នុងឆ្នាំ១៩៧៦ បន្ទាប់ពី អឿន ត្រូវបានគេចាប់ខ្លួន សាក្សីនេះក៏ត្រូវបានគេចាប់ខ្លួនផងដែរ។ គាត់ត្រូវបានគេបញ្ជូនទៅមន្ទីរ ស-២១ ហើយបន្ទាប់មកទៅព្រៃស ដែលជាទីកន្លែងដែលគាត់នៅទីនោះរហូតដល់ការចូលលុកលុយរបស់ វៀតណាម[179]។

## តួនាទីរបស់ជនជាប់ចោទ

3. សាក្សីនេះផ្តល់ភស្តុតាងថា **ឌុច** បានបញ្ជាអ្នកក្រោមបង្គាប់របស់គាត់ឱ្យសម្លាប់ប្រជាជននៅភ្នំក្រវាញ ក្នុងឆ្នាំ១៩៧៩ ដោយមូលហេតុលួចអង្ករ[180]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

4. សាក្សីនេះផ្តល់ភស្តុតាងថា មេបញ្ជាការកងពលធំ៣១០ គឺ អឿន ដែលក្រោយមកត្រូវបានគេចាប់ខ្លួន[181]។ បន្ទាប់ពីការចាប់ខ្លួនរបស់គាត់មក ក៏មានការជួបប្រជុំនៅក្នុងកងពលធំនោះ ហើយគេបានប្រាប់ថា អឿន គឺជាជនក្បត់[182]។ ក្រោយមក អ្នកទាំងឡាយដែលនៅក្នុងកងពលធំនោះក៏ត្រូវបានគេចាប់ខ្លួនផងដែរ រួមទាំងសាក្សីរូបនេះ ដែលត្រូវបានគេឃុំខ្លួននៅមន្ទីរ ស-២១ ហើយបន្ទាប់មកនៅព្រៃស[183]។ មុនពេលគេបញ្ជូនទៅមន្ទីរ ស-២១ សាក្សីនេះត្រូវបានគេសួរចម្លើយនៅក្នុងផ្ទះមួយជិតមន្ទីរពេទ្យអង្គដួង ដោយត្រូវបានគេវាយ ឆក់ខ្សែភ្លើង និងសួរចម្លើយថាតើគាត់ជា សេអ៊ីអា ឬ[184]។

5. សាក្សីនេះផ្តល់ភស្តុតាងថា បន្ទាប់មកគាត់ក៏ត្រូវបានគេបញ្ជូនទៅទួលស្លែងតាមរថយន្តតូច ដោយត្រូវបានគេចងមុខ ហើយឃុំនៅទីនោះអស់រយៈពេលបីថ្ងៃមុនពេលដែលគាត់ត្រូវបានគេបញ្ជូនទៅព្រៃស[185]។

6. ព្រៃស ត្រូវបានគេចែកជាពីរអង្គភាព គឺ អង្គភាព១៤ និងអង្គភាព១៧[186]។ អង្គភាព១៤ សម្រាប់អ្នកទោសធ្ងន់ និងអង្គភាព១៧ សម្រាប់អ្នកទោសស្រាល ហើយក្រុមនេះទទួលបានរបបអាហារគ្រប់គ្រាន់ និងការងារស្រាលៗ[187]។ សាក្សីនេះបាននិយាយថា រូបថតរបស់គាត់ត្រូវបានគេដាក់តាំងនៅ ទួលស្លែង[188]។

## រចនាសម្ព័ន្ធសិទ្ធិអំណាច

7. ប្រធាននៅព្រៃសមានឈ្មោះ ផល[189]។ ប្រធានមន្ទីរពេទ្យអង្គឌួងគឺជាភរិយារបស់ អឿន ដែលជាមេបញ្ជាការ កងពលធំ៣១០[190]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

8. សាក្សីនេះផ្តល់ភស្តុតាងថា គាត់ត្រូវបានគេចាប់ខ្លួន និងសួរចម្លើយនៅផ្ទះមួយជិតមន្ទីរពេទ្យអង្គឌួងអស់រយៈពេលបីថ្ងៃ។ បន្ទាប់មកគាត់ក៏ត្រូវបានគេឃុំខ្លួននៅមន្ទីរ ស-២១ អស់រយៈពេលបីថ្ងៃទៀត ហើយក្រោយមកត្រូវបានគេបញ្ជូនទៅព្រៃស ដែលជាទីកន្លែងដែលគាត់នៅទីនោះរហូតដល់វៀតណាមបានចូលមកដល់[191]។

## ការធ្វើឱ្យទៅជាទាសករ ការបង្ខការឃើចាប់ខ្លួនខុសច្បាប់ដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

9. សាក្សីនេះផ្តល់ភស្តុតាងថា នៅពេលដែលគាត់ត្រូវបានគេចាប់ខ្លួន ហើយឃុំខ្លួននៅក្នុងផ្ទះជិតមន្ទីរពេទ្យអង្គខ្លួង គាត់ត្រូវបានគេវាយ និងឆក់ខ្សែភ្លើង ហើយត្រូវបានគេផ្តល់អាហារឱ្យតិចតួច[192]។

10. សាក្សីនេះផ្តល់ភស្តុតាងថា គាត់ត្រូវបានគេប្រាប់ថា ប្រសិនបើគាត់ប្រព្រឹត្តកំហុសនៅព្រៃស គាត់នឹងត្រូវបានគេបញ្ជូនទៅមន្ទីរ ស-២១ ហើយនឹងត្រូវស្លាប់[193]។ សាក្សីនេះផ្តល់ភស្តុតាងថា នៅព្រៃស ប្រសិនបើអ្នកទោសមិនអាចបញ្ចប់ផែនការការងារបានទេ ពួកគេនឹងមិនត្រូវបានទទួលរបបអាហារឡើយ ហើយនឹងត្រូវបានគេវាយថែមទៀត[194]។ គាត់បានឃើញអ្នកទោសខ្លះត្រូវបានគេចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១[195]។

## ការសួរចម្លើយ

11. សាក្សីនេះផ្តល់ភស្តុតាងថា គាត់ត្រូវបានគេសួរចម្លើយនៅផ្ទះមួយជិតមន្ទីរពេទ្យអង្គខ្លួងអស់រយៈពេលជិតបីថ្ងៃ[196]។ គាត់ត្រូវបានគេវាយ ឆក់ខ្សែភ្លើង និងសួរចម្លើយថាតើគាត់ជា សេអ៊ីអា ឬ[197]។

## ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

12. សាក្សីនេះផ្តល់ភស្តុតាងថា គាត់ត្រូវបានគេវាយ ឆក់ខ្សែភ្លើង និងត្រូវបានគេផ្តល់អាហារឱ្យតិចតួច នៅពេលដែលគាត់ជាប់ឃុំក្នុងផ្ទះមួយជិតមន្ទីរពេទ្យអង្គខ្លួង[198]។ នៅទួលស្លែង គាត់បានឮសម្រែកអ្នកទោសដែលកំពុងត្រូវបានគេសួរចម្លើយ[199]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

13. សាក្សីនេះផ្តល់ភស្តុតាងថា **ឌុច** បានបញ្ជាអ្នកក្រោមបង្គាប់របស់គាត់ឱ្យសម្លាប់ប្រជាជននៅភ្នំក្រវាញក្នុងឆ្នាំ១៩៧៩ ដោយមូលហេតុលួចអង្ករ[200]។

## សក្ខីកម្មមុនៗ

14. សាក្សីនេះបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់ ញ៉ែម នី ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៣, D59, ERN 00056520-00056575 (ភាសាខ្មែរ)។

## ឯកសារពាក់ព័ន្ធដទៃទៀត

15. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយនៅក្នុងចម្លើយរបស់សាក្សី។

## 9. នឹម គឹមស្រ៊ាង

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីរូបនេះផ្តល់ភស្តុតាងអំពីគោលនយោបាយ និងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ចំពោះមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161)*, ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច*(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំមនុស្សខុសច្បាប់ កង្វះខាតការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ឱ្យទៅជាទាសករ ការទទួលរងការឈឺចាប់ធ្ងន់ធ្ងរ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបយ៉ាងអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល និងមនុស្សឃាត និងការសម្លាប់ជនជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងឱ្យទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនកម្រិតត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីនេះមានអាយុប្រហែល ២២ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភេទស្រី ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៥៣។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីនេះគឺជាទាហានក្នុងកងពលធំ១២ (កងពលធំ ទី១២ ហើយក្រោយមកក្លាយជាកងពលធំ៧០៣) កងវរសេនាតូចទី១១៦ នៃកងទ័ពកម្ពុជា ប្រជាធិបតេយ្យ។ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីនេះត្រូវបានគេបញ្ជូនឱ្យទៅរៀនថតរូប។ បន្ទាប់ពីរៀនថតរូបហើយ សាក្សីនេះត្រូវបានគេប្រគល់ការងារជាអ្នកថតរូបអ្នកទោសដែលចូលមក មណ្ឌលឃុំឃាំងទួលស្លែង (មន្ទីរ ស-២១)។ សាក្សីនេះបានធ្វើការជាអ្នកថតរូបនៅមន្ទីរ ស-២១ រហូតដល់របបកម្ពុជាប្រជាធិបតេយ្យបានដួលរលំនៅក្នុងខែមករា ឆ្នាំ១៩៧៩[201]។ បន្ទាប់ពីរត់ភៀសខ្លួន ពីទីក្រុងភ្នំពេញក្នុង

ឆ្នាំ១៩៧៩ គាត់ និងអ្នកថតរូបខ្លះទៀតបានទៅរស់នៅជាមួយ **ឌុច** នៅភ្នំបាក់ ក្នុងខេត្ត ពោធិសាត់ជិតព្រំដែនថៃ[202]។

## វចនាសម្ព័ន្ធ និងគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ

3. សាក្សីនេះផ្តល់ភស្តុតាងថា តា ណាត គឺជាប្រធានកងពលធំទី១២ នៃកងទ័ពកម្ពុជាប្រជាធិបតេយ្យ[203]។

## តួនាទីរបស់ជនជាប់ចោទ

4. សាក្សីនេះផ្តល់ភស្តុតាងថា **ឌុច** គឺជាប្រធានមន្ទីរ ស-២១[204] និងគ្រប់គ្រងក្រុមអ្នកថតរូបដោយផ្ទាល់ដែលគាត់ជាប្រធានក្រុម[205]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

5. សាក្សីនេះផ្តល់ភស្តុតាងថា បុគ្គលិកនៅមន្ទីរ ស-២១ ត្រូវបានគេបែងចែកជាបួនផ្នែក គឺ អង្គភាពសួរចម្លើយ អង្គភាពការពារ អង្គភាពសេដ្ឋកិច្ច និងអង្គភាពកសិកម្ម។ កន្លែងស្នាក់នៅរបស់សាក្សីនេះ មានចម្ងាយ ៧០ម ពីផ្ទះរបស់ **ឌុច**[206]។ នៅពេលមានអ្នកទោសថ្មីមកដល់ សាក្សីនេះត្រូវបានគេទាក់ទងតាមទូរស័ព្ទ។ បន្ទាប់មក គាត់ទៅកន្លែងថតរូប ដែលស្ថិតនៅអគារមួយខាងក្នុងច្រកចូលបន្ទិចនៃមន្ទីរ ស-២១ ហើយគាត់ថតរូបអ្នកទោសដែលទើបមកដល់ម្នាក់ៗចំនួនបីប៉ុស្តិ៍។ បន្ទាប់ពីថតរូបរួច សាក្សីនេះត្រូវផ្តិតរូបនៅផ្ទះរបស់គាត់។ អ្នកទោសនីមួយៗត្រូវបានគេដាក់លេខសំគាល់ ដែលត្រូវបានគេកត់ត្រាជាមួយនឹងឈ្មោះ និងកាលបរិច្ឆេទនៃការចាប់ខ្លួនអ្នកទោសនោះ។ គេដាក់លេខសំគាល់នោះជាការប្រុងប្រយ័ត្ន ដើម្បីតាមដានអ្នកទោសក្នុងករណីដែលរូបថតរបស់អ្នកទោសខូច[207]។ សាក្សីនេះបានបញ្ជាក់ថា អ្នកទោសភាគច្រើនដែលគាត់បានថតរូបនោះ ត្រូវបានគេបញ្ជូនឲ្យទៅធ្វើស្រែនៅព្រៃស[208]។

## វចនាសម្ព័ន្ធសិទ្ធិអំណាច

6. សាក្សីនេះផ្តល់ភស្តុតាងថា **ឌុច** គឺជាប្រធានមន្ទីរ ស-២១ និង ហ៊ី គឺជាអនុប្រធាន[209]។ សាក្សីនេះបានផ្តល់រូបថតដែលបានផ្តិតរួចទៅឲ្យ ធី[210]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

7. សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានឃើញគេនាំយកទាហានវៀតណាមដែលមានចំនួនពី ២០ ទៅ ៣០នាក់ទៅមន្ទីរ ស-២១ ចំនួនបីករណី សរុបមានអ្នកទោសវៀតណាមចំនួន ១០០នាក់។ ជនបរទេស ផ្សេងទៀត

ដែលសាក្សីនេះបានឃើញគឺអ្នកការសែតបរទេសពីរនាក់ ដែលសាក្សីនេះមិនដឹងច្បាស់អំពី សញ្ជាតិរបស់ពួកគេឡើយ (គាត់គិតថាប្រហែលជាជនជាតិ គុយបា ឬរុស្ស៊ី)[211]។

**ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត**

8. សាក្សីនេះផ្តល់ភស្តុតាងថា អ្នកទោសខ្លះត្រូវបានគេថតរូបទាំងដៃជាប់ខ្នោះ[212]។

**សក្ខីកម្មមុនៗ**

9. សាក្សីនេះបានផ្តល់ចម្លើយមុនពីរតាមការដឹងរបស់សហព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់ នឹម គឹមស្រ៊ាង ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៧, ERN 00162729-00162741, ឯកសារ D22/11 (ភាសាអង់គ្លេស)។

(2) បទសម្ភាសន៍របស់ នឹម គឹមស្រ៊ាង ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨, ERN 00164439-00164442, ឯកសារ D51/1 (ភាសាអង់គ្លេស)។

**ឯកសារពាក់ព័ន្ធដទៃទៀត**

10. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយនៅក្នុងចម្លើយរបស់សាក្សី។

## 10. ប៉ែន ហេង

## ចរិតលក្ខណ: និងខ្លឹមសារនៃភស្តុតាង

1. សាក្សីរូបនេះផ្តល់ភស្តុតាងអំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* និងគោលនយោបាយព្រមទាំងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ចំពោះមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161)*, ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច*(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំមនុស្សខុសច្បាប់ កង្វះខាតការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ឱ្យទៅជាទាសករ ការទទួលរងការឈឺចាប់ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបយ៉ាងអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់ផ្តាច់ពូជ និងមនុស្សឃាត និងការសម្លាប់ ជនជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ ដោយ សាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនកម្រិតត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីនេះមានអាយុប្រហែល ១៨ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភេទប្រុស ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៥៧។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីនេះប្រកបរបរធ្វើស្រែ និងចិញ្ចឹមគោ។ ក្នុងឆ្នាំ១៩៧៣ គាត់បានស្ម័គ្រចិត្តចូលធ្វើទាហានក្នុងកងទ័ពឃុំ។ បន្ទាប់មកគាត់ត្រូវបានគេបញ្ជូនទៅកងទ័ពស្រុកក្នុងកងវរសេនាតូចទី១៣០ មានតួនាទីជាប្រធានក្រុម។ បន្ទាប់ពីការដួលរលំទីក្រុងភ្នំពេញ ក្នុងខែកក្កដា ឆ្នាំ១៩៧៥ គាត់ត្រូវបានគេបញ្ជូនទៅយាមនៅមន្ទីរ ស-២១។ គាត់គឺជាប្រធានក្រុមដែល មានគ្នាបីនាក់ ហើយបន្ទាប់មកបានក្លាយជាអនុប្រធានកង។ គាត់ត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យ វិកលចរិត នៅតាខ្មៅរយៈពេលមួយខែ បន្ទាប់មកទៅគុកដាំផេង នៅខាងជើងមន្ទីរពេទ្យមុន្នីវង្សរយៈ ពេលបីខែ។ នៅដើមឆ្នាំ១៩៧៦ អង្គភាពទាំងមូលត្រូវបានគេបញ្ជូនទៅមន្ទីរ ស-២១[213]។ ក្នុងអំឡុងពេលដែលគាត់ជាធ្វើជាអ្នកយាម គាត់ត្រូវបានគេបញ្ជូនទៅព្រៃស[214]។

## វចនាសម្ព័ន្ធ និងគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ

3. សាក្សីនេះផ្តល់ភស្តុតាងថា ឌុច បានកោះប្រជុំរៀននយោបាយនៅមន្ទីរ ស-២១[215] ដែលតែងតែមាន វត្តមាន តា ម៉ុក, សុន សេន និង **ខៀវ សំផន** ហើយនិងមានការចូលរួមពី **អៀង សារី** ឃូរ១ម្តង[216]។

## តួនាទីរបស់ជនជាប់ចោទ

4. ជាអ្នកយាមនៅមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងថា **ឌុច** គឺជាប្រធានទូទៅនៅមន្ទីរ ស-២១[217]។ ឌុច បានកោះប្រជុំរៀននយោបាននៅមន្ទីរ ស-២១ និងបានបើកប្រជុំស្តីអំពីវិន័យ[218]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

5. សាក្សីនេះផ្តល់ភស្តុតាងថា គាត់គឺជាអ្នកយាមនៅមន្ទីរ ស-២១ ពីខែកក្កដា ឆ្នាំ១៩៧៥ រហូតដល់របប ខ្មែរក្រហមបានដួលរលំ។ សាក្សីនេះផ្តល់ភស្តុតាងថា មន្ទីរពេទ្យមុន្នីវង្សត្រូវបានគេប្រើប្រាស់ជាគុក បណ្តោះអាសន្ន ក្នុងខណៈដែលពួកគេកំពុងបំបែកបន្ទប់រៀននៅមន្ទីរ ស-២១ ធ្វើជាបន្ទប់ឃុំឃាំង។ មានអ្នកជាប់ឃុំជាច្រើនត្រូវបានគេឃុំឃាំងនៅមន្ទីរពេទ្យមុន្នីវង្ស ក្នុងខណៈដែលការសាងសង់មន្ទីរ ស-២១ កំពុងដំណើរការ ដូច្នេះមន្ទីរឃុំឃាំងមួយទៀតត្រូវបានគេបង្កើតឡើងនៅមន្ទីរពេទ្យវិកលចរិតនៅ តាខ្មៅ[219]។ នៅពេលដែលគាត់បានចូលដល់មន្ទីរ ស-២១ គាត់ត្រូវបានគេចាត់ឲ្យយាមនៅផ្ទះខាងលិច ទួលស្លែង ដែលនៅពេលនោះមានអ្នកជាប់ឃុំជាច្រើនក្នុងបន្ទប់ឃុំខ្លួនដាច់ដោយឡែក[220]។ អ្នកជាប់ឃុំជា ច្រើនមកពីគុកដាំផេងត្រូវបានគេផ្ទេរទៅទួលស្លែងនៅពេលដែលបន្ទប់ឃុំខ្លួនបានសង់រួចរាល់។ កន្លែង ប្រហារជីវិតស្ថិតនៅចម្ងាយ ៧០-៨០ម ពីផ្ទះដែលអ្នកជាប់ឃុំឃាំងត្រូវបានគេឃុំខ្លួន[221]។

## វចនាសម្ព័ន្ធសិទ្ធិអំណាច

6. សាក្សីនេះផ្តល់ភស្តុតាងថា ដំបូង តាណាត គឺជាប្រធានមន្ទីរ ស-២១ បន្ទាប់មក ឌុច បានក្លាយជាប្រធាន ទូទៅ។ អនុប្រធានគឺជា ហ៊ រ ដែលខ្វាក់ភ្នែកម្ខាងជាភ្នែកស្រឡេវ ហើយសមាជិកគឺ ហ៊ុយ មានរាងខ្ពស់ សម្បុរខ្មៅ[222]។ ចាន់ ដែលមានជម្ងឺសើស្បែកពេញខ្លួន ក៏ស្ថិតនៅក្រោមបញ្ជារបស់ ឌុច ផងដែរ[223]។ មេផ្ទាល់របស់សាក្សីនេះគឺ ប៉េង ដែលជាប្រធានកងអនុសេនាតូចរបស់សាក្សីនេះ[224]។ យោងតាមសាក្សី បានឲ្យដឹងថា ចាន់ ជាប្រធានអង្គភាពសួរចម្លើយ ដោយមាន សួន ជាអនុប្រធាន[225]។ សាក្សីនេះនឹង បង្ហាញភស្តុតាងផងដែរថា សេង, ទិត ដែលមានសក់រួញ សម្បុរខ្មៅ និង ឈិន តេង ជាអ្នកសួរ ចម្លើយ[226]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្ដីដោយយុត្តិធម៌

7. សាក្សីនេះផ្ដល់ភស្តុតាងថា អ្នកទោសនៅមន្ទីរពេទ្យមុន្នីវង្សគឺជាមេបញ្ជាការកងពលធំ និងកងវរសេនាធំ។ មានមនុស្សជាច្រើនត្រូវបានគេឃុំខ្លួននៅទីនោះ ក្នុងខណៈដែលការសាងសង់មន្ទីរ ស-២១ កំពុងដំណើរការ ដូច្នេះ មន្ទីរឃុំឃាំងមួយទៀតត្រូវបានគេបង្កើតឡើងនៅមន្ទីរពេទ្យវិកលចរិតចាស់នៅតាខ្មៅ[227]។ អ្នកជាប់ឃុំឃាំងភាគច្រើន ដែលត្រូវបានគេឃុំខ្លួននៅក្នុងផ្ទះតូចៗមុនពេលដែលសាលាទួលស្លែងក្លាយជាគុក គឺជាកម្មាភិបាលជាន់ខ្ពស់ ដែលត្រូវបានគេចាប់ខ្លួននៅតាមស្រុក តំបន់ និងភូមិភាគនានា។ សាក្សីនេះផ្ដល់ភស្តុតាងថា តាកាត ដែលជាលេខាស្រុក១៨ ត្រូវបានគេឃុំខ្លួន ដោយដាក់ខ្នោះជើង ហើយថាសាក្សីនេះបានយាមគាត់ដោយផ្ទាល់[228]។ សាក្សីនេះផ្ដល់ភស្តុតាងថា អ្នកយាមត្រូវបានគេចាប់ខ្លួននៅពេលដែលពួកគេមានកំហុស។ ឈិន តេង គឺជាអ្នកសួរចម្លើយម្នាក់ ដែលត្រូវបានគេចាប់ខ្លួន ហើយឃុំខ្លួននៅមន្ទីរ ស-២១[229]។ សាក្សីនេះផ្ដល់ភស្តុតាងថា អ្នកជាប់ឃុំឃាំង នៅដំរំផេង ត្រូវបានគេបញ្ជូនទៅមន្ទីរ ស-២១ នៅពេលដែលបន្ទប់ឃុំខ្លួនត្រូវបានសាងសង់រួច[230]។ គាត់បានឃើញចាន់ ចក្រី ត្រូវបានគេចាប់ខ្លួននៅក្នុងគុកដំរំផេង[231]។

8. សាក្សីនេះផ្ដល់ភស្តុតាងថា នៅព្រៃស មានអង្គភាពនារីពីរ និងអង្គភាពយុវជនបី[232]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

9. សាក្សីនេះផ្ដល់ភស្តុតាងថា នៅព្រៃស ពួកគេធ្វើការពីម៉ោង៤ រហូតដល់ម៉ោង១១ ទៅម៉ោង១២យប់ ហើយមិនបានទទួលអាហារគ្រប់គ្រាន់ទេ[233]។

## ការសួរចម្លើយ

10. សាក្សីនេះផ្ដល់ភស្តុតាងថាអ្នកសួរចម្លើយស្ថិតនៅក្នុងក្រុម តាចាន់។ សេង, ទិត ដែលមានសក់រួញសម្បុរខ្មៅ និង ឈិន តេង ជាអ្នកសួរចម្លើយ។ អ្នកជាប់ឃុំឃាំងត្រូវបានគេសួរចម្លើយនៅខាងក្រៅអគារ និងបន្ទាប់មកត្រូវបានគេនាំយកមកកន្លែងរបស់ពួកគេវិញ[234]។

## ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

11. សាក្សីនេះផ្ដល់ភស្តុតាងថា គាត់បានឃើញស្នាមវាយ និងឈាមហូរចេញពីខ្នងអ្នកទោសបន្ទាប់ពីត្រូវបានគេសួរចម្លើយរួច[235]។ ជួនកាលគាត់បានឃើញគេសែងអ្នកជាប់ឃុំឃាំងសន្លប់ទៅកាន់កន្លែងអ្នក

យាមវិញ[236]។ សាក្សីនេះផ្តល់ភស្តុតាងថា ជួនកាលគាត់បានឮសម្រែកនៅពេលយប់នៅគុកដាំផេង[237]។ សាក្សីនេះផ្តល់ភស្តុតាងថា នៅព្រៃស ពួកគេបានវាយ និងទាត់ធាក់អ្នកទោសដែលឈឺខ្លាំងមិនអាចទៅធ្វើការទាន់ម៉ោង[238]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

12. សាក្សីនេះផ្តល់ភស្តុតាងថា នៅពេលដែលគេសួរចម្លើយចប់សព្វគ្រប់ រយៈពេលមួយខែ ឬពីរខែ អ្នកជាប់ឃុំឃាំងត្រូវបានគេយកទៅសម្លាប់។ ពួកគេត្រូវបានគេប្រហារជីវិតនៅពេលយប់[239]។ អ្នកនាំសារម្នាក់យកឈ្មោះអ្នកជាប់ឃុំឃាំងទៅឱ្យអ្នកយាម ហើយអ្នកយាមក៏បាននាំយកអ្នកជាប់ឃុំឃាំងនោះចេញពីបន្ទប់ឃុំខ្លួនដោយចងដៃទៅក្រោយខ្នង និងចងមុខដោយក្រមាយកទៅកន្លែងប្រហារជីវិតដែលស្ថិតនៅខាងក្រោយមន្ទីរ ស-២១។ មានពេជ្ឈឃាដចំនួនបួននាក់ ម្នាក់ក្នុងចំណោមអ្នកទាំងនោះគឺ ប៉េង។ អ្នកយាមបានឱ្យអ្នកទោសអង្គុយ ឬឈរនៅមាត់រណ្តៅ។ ពួកគេយកទុយោទឹកវាយគល់កអ្នកទោស ហើយធាក់ទម្លាក់រណ្តៅ។ សាក្សីនេះសន្និដ្ឋានថា មានសាកសព ៤០នាក់ ក្នុងរណ្តៅនីមួយៗ។ មិនមានការប្រហារជីវិតរាល់ថ្ងៃទេ ជួនកាលមានការប្រហារជីវិតម្តងក្នុងមួយខែ។ ក្នុងមួយលើកៗ ពួកគេត្រូវរង់ចាំមានចំនួនអ្នកទោសច្រើន[240]។ សាក្សីនេះផ្តល់ភស្តុតាងថា សូម្បីតែសមាជិកនៃអង្គភាពការពារ ៣ក៏មិនត្រូវបានគេប្រាប់ឱ្យបានច្បាស់ថា ការប្រហាជីវិតកំពុងតែត្រូវបាន គេអនុវត្តទៅលើអ្នកទោសដែរ ទោះបីជាវាច្បាស់ណាស់ដែរថា នៅពេលសួរចម្លើយចប់សព្វគ្រប់ អ្នកទោសត្រូវបានគេប្រហារជីវិតជាក់ស្តែងសាក្សីនេះបានឮសម្លេងនៃការប្រហារជីវិតពីកន្លែងស្នាក់នៅរបស់គាត់[241]។ សាក្សីនេះបានបញ្ជាក់ថា អ្នកជាប់ឃុំឃាំងម្នាក់បានលួចយកកាំភ្លើងខ្លី ហើយបានបាញ់សម្លាប់ខ្លួនឯង[242]។

## សក្ខីកម្មមុនៗ

13. សាក្សីនេះបានផ្តល់ចម្លើយមុនពីរតាមការដឹងរបស់សហព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់ ប៉ែន ហេង ដោយ ក.ស.ច.ស ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧, D28/6, ERN 00163692-98 (ភាសាអង់គ្លេស)។

(2) បទសម្ភាសន៍របស់ ប៉ែន ហេង ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, 19.131, ERN 00008363-00008458 (ភាសាខ្មែរ); អត្ថបទសង្ខេប ជាភាសាអង់គ្លេស (ERN 00182994-00182996)។

## ឯកសារពាក់ព័ន្ធដទៃទៀត

14. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយនៅក្នុងចម្លើយរបស់សាក្សី។

## 11. ព្រំ ឈឿន

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ **ឌុច** *(55-59, 90-99, 107-111 & 153 [ថ្មី]-161),* ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច *(20-25)* នៃមន្ទីរ ស-២១ ចំនួន និងប្រភេទនៃអ្នកជាប់ឃុំឃាំង ការដាក់គុក ការឃុំឃាំមនុស្សខុសច្បាប់ កង្វះខាតការជំនុំជម្រះទោស ប្រកបដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ប្រជាជនឱ្យទៅជាទាសករ ការទទួលរង ការឈឺចាប់ធ្ងន់ធ្ងរ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* និងការសម្លាប់ផ្តាច់ពូជ និងមនុស្សឃាត និងការសម្លាប់ដោយចេតនាទៅលើជនជាប់ឃុំឃាំង *(107-128, 138, 139-140, 151 & 152 [ថ្មី])* ដែលបាន កើតឡើងនៅមន្ទីរស-២១។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿង ឱ្យទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះមិនមែនមានត្រឹមតែអង្គហេតុ ដូចដែលបានរៀប រាប់ដូចខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីនេះមានអាយុប្រហែល ៥០ឆ្នាំ មកពីខេត្តកំពង់ស្ពឺ។ គាត់បានបួសជាព្រះសង្ឃក្នុងដើមទសវត្សរ៍ ៧០។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច គាត់បានទៅភ្នំពេញជាមួយបងប្អូនជីដូនមួយរបស់គាត់ ដែលជាទីកន្លែងដែលគាត់បានបង្រៀនអក្ខរកម្មនៅបឹងទំពុន ធ្វើការក្នុងកងកុមារ។ គាត់ត្រូវបានគេផ្ទេរ ទៅយាមកាមនៅមន្ទីរសន្តិសុខ ស-២១ និងជួនកាលធ្វើស្រែនៅបឹងឆ្នោត។ សាក្សីនេះបាន ធ្វើការនៅមន្ទីរ ស-២១ រហូតដល់របបកម្ពុជាប្រជាធិបតេយ្យដួលរលំ ដោយគាត់បានភៀសខ្លួនទៅប៉ែក ខាងលិចប្រទេស កម្ពុជា[243]។

### តួនាទីរបស់ជនជាប់ចោទ

3. សាក្សីនេះផ្តល់ភស្តុតាងថា **ឌុច** គឺជាប្រធានមន្ទីរ ស-២១ ដោយត្រួតពិនិត្យមើលប្រតិបត្តិការនៅទីនោះ។ សាក្សីនេះជារឿយៗបានបើកទ្វារបងមន្ទីរ ស-២១ ឱ្យ **ឌុច** ដើម្បីឱ្យគាត់ដើរឡើងរថយន្តរបស់គាត់[244]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

4. សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានធ្វើការនៅមន្ទីរ ស-២១ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៩។ សាក្សីនេះផ្តល់ភស្តុតាងថា អ្នកធ្វើការនៅមន្ទីរ ស-២១ តែងតែបាត់ខ្លួន ដោយលើក ឧទាហរណ៍មួយអំពីកម្មាភិបាលម្នាក់ដែលបានប្រព្រឹត្តអំពើចាប់រំលោភ ហើយបន្ទាប់មកក៏បានបាត់ខ្លួន រហូត[245]។ មនុស្សជាច្រើនត្រូវបានគេនាំយកចេញតាមច្រកចូលខាងក្នុង[246]។

## រចនាសម្ព័ន្ធសិទ្ធិអំណាច

5. សាក្សីនេះផ្តល់ភស្តុតាងថា ឌុច បានត្រួតពិនិត្យប្រតិបត្តិការនៅមន្ទីរ ស-២១ ហើយថា ប៉ុន ទទួលបន្ទុកផ្នែកការពារ[247]។ សាក្សីនេះក៏នៅចាំបុរសម្នាក់ឈ្មោះ សើ ដែលបានបើករថយន្ត និងពេទ្យម្នាក់ឈ្មោះ សឿ ដែលបានព្យាបាលមនុស្ស និងសត្វជ្រូក[248]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

6. សាក្សីនេះផ្តល់ភស្តុតាងថា ជួនកាលគាត់បានឃើញអ្នកទោសដែលត្រូវបានគេចងមុខចំនួនពីរ ទៅដប់នាក់ ត្រូវបានគេនាំយកទៅមន្ទីរ ស-២១ ជារៀងរាល់សប្តាហ៍ ឬក៏ជារៀងរាល់មួយខែ ឬពីរខែ[249]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

7. សាក្សីនេះផ្តល់ភស្តុតាងថា អ្នកដែលត្រូវបានគេនាំខ្លួនយកទៅមន្ទីរ ស-២១ តាមរថយន្តធំៗ ត្រូវបានគេដាក់ខ្នោះដៃ និងចងមុខ[250]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

8. សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានដឹងថាមានការប្រហារជីវិតនៅប៉ែកខាងលិចខាងក្រោយមន្ទីរ ស-២១[251]។

## សក្ខីកម្មមុនៗ

9. សាក្សីនេះបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់ ព្រុំ ឈឿន ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០៥, ERN 00060319-00060382 (ភាសាខ្មែរ); អត្ថបទសង្ខេប ជាភាសាអង់គ្លេស (ERN 00060319-00060387)។

## ឯកសារពាក់ព័ន្ធដទៃទៀត

10. មានវត្ថុតាងជាក់លាក់មួយដែលមាននិយាយយោងដល់នៅក្នុងចម្លើយរបស់សាក្សីរូបនេះ :

(1) បញ្ជីទិន្នន័យប្រវត្តិរូបរបស់ ព្រុំ ឈឿន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៦, ERN 00058146-00058147 (ភាសាខ្មែរ)។

## 12. ព្រុំ សុខ

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ចំពោះមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពី ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច*(20-25)* និងការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំមនុស្សខុសច្បាប់ កង្វះខាតការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ទៅលើអ្នកជាប់ឃុំឃាំង *(107-128, 138, 139-140, 151 )*។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីនេះមានអាយុប្រហែល ១៤ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភេទប្រុស ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៦១។ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីនេះត្រូវបានគេប្រមូលផ្តុំ និងបញ្ជូនទៅភ្នំពេញ ដែលជាទីកន្លែងដែលគាត់ធ្វើការជាអ្នកបោសសំអាតរយៈពេលមួយសប្តាហ៍ បន្ទាប់មក គាត់ត្រូវបានគេដាក់ក្នុងអង្គភាពកុមារ ដែលការងាររបស់គាត់គឺលើកទំនប់ និងជីកប្រឡាយនៅព្រៃស។ ពីរខែក្រោយ សាក្សីនេះបានទៅបឹងទំពុន ដែលនៅទីនោះគាត់ធ្វើការកាត់ស្មៅ និងដើមឈើ។ ចុងឆ្នាំ១៩៧៦ គាត់ត្រូវបានគេជ្រើសរើសឱ្យទៅរៀនពេទ្យនៅ ប៉េហ្សី ជិតផ្សារថ្មី។ ចុងឆ្នាំ១៩៧៧ សាក្សីនេះត្រូវបានគេបញ្ជូនទៅតាខ្មៅ ដែលនៅទីនោះគាត់បានដឹកបន្លែទៅកាន់មន្ទីរពេទ្យប៉េហ្សី។ បន្ទាប់ពីរយៈពេលមួយឆ្នាំក្រោយមក គាត់ក៏ត្រូវបានគេចាត់តាំងឱ្យទៅព្យាបាលជម្ងឺគ្រុនចាញ់នៅមន្ទីរពេទ្យប៉េហ្សី និងធ្វើការជាមួយក្រុមកំចាត់មូស និងដង្កូវទឹក។ មួយខែមុនឆ្នាំ១៩៧៩ សាក្សីនេះត្រូវបានគេបញ្ជូនឱ្យទៅធ្វើការនៅមន្ទីរ ស-២១ ដែលគាត់ស្ថិតនៅទីនោះរហូតដល់របបកម្ពុជាប្រជាធិបតេយ្យដួលរលំ[252]។

### ការបង្កើត រយៈពេល និងប្រតិបត្តិការ

3. ជាពេទ្យម្នាក់នៅមន្ទីរ ស-២១ ដំបូងសាក្សីនេះធ្វើការនៅក្នុងក្រុមពេទ្យខាងក្នុង ប៉ុន្តែក្រោយមកគាត់ក៏ត្រូវបានផ្ទេរទៅក្រុមពេទ្យខាងក្រៅ។ នៅពេលធ្វើការក្នុងក្រុមពេទ្យខាងក្រៅ សាក្សីនេះបានបានដេកនៅក្នុងអគារសាលាទួលស្វាយព្រៃ។ យោងតាមសាក្សីនេះបានឱ្យដឹងថា ឱសថបរទេសដែលសល់ពីរបបមុន និងឱសថដែលផលិតក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ដូចជា B2, B12 និងថ្នាំគីនីន ត្រូវបានគេស្តុក

ទុកនៅក្នុងអគារជិតកន្លែងស្នាក់នៅរបស់ពេទ្យ។ សាក្សីនេះបានធ្វើការនៅមន្ទីរ ស-២១ រហូតដល់របប កម្ពុជាប្រជាធិបតេយ្យដួលរលំក្នុងឆ្នាំ១៩៧៩ ប៉ុន្តែបានចូលមន្ទីរ ស-២១ តែម្តងគត់[253]។

4. ជាសមាជិកនៃអង្គភាពកុមារ សាក្សីនេះបានជីកប្រឡាយ និងលើកទំនប់នៅព្រៃស[254]។ នៅពេលធ្វើការជាមួយក្រុមបង្ការជម្ងឺគ្រុនចាញ់នៅមន្ទីរពេទ្យប៉េហ្សី សាក្សីនេះបានបួមឈាមពីប្រជាជននៅមាត់ស្ទឹងជិតព្រៃស[255]។

## វចនាសម្ព័ន្ធសិទ្ធិអំណាច

5. សាក្សីនេះផ្តល់ភស្តុតាងថា ទ្រី មានមាឌធំ រាងខ្ពស់ ហើយដៃរបស់គាត់មានរោម គឺជាប្រធានអង្គភាពពេទ្យ។ សាក្សីនេះបានធ្វើការជាមួយ ថាន ដែលជាក្មួយរបស់ នួន ជា។ ថានចេះនិយាយភាសាបារាំង ចិន និងអង់គ្លេស បានត្រួតពិនិត្យកាលបរិច្ឆេទផុតកំណត់របស់ឱសថបរទេស ព្រមទាំងធ្វើការជាឆ្មបសម្រាប់កម្មាភិបាលខ្មែរក្រហមមកពីមន្ទីរ ស-២១ និងមូលដ្ឋានផ្សេងៗទៀត។ សាក្សីនេះនៅចាំឈ្មោះសមាជិកខ្លះនៃក្រុមពេទ្យខាងក្នុង រួមមាន ថា, ស្រុ, ស្វ, ធីម និង ដន[256]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

6. ពេលមួយដងនោះដែលសាក្សីនេះបានចូលទៅក្នុងមន្ទីរ ស-២១ គាត់បានឃើញអ្នកទោសជាប់ខ្នោះ[257]។

## សក្ខីកម្មមុនៗ

7. សាក្សីនេះបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់ ព្រុំ សុខ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨, D28/17, ERN 00163828-00163831 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

8. មិនមានឯកសារពាក់ព័ន្ធជាក់លាក់ផ្សេងទៀតដែលមាននិយាយយោងនៅក្នុងចម្លើយរបស់សាក្សីឡើយ។

## 13. សៅ ខេ

## ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ចំពោះមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161),* ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច *(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំមនុស្សខុសច្បាប់ កង្វះខាតការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឲ្យទៅជាទាសករ ការទទួលរងការ ឈឺចាប់ធ្ងន់ធ្ងរ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបយ៉ាងអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល និងមនុស្សឃាត និងការសម្លាប់ជនជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងឲ្យទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមាន ត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. ជាអ្នកស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង សាក្សីមានអាយុ ១៦ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភេទប្រុស ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៥៩។ ក្នុងឆ្នាំ១៩៧៤ សាក្សីនេះបានចូលបម្រើក្នុងកងទ័ពខ្មែរក្រហម ក្នុងតំបន់របស់គាត់។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានក្តាប់អំណាច សាក្សីនេះត្រូវបានគេបញ្ជូនទៅបឹងទំពុនរយៈពេលពីរខែកន្លះ ដើម្បីហ្វឹកហាត់យោធា និងធ្វើស្រែ[258]។ ក្នុងខែកុម្ភៈ ឬខែមីនា ឆ្នាំ១៩៧៦ គាត់ត្រូវបានគេផ្ទេរទៅមន្ទីរសន្តិសុខ ស-២១។ គាត់ធ្វើការនៅមន្ទីរ ស-២១ ជាជាងភ្លើង និងជាអ្នកយាមរហូតដល់របបនេះដួលរលំ។ ក្នុងអំឡុងគាត់ធ្វើការជាមួយខ្មែរក្រហម សាក្សីនេះត្រូវបានគេបញ្ជូនទៅធ្វើការនៅតាខ្មៅចំនួនពីរដង។ លើកទីមួយ គឺនៅពេលដែលគាត់កំពុងធ្វើការនៅបឹងទំពុន ហើយលើកទីពីរនៅពេលដែលធ្វើជាអ្នកយាមនៅមន្ទីរ ស-២១[259]។

## តួនាទីរបស់ជនជាប់ចោទ

3. ជាសន្តិសុខយាមនៅមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានស្គាល់ **ឌុច** ជាប្រធានគុក។ គាត់ដឹងច្បាស់នៅពេលដែលសាក្សីនេះបានឃើញ **ឌុច** "មើលការខុសត្រូវកន្លែងនោះ" ដោយបានមកទីស្នាក់ការ

មន្ទីរ ស-២១[260]។ **ឌុច** បានបង្រៀននយោបាយ និងបានណែនាំអ្នកធ្វើការនៅមន្ទីរ ស-២១[261]។ នៅពេលដែលមានការប្រជុំរៀនសូត្រ គឺមានតែ **ឌុច** ម្នាក់គត់ដែលបានឡើងនិយាយ[262]។ គាត់ធ្លាប់និយាយអំពីគោលនយោបាយកំទេចពួកបរិវារ លន់ ណុល ដោយចោទថាពួកគេជាជនក្បត់[263]។ លើសពីនេះទៀត ប៉េង បានប្រាប់សាក្សីនេះថា **ឌុច** គឺជាអ្នកដែលត្រួតពិនិត្យមន្ទីរ ស-២១ ទាំងមូល[264]។ នៅពេលដែលមានប្រជុំជាមួយ **ឌុច** ពួកគេមិនអាចបដិសេធមិនចូលរួមបានឡើយ[265]។ សាក្សីនេះក៏បានដឹងអំពីការណែនាំឱ្យគាស់សាកសពចេញពីរណ្ដៅចំនួនពីរ នៅជិតតាខ្មៅ ដែលជាបទបញ្ជារបស់ **ឌុច** ថ្នាក់ដឹកនាំនៃមន្ទីរ ស-២១[266]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

4. សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានធ្វើការនៅមន្ទីរ ស-២១ ចាប់ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៩។ សាក្សីនេះបញ្ជាក់ថា មានអគារបីជាន់ចំនួនបួនអគារនៅមន្ទីរ ស-២១ ហើយថា មន្ទីរសន្តិសុខតាខ្មៅក៏ ឌុច ជាអ្នករៀបចំចាត់ចែងដែរ។ មុនពេលមន្ទីរសន្តិសុខតាខ្មៅត្រូវបានផ្លាស់ទៅមន្ទីរ ស-២១ មន្ទីរនេះស្ថិតនៅបរិវេណទួលស្វាយព្រៃ[267]។ អ្នកយាមមន្ទីរ ស-២១ ត្រូវបានគេបែងចែកជាបីក្រុមធំៗ ដែលទទួលបន្ទុកខាងការសួរចម្លើយ ប្រហារជីវិត និងការពារ[268]។ សាក្សីនេះក៏បានចង្អុលប្រាប់អំពីកន្លែងមួយចំនួនដែលខ្លួនបានស្គាល់នៅលើផែនទីរូបថតមន្ទីរ ស-២១[269]។

## វចនាសម្ព័ន្ធសិទ្ធិអំណាច

5. សាក្សីនេះផ្តល់ភស្តុតាងថា **ឌុច** គឺជាប្រធានមន្ទីរ ស-២១ ហើយថា ចាន់ នៅក្រោម **ឌុច**។ ចាន់ បានមកចូលរួមប្រជុំពីរដងដើម្បីផ្តល់ការណែនាំ[270]។ សាក្សីនេះផ្តល់ភស្តុតាងថា តាប៉េង ទទួលបន្ទុកអង្គភាពការពារ។ សាក្សីនៅចាំរាងរៅមុខមាត់របស់មនុស្សជាច្រើន ដែលទទួលបន្ទុកកិច្ចការនៅមន្ទីរសន្តិសុខនេះ ទោះបីជាគាត់មិនបានចាំឈ្មោះយ៉ាងណាក៏ដោយ[271]។ អង្គភាពបឹងទំពុន ក៏ស្ថិតក្រោមការបញ្ជារបស់ **ឌុច** ដែរ[272]។ សាក្សីនេះបានបញ្ជាក់ថា គាត់បានដឹងថាបឹងទំពុនជាចំណុះរបស់មន្ទីរ ស-២១ ពីព្រោះគាត់បានឃើញ ប៉េង មកត្រួតពិនិត្យ[273]។ ទោះបីជា ឌុច មិនដែលបានមកយ៉ាងណាក៏ដោយ ក៏ ចាន់ បានមកទីនេះពីរ ឬបីដង[274]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

6. សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានឃើញប្រជាជនថៃ វៀតណាម ព្រមទាំងកម្មាភិបាលខ្មែរក្រហម និង "ប្រជាជន១៧មេសា" ត្រូវបានគេដាក់ឃុំឃាំងនៅមន្ទីរ ស-២១ និងនៅតាខ្មៅ។ ជនជាតិវៀតណាមដែលត្រូវបានគេចាប់ជាច្រើនស្លៀកពាក់ឯកសណ្ឋាន និងពាក់មួកកងទ័ព[275]។ អ្នកទោសទាំងនោះក៏រួមមានជនជាតិអាមេរិកចំនួន១២នាក់ផងដែរ ដែលពួកគេពាក់អាវធំ[276]។ រៀងរាល់ថ្ងៃ រថយន្តធំៗបានដឹកអ្នកទោសចូល និងចេញពីមន្ទីរ ស-២១។ ជនបរទេសត្រូវបានគេឃុំដាច់ដោយឡែកពីប្រជាជនទូទៅ[277]។ អ្នកយាមត្រូវបានគេដាក់វិន័យប្រសិនបើគេឃើញងោកពេលកំពុងបំពេញភារកិច្ច[278]។ ប្រសិនបើអ្នកយាមណាម្នាក់ដេក អ្នកនោះត្រូវបានគេណែនាំ ហើយបន្ទាប់មកត្រូវបានគេបញ្ជូនទៅកន្លែងឃុំខ្លួន តែម្តង[279]។ អ្នកធ្វើការនៅបឹងទំពុន ដែលមិនអាចទ្រាំទ្រការងារធ្វើស្រែបានក៏ត្រូវបានគេបញ្ជូនទៅឃុំខ្លួន ផងដែរនៅមន្ទីរ ស-២១[280]។ សាក្សីនេះផ្តល់ភស្តុតាងថា នៅពេលដែលចំនួនអ្នកទោសមានច្រើនលើសលប់ពេកនោះ អ្នកទោសដែលត្រូវបានគេឃុំខ្លួនរយៈពេលយ៉ាងយូរបំផុតមួយសប្តាហ៍ត្រូវបានគេយក ចេញដើម្បីទុកកន្លែងទំនេរសម្រាប់អ្នកទោសមកក្រោយ[281]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

7. សាក្សីនេះផ្តល់ភស្តុតាងថា នៅមន្ទីរ ស-២១ អ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងរួម ត្រូវបានគេដាក់ខ្នោះជាក្រុមដោយភ្ជាប់ទៅនឹងរនុកដែក ហើយថា អ្នកដែលត្រូវបានគេឃុំខ្លួនដាច់ដោយឡែក គឺជាមន្ត្រីជាន់ខ្ពស់[282]។ អ្នកទោសខ្លះបានធ្វើអត្តឃាត ហើយអ្នកយាមដែលមើលការខុសត្រូវពួកគេត្រូវទទួល ទណ្ឌកម្ម[283]។ សាក្សីនេះក៏បានផ្តល់ភស្តុតាងថា នៅពេលធ្វើស្រែនៅបឹងទំពុន គាត់បានទៅបោសសំអាតផ្ទះមួយដែលគាត់គិតថាផ្ទះនោះត្រូវបានគេប្រើជាកន្លែងសម្រាប់ឃុំខ្លួនមនុស្ស ពីព្រោះគាត់បានឃើញ ខ្នោះជើងនៅទីនោះ[284]។

## ការសួរចម្លើយ

8. សាក្សីនេះផ្តល់ភស្តុតាងថា ការសួរចម្លើយ [អ្នកទោសម្នាក់] ត្រូវការពេលវេលាមួយថ្ងៃ ទៅដប់ថ្ងៃ គឺសួរទាំងថ្ងៃទាំងយប់។ អ្នកទោសថៃចំនួនដប់នាក់ ត្រូវបានគេយកទៅសួរចម្លើយនៅកន្លែងខុសៗគ្នា[285]។ នៅពេលដែលគេយកអ្នកទាំងនោះត្រលប់មកមន្ទីរ ស-២១ វិញ អ្នកទាំងនោះស្ថិតក្នុងសភាពទុនខ្សោយដោយមានស្នាមរបួសនៅលើខ្នងរបស់ពួកគេ[286]។ ទាហានវៀតណាមដែលត្រូវបានចាប់ខ្លួនក្នុងអំឡុង

ឆ្នាំ១៩៧៧ ក៏ត្រូវបានគេយកទៅថតជាខ្សែភាពយន្តផងដែរ[287]។ លើសពីនេះទៀត សាក្សីនេះបានឃើញសមាជិកម្នាក់ក្នុងក្រុមរបស់គាត់ត្រូវបានគេចាប់ខ្លួន និងសួរចម្លើយដោយមិនដឹងហេតុផល[288]។

## ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

9. សាក្សីនេះផ្តល់ភស្តុតាងថា នៅពេលត្រលប់មកពីសួរចម្លើយវិញ អ្នកទោសមានស្នាមធ្វើទារុណកម្ម។ មានពេទ្យសម្រាប់ព្យាបាលរបួស[289]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

10. សាក្សីនេះផ្តល់ភស្តុតាងថា អ្នកទោសត្រូវបានគេយកចេញទៅប្រហារជីវិត នៅក្នុងបរិវេណមន្ទីរ ស-២១ ដោយការពារមិនឲ្យលេចព័ត៌មានចេញទៅអ្នកខាងក្រៅ។ សាក្សីនេះបានដឹងតាមរយៈ ប៉េង ថា ជនបរទេសត្រូវបានគេយកទៅសម្លាប់ ប៉ុន្តែសាក្សីនេះមិនបានដឹងថាគេយកទៅសម្លាប់នៅឯណាទេ[290]។ សាក្សីនេះបញ្ជាក់ថា សាកសពចាំបាច់ត្រូវគាស់យកមកដុតរយៈពេលកន្លះឆ្នាំក្រោយ[291]។ នៅពេលធ្វើការនៅមន្ទីរ ស-២១ សមាជិកប្អូន ឬប្រាំនាក់របស់សាក្សីនេះ បានគាស់រណ្តៅកប់សាកសពចំនួនពីរ នៅចម្ងាយប្រហែល ១០០ម ខាងក្រោយផ្ទះនៅតាខ្មៅ[292]។ សាកសពទាំងនោះត្រូវបានគេដាក់គរលើគ្នា[293]។ សាកសពខ្លះនៅជាប់ចំណងដៃ។ សាកសពខ្លះទៀតមិនមានជាប់ចំណងដៃទេ[294]។ សាកសពខ្លះនៅមានរុំមុខ។ សាកសពខ្លះមិនមានរុំមុខទេ[295]។ សាកសពខ្លះបែកលលាដ៏ក្បាលខាងក្រោយ ខ្លះទៀតបែកពីចំហៀង ហើយខ្លះទៀតខ្វូងចូលក្នុងតែម្តង[296]។ សាកសពខ្លះមានរបួសដែលត្រូវបានគេ អារបំពង់ក[297]។ មិនមានស្នាមរបួសដោយសារការបាញ់នឹងកាំភ្លើងឡើយ ហើយអ្នកដែលយកសាក្សីនេះ ទៅកន្លែងគាស់សាកសពនោះ បានប្រាប់គាត់ថាជនរងគ្រោះទាំងអស់នោះត្រូវបានគេវាយសម្លាប់[298]។

## សក្ខីកម្មមុនៗ

11. សាក្សីនេះបានផ្តល់ចម្លើយមុនបីតាមការដឹងរបស់សហព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់ សៅ ខេ ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៥, D59, ERN00058713-00058771 (ភាសាខ្មែរ)។

(2) បទសម្ភាសន៍របស់ សៅ ខេ ដោយ ក.ស.ច.ស-អ.វ.ត.កចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០៨, ERN 00194973-00194977, ឯកសារ D78/8 (ភាសាអង់គ្លេស)។

(3) បទសម្ភាសន៍របស់ សៅ ខេ ដោយ ក.ស.ច.ស-អ.វ.ត.កចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨, ERN 00194983-00194986, ឯកសារ D78/9 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

12. មិនមានឯកសារពាក់ព័ន្ធជាក់លាក់ផ្សេងទៀតដែលត្រូវបាននិយាយយោងដល់នៅក្នុងចម្លើយរបស់សាក្សីឡើយ។

## 14. គុប សឿន ហៅ គុប ព្រាប ហៅ ច្រឹក

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ចំពោះមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161),* ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* ការធ្វើទារុណកម្ម និងការធ្វើបាបយ៉ាងអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងឱ្យទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះ ទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីនេះកើតក្នុងឆ្នាំ១៩៥៦ ក្នុងខេត្តកំពង់ឆ្នាំង[299]។ ក្នុងឆ្នាំ១៩៧៦ គាត់ត្រូវបានគេបញ្ជូនពីអង្គភាពរបស់គាត់នៅកំពង់ត្រឡាច ទៅភ្នំពេញ ដែលនៅទីនោះគាត់ត្រូវបានបង្ហាត់ពីរបៀបវាយអង្គុលីលេខ។ បន្ទាប់មក គាត់ក៏ចាប់ផ្តើមធ្វើការនៅមន្ទីរ ស-២១ វាយអត្ថបទចម្លើយសារភាព[300]។ គាត់ធ្វើការនៅទីនោះរហូតដល់វៀតណាមវាយលុកចូល[301]។

### តួនាទីរបស់ជនជាប់ចោទ

3. ចម្លើយសារភាពដែលសាក្សីនេះបានវាយត្រូវបានប្រគល់ឱ្យមេរបស់គាត់ នៅពេលដែលអ្នកនាំសារពី **ឌុច** បានមកហៅពួកគេ[302]។ គាត់បានដឹងថា **ឌុច** គឺជាប្រធាន។ គាត់ចាត់ទុកការត្រួតត្រាមន្ទីរ ស-២១ របស់ **ឌុច** ថាជា "ការតឹងរ៉ឹងបំផុត" ហើយបញ្ជាក់ថា "មានអ្នកទោសបានបាត់ខ្លួនផងដែរ"[303]។

### ការបង្កើត រយៈពេល និងប្រតិបត្តិការ

4. សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានវាយអត្ថបទចម្លើយសារភាពចេញពីឯកសារសរសេរដោយដៃ ដែលត្រូវបានប្រគល់ឱ្យដោយប្រធានរបស់គាត់ ហ៊ុយ និងស្រែ[304]។ ឯកសារទាំងនោះ ជាជីវប្រវត្តិ ហើយបន្ទាប់មកមានសេចក្តីលំអិតអំពី "សកម្មភាពក្បត់" និងបញ្ជីឈ្មោះអ្នកដែលជាប់ពាក់ព័ន្ធដទៃទៀត។ ឈ្មោះជាច្រើន ដែលមាននៅក្នុងបញ្ជីនោះ ក្រោយមកនឹងក្លាយជាអ្នកដែលត្រូវ សរសេរចម្លើយសារភាពដោយខ្លួនឯង[305]។

5. មេរបស់គាត់ទាំង ហ៊ុយ និងស្រែ ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ១៩៧៨[306]។ ចម្លើយសារភាពភាគច្រើនមកពីភូមិភាគឧត្តរ និងបូព៌ា ហើយអ្នកទាំងនោះគឺជាជនជាតិវៀតណាម ចាម ឬភ្នង[307]។

## ការធ្វើទារុណកម្ម

6. សាក្សីនេះបានឮសម្រែកអ្នកដែលត្រូវបានគេធ្វើទារុណកម្ម[308]។

## សក្ខីកម្មមុនៗ

7. សាក្សីនេះបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់ គុប សឿន ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧, D28/4, ERN 00225123-00225129 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

8. មិនមានឯកសារពាក់ព័ន្ធជាក់លាក់ផ្សេងទៀតដែលត្រូវបាននិយាយយោងដល់នៅក្នុងចម្លើយរបស់សាក្សីឡើយ។

## 15. ទុំ សាត

## ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161)*, ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច*(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំមនុស្សខុសច្បាប់ កង្វះខាតការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឱ្យទៅជាទាសករ ការទទួលរងការឈឺចាប់ធ្ងន់ធ្ងរ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបយ៉ាងអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល និងមនុស្សឃាត និងការសម្លាប់ជនជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាង ដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីនេះមានអាយុប្រហែល ១២ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភេទប្រុស ជនជាតិខ្មែរ កើតប្រហែលក្នុងឆ្នាំ១៩៦៣។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីនេះបានរស់នៅជាមួយឪពុកម្តាយរបស់គាត់ក្នុងស្រុកបរិបូរណ៍។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានក្តាប់អំណាច សាក្សីនេះត្រូវបានគេបំបែកពីឪពុកម្តាយរបស់គាត់ ហើយផ្លាស់ទៅនៅស្រុកតាខ្មៅ ខេត្តកណ្តាល ដែលនៅទីនោះគាត់ត្រូវបានគេបញ្ជាឱ្យចូលរៀនវគ្គបណ្តុះបណ្តាលយុទ្ធសាស្ត្រយោធា។ អស់រយៈពេល ៤-៥ខែ គាត់បានទទួលការបណ្តុះបណ្តាលអំពីការរៀបចំអង្គភាពកុមារ និងការហាត់បាញ់កាំភ្លើង។ សាក្សីនេះផ្តល់ភស្តុតាងថា ទុយ គឺជាប្រធានសាលាបណ្តុះបណ្តាលយោធានេះ។ ក្នុងឆ្នាំ១៩៧៧ គាត់ត្រូវបានគេបញ្ជូនឱ្យទៅធ្វើស្រែនៅជើងឯក ហើយបន្ទាប់មកទៅធ្វើការជាមួយ ហ៊ុយ ដែលជាអ្នកយាមនៅមន្ទីរ ស-២១។ សាក្សីនេះត្រូវបានគេផ្ទេរពីមន្ទីរ ស-២១ ទៅធ្វើការនៅគុកព្រៃស ប្រហែលជាកន្លះខែ មុនពេលដែលរបបនេះដួលរលំ។

### តួនាទីរបស់ជនជាប់ចោទ

3. ជាអ្នកយាមនៅមន្ទីរ ស-២១ សាក្សីនេះផ្ដល់ភស្ដុតាងថា គាត់បានឃើញ ឌុច ជាប្រធានគុក[309]។ គាត់ដឹងច្បាស់នៅពេលដែលគាត់បានឃើញ ឌុច "មើលការខុសត្រូវកន្លែងនោះ"[310]។

### ការបង្កើត រយៈពេល និងប្រតិបត្តិការ

4. សាក្សីនេះផ្ដល់ភស្ដុតាងថា គាត់គឺជាអ្នកយាមនៅមន្ទីរ ស-២១ ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩។ នៅពេលដែលគាត់បានមកដល់មន្ទីរ ស-២១ ដំបូង សាក្សីនេះត្រូវបានគេដាក់នៅក្នុងក្រុមការពារ ដែលដឹកនាំដោយ អឿន ហើយ ហ៊ុយ ជាប្រធានរបស់គាត់[311]។ សាក្សីនេះបានបញ្ជាក់ថា ដោយសារតែគាត់នៅក្មេងពេក គេក៏ឱ្យគាត់យាមនៅទ្វាចូលខាងក្រៅបរិវេណគុក។ គាត់ផ្ដល់ភស្ដុតាងថា មានអគារមួយស្ថិតនៅកណ្ដាលបរិវេណនោះដែលត្រូវបានគេប្រើជាការិយាល័យនៃមន្ទីរ ស-២១។ សាក្សីនេះផ្ដល់ភស្ដុតាងថា គាត់បានដឹងថា ហឹម ហ៊ុយ ជាប្រធានអង្គភាពរថយន្តនៃមន្ទីរ ស-២១[312]។

### រចនាសម្ព័ន្ធសិទ្ធិអំណាច

5. សាក្សីនេះផ្ដល់ភស្ដុតាងថា ឌុច គឺជាប្រធានមន្ទីរ ស-២១។ ហ៊ រ គឺជាកម្មាភិបាលជាន់ខ្ពស់ជិតស្និទ្ធជាមួយ ឌុច ហើយ ប៉េង អ៊ី ក៏ជាកម្មាភិបាលជាន់ខ្ពស់ម្នាក់ដែរ។ សាក្សីនេះផ្ដល់ភស្ដុតាងថា អ្នកយាមត្រូវបានគេរៀបចំជាក្រុម។ ហ៊ុយ គឺជាមេក្រុមរបស់គាត់ ហើយ អឿន គឺជាប្រធានក្រុមរបស់គាត់ គឺក្រុមការពារ។ សាក្សីនេះផ្ដល់ភស្ដុតាងថា គាត់ត្រូវបានគេបញ្ជាឱ្យធ្វើការនៅខាងក្រៅបរិវេណមន្ទីរ ស-២១ (នៅទ្វាចូលគុក)។ សាក្សីនេះផ្ដល់ភស្ដុតាងថា គាត់បានឃើញអ្នកទោស ម្ដងមួយនាក់ ឬពីរនាក់ត្រូវបានគេយកចេញទៅសួរចម្លើយ ហើយបានឃើញស្លាកស្នាមធ្វើទារុណកម្ម ដូចជា ចេញឈាមនៅលើខ្លួន នៅពេលដែលគេយកអ្នកទោសត្រលប់មកកន្លែងឃុំខ្លួនវិញ ហើយគាត់បានឃើញការបាត់ខ្លួនរបស់សន្តិសុខយាមនៅមន្ទីរ ស-២១[313]។ សាក្សីនេះផ្ដល់ភស្ដុតាងថា នៅខាងក្នុងបរិវេណនោះមានអគារការិយាល័យមួយស្ថិតនៅកណ្ដាលមន្ទីរ ស-២១។

### ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្ដីដោយយុត្តិធម៌

6. សាក្សីនេះមិនបានផ្ដល់ព័ត៌មានអំពីអ្នកជាប់ឃុំឃាំង ចំនួន និងប្រភេទនៃអ្នកឃុំឃាំងទេ ដោយសារតែគាត់បានយាមនៅខាងក្រៅបរិវេណ ហើយមិនមានព័ត៌មានទាក់ទិនទៅនឹងបញ្ហាទាំងនេះទេ។

## ការធ្វើឱ្យទៅជាទាសករ ការបង្អត់ការឈប់ចាប់ផ្ដើមដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

7. សាក្សីនេះផ្ដល់ភស្ដុតាងថា នៅពេលធ្វើការជាអ្នកយាមនៅមន្ទីរ ស-២១ គាត់ទទួលបានតែបបររាវៗ ឬក៏សម្លរជាមួយត្រកួនពីរបីដើមហូបតែប៉ុណ្ណោះ[314]។

## ការសួរចម្លើយ

8. សាក្សីនេះផ្ដល់ភស្ដុតាងថា អ្នកយាមត្រូវបានគេឃើញបណ្ដើរអ្នកទោសចេញពីគុក ដើម្បីយកទៅសួរចម្លើយ[315]។

## ការធ្វើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

9. សាក្សីនេះផ្ដល់ភស្ដុតាងថា អ្នកយាមត្រូវបានគេឃើញបណ្ដើរអ្នកទោសចេញពីគុក ដើម្បីយកទៅសួរចម្លើយ។ នៅពេលគេយកអ្នកទោសត្រលប់មកវិញ គេឃើញមានចេញឈាមនៅលើដងខ្លួន ដែលជាសញ្ញាណបញ្ជាក់ថាអ្នកទោសទាំងនោះត្រូវបានគេធ្វើទារុណកម្ម[316]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

10. សាក្សីនេះផ្ដល់ភស្ដុតាងអំពីការបាត់ខ្លួនអ្នកយាមខ្លះ មិនដែលឃើញត្រលប់មកវិញឡើយ។ គាត់សន្មតថាពួកគេបានស្លាប់[317]។

## សក្ខីកម្មមុនៗ

11. សាក្សីនេះបានផ្ដល់ចម្លើយមុនពីរតាមការដឹងរបស់សហព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់ ទុំ សាត ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី5 ខែឧសភា ឆ្នាំ2005, D59, ERN 00058694-00058712 (ភាសាខ្មែរ)។

(2) បទសម្ភាសន៍របស់ទុំ សាត ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ2001, ERN 00058138-00058139 (ភាសាខ្មែរ)។

## ឯកសារពាក់ព័ន្ធដទៃទៀត

12. មានវត្ថុតាងជាក់លាក់មួយដែលចម្លើយរបស់សាក្សីរូបនេះយោងដល់ :

(1) **ប្រវត្តិរូបរបស់ទុំ សាត មិនមានចុះការបរិច្ឆេទ**, ERN 00058138-00058139 (**ភាសាខ្មែរ**)។

## 16. ម៉ៃម យាន

## ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីរូបនេះផ្ដល់ភស្តុតាងអំពីគោលនយោបាយ និងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ចំពោះមន្ទីរ ស-២១ សាក្សីនេះផ្ដល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161),* ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច*(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំមនុស្សខុសច្បាប់ កង្វះខាតការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឱ្យទៅជាទាសករ ការទទួលរងការឈឺចាប់ធ្ងន់ធ្ងរ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបយ៉ាងអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល និងមនុស្សឃាត និងការសម្លាប់ជនជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្ដល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុប្រហែល ១៩ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភេទប្រុស ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៥៦។ ក្នុងឆ្នាំ១៩៧២ សាក្សីនេះបានធ្វើជាឈ្លបឃុំ ហើយក្នុងឆ្នាំ១៩៧៤ គាត់បានផ្លាស់ទៅធ្វើជាឈ្លបស្រុកនៅស្រុកកំពង់ត្រឡាច។ ពីរខែបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានក្ដាប់អំណាច សាក្សីនេះត្រូវបាន ចាន់ មកពីមន្ទីរ ស-២១ ជ្រើសរើសយកទៅហ្វឹកហាត់យុទ្ធសាស្ត្រយោធានៅតាខ្មៅ រយៈពេលបីខែមុនពេលដែលគាត់ត្រូវបានគេបញ្ជូនទៅមន្ទីរ ស-២១ ប្រហែលជានៅចុងឆ្នាំ១៩៧៥។ ក្នុងខែមករា ឆ្នាំ១៩៧៩ សាក្សីនេះបានភៀសខ្លួនចូលព្រៃជាមួយ ឌុច។ គាត់បានរស់នៅក្នុងជំរុំជនភៀសខ្លួនក្នុងទឹកដីថៃមុនពេលត្រលប់មកផ្ទះវិញក្នុងឆ្នាំ១៩៨៣។

## តួនាទីរបស់ជនជាប់ចោទ

3. សាក្សីនេះផ្ដល់ភស្តុតាងថា **ឌុច** គឺជាប្រធានមន្ទីរ ស-២១។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

4. សាក្សីនេះផ្តល់ភស្តុតាងថា គាត់ត្រូវបានគេជ្រើសរើសឲ្យទៅហ្វឹកហាត់យុទ្ធសាស្ត្រយោធានៅតាខ្មៅ ហើយបន្ទាប់មក គាត់ត្រូវបានគេបញ្ជូនទៅមន្ទីរ ស-២១ ដោយសារតែប្រវត្តិរូបរបស់គាត់ល្អ[318]។ គាត់បានស្នាក់នៅបឹងទំពុនរយៈពេលពីរបីថ្ងៃ មុនពេលគាត់ត្រូវបានគេបញ្ជូនទៅតាខ្មៅ ដែលនៅទីនោះ គាត់បានរៀនអំពីយុទ្ធសាស្ត្រយោធាជាមួយមនុស្សចំនួន ៥០-៦០នាក់ផ្សេងទៀត ដែលពួកគេខ្លះក្រោយមកត្រូវបានគេផ្លាស់ទៅមន្ទីរ ស-២១[319]។ សាក្សីនេះផ្តល់ភស្តុតាងថា មន្ទីរ ស-២១ បានចាប់ផ្តើមប្រតិបត្តិការមុនការមកដល់របស់គាត់ ហើយកាលដំបូង អ្នកជាប់ឃុំឃាំងត្រូវបានគេឃុំខ្លួននៅក្នុងផ្ទះជុំវិញមន្ទីរ ស-២១[320]។ សាក្សីនេះផ្តល់ភស្តុតាងថា អ្នកជាប់ឃុំឃាំងត្រូវបានគេផ្ទេរពីផ្ទះទាំងនោះចូលទៅមន្ទីរ ស-២១ ហើយថាចំនួនអ្នកជាប់ឃុំឃាំងដែលត្រូវបានគេនាំយកទៅមន្ទីរ ស-២១ មានកាន់តែច្រើនឡើងៗ ជាពិសេសនៅពេលវៀតណាមជិតវាយលុកចូល[321]។ សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានសរសេរជីវប្រវត្តិពីរ ជីវប្រវត្តិមួយសរសេរនៅផ្ទះដោយ ចាន់ និងមួយទៀតសរសេរនៅមន្ទីរ ស-២១[322]។ សាក្សីនេះផ្តល់ភស្តុតាងថា មានអគារបួននៅមន្ទីរ ស-២១ ហើយថា គាត់មានភារកិច្ចយាមនៅខាងក្នុងបន្ទប់អ្នកទោស ចាប់ពីម៉ោង១២ [ថ្ងៃត្រង់] ដល់ម៉ោង៦ព្រឹក[323]។ គាត់បានឮថា ប៉ុល ពត បានមកបង្រៀននៅមន្ទីរ ស-២១ ម្តង រយៈពេលមួយសប្តាហ៍[324]។

## រចនាសម្ព័ន្ធសិទ្ធិអំណាច

5. សាក្សីនេះផ្តល់ភស្តុតាងថា **ឌុច** គឺជាប្រធានមន្ទីរ ស-២១ និង ហ៊ រ ជាអនុប្រធាន ហើយ ចាន់ ប្រហែលជាកម្មាភិបាលជាន់ខ្ពស់ទីបី[325]។ ហៀក គឺជាប្រធានក្រុមរបស់គាត់ ប៉ុន្តែក្រោយមកត្រូវបានគេចាប់ខ្លួន និងប្រហារជីវិត[326]។ សាក្សីនេះផ្តល់ភស្តុតាងថា អ្នកយាមត្រូវបានគេបែងចែកជាបួនក្រុម ហើយបានហ្វឹកហាត់យុទ្ធសាស្ត្រយោធានៅតាខ្មៅ ហើយថាពួកគេភាគច្រើនមកពីខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ និងខេត្តកណ្តាល[327]។ អ្នកយាម និងអ្នកសួរចម្លើយមកពីផ្នែកផ្សេងៗគ្នា ប៉ុន្តែធ្វើការក្នុងការិយាល័យតែមួយ[328]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

6. សាក្សីនេះផ្តល់ភស្តុតាងថា ពីដំបូង អ្នកជាប់ឃុំឃាំងត្រូវបានគេឃុំខ្លួននៅក្នុងផ្ទះជុំវិញមន្ទីរ ស-២១ ហើយប្រមាណ ៤-១០ថ្ងៃ បន្ទាប់ពីគាត់បានមកដល់មន្ទីរ ស-២១ អ្នកទោសទាំងនោះត្រូវបានគេផ្ទេរទៅ

ក្នុងមន្ទីរ ស-២១[329]។ សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានឃើញអ្នកទោសជនជាតិបារាំង វៀតណាម និងថៃ នៅមន្ទីរ ស-២១[330]។ សាក្សីនេះផ្តល់ភស្តុតាងថា មានអ្នកទោសស្ត្រី ហើយពួកគេត្រូវបានគេឃុំខ្លួនដាច់ដោយឡែកពីអ្នកទោសបុរស។ អ្នកទោសនេះផ្តល់ភស្តុតាងថា គាត់ធ្លាប់បានឃាមអ្នកទោសស្ត្រីម្នាក់ឈ្មោះ យាយ ម៉ែន ដែលជាមេបញ្ជាការនៃកងពលធំមួយ ហើយថាពួកគេមានកូនមួយជាមួយគ្នា[331]។ សាក្សីនេះផ្តល់ភស្តុតាងថា បន្ទាប់ពីគាត់បានមកដល់មន្ទីរ ស-២១ បានរយៈពេល ពីរខែ បន្ទប់រៀនត្រូវបានគេខាន់ជាបន្ទប់តូចៗសម្រាប់ឃុំខ្លួនអ្នកទោសម្នាក់ៗ[332]។ សាក្សីនេះផ្តល់ ភស្តុតាងថា នៅពេលមួយនោះ មានមនុស្សចំនួន ៥០-៦០នាក់ ដែលជាចំនួនច្រើនបំផុតបានមកដល់មន្ទីរ ស-២១ ហើយថា ក្នុងបន្ទប់សាលារៀនកម្រទំនេរណាស់[333]។

## ការធ្វើឲ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

7. សាក្សីនេះផ្តល់ភស្តុតាងថា អ្នកទោសត្រូវបានគេឃុំខ្លួនក្នុងបន្ទប់មួយៗដាច់ពីគ្នា ហើយបន្ទាប់ពីសួរចម្លើយរួច ពួកគេត្រូវបានគេយកទៅដាក់នៅជាន់ខាងលើនៃមន្ទីរ ស-២១ ដោយដាក់ខ្នោះជើងភ្ជាប់ទៅនឹងរនុកដែក[334]។ អ្នកទោសត្រូវបានគេដាក់ខ្នោះដៃ ហើយទទួលបានអាហារពីរពេលក្នុងមួយថ្ងៃនៅម៉ោង ៨ព្រឹក និង ៤ល្ងាច[335]។ សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានឮថាមានអ្នកទោសខ្លះសម្លាប់ខ្លួនឯងដោយព្យួរក លេបថ្នាំ ឬប្រើដែកគោលសម្លាប់ខ្លួនឯង[336]។ ជារឿយៗគាត់បានឃើញអ្នកទោស ៤-៥នាក់ ស្លាប់ជារៀងរាល់ខែ[337]។ ពេទ្យមើលថែអ្នកទោសដែលមានជម្ងឺពីរដងជារៀងរាល់ថ្ងៃ[338]។ អ្នកទោសត្រូវបានគេងូតទឹកឲ្យរួមគ្នាក្នុងបន្ទប់តែមួយ ដោយបាញ់នឹងទុយោទឹក ពីរ ឬបីថ្ងៃម្តងក្នុងខណៈដែល ពួកគេនៅជាប់ខ្នោះជើង[339]។ អ្នកទោសត្រូវបានគេបង្ខំឲ្យបន្ទោរបង់ដាក់ក្នុងកេះគ្រាប់[340]។ នៅពេលយប់ ពួកគេស្លៀកតែខោខ្លីប៉ុណ្ណោះ[341]។

## ការសួរចម្លើយ

8. សាក្សីនេះផ្តល់ភស្តុតាងថា អ្នកទោសទាំងអស់នៅមន្ទីរ ស-២១ ត្រូវបានគេសួរចម្លើយ ហើយជាធម្មតាក្នុងការសួរចម្លើយម្តងៗមានរយៈពេលបី ទៅប្រាំថ្ងៃ ហើយការសួរចម្លើយខ្លះបន្តដល់រយៈពេល ដប់ថ្ងៃ[342]។ ការសួរចម្លើយត្រូវបានគេធ្វើនៅក្នុងផ្ទះជុំវិញគុក ខាងជើងទ្វារចូល ចាប់ពីម៉ោង៧ព្រឹកដល់ម៉ោង១១ព្រឹក ម៉ោង១ថ្ងៃ ដល់ម៉ោង៥ល្ងាច ហើយជួនកាលពីម៉ោង១ថ្ងៃ ដល់ម៉ោង៩យប់[343]។ សាក្សីនេះបាននិយាយថា គាត់មិនដែលបានឃើញការសួរចម្លើយទេ ប៉ុន្តែគាត់បានឃើញអ្នកទោសចេញ ឈាម និងមានស្នាមជាំ

បណ្តាលមកពីការវាយ និងការឆក់ខ្សែភ្លើងបន្ទាប់ពីការសួរចម្លើយ[344]។ បន្ទាប់ពីសួរចម្លើយរួច អ្នកទោសត្រូវបានគេយកចេញពីបន្ទប់ ហើយដឹកយកចេញទៅតាមរថយន្ត[345]។

## ការធ្វើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

9. សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានឃើញស្នាមជាំ និងមានចេញឈាម នៅពេលអ្នកទោសត្រលប់មកពីបន្ទប់សួរចម្លើយវិញ[346]។ សាក្សីនេះផ្តល់ភស្តុតាងថា អ្នកទោសបានធ្វើអត្តឃាត ពីព្រោះពួកគេត្រូវបានគេវាយធ្វើបាបរាល់ថ្ងៃ[347]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

10. សាក្សីនេះផ្តល់ភស្តុតាងថា បន្ទាប់ពីសួរចម្លើយចប់សព្វគ្រប់ អ្នកទោសត្រូវបានគេយកចេញពីបន្ទប់ ហើយដឹកយកចេញទៅតាមរថយន្ត[348]។ អ្នកទោសត្រូវបានគេយកទៅសួរចម្លើយ ហើយត្រូវបានគេដឹកយកចេញទៅតាមរថយន្តជារៀងរាល់ ៣-១០ថ្ងៃ ម្តង ដោយមានអ្នកទោសពីរ ឬបីនាក់ត្រូវបានគេយកចេញពីបន្ទប់ធំនីមួយៗ[349]។ ប្រធានក្រុមរបស់សាក្សីនេះគឺឈ្មោះ ហៀក ដែលក្រោយមកត្រូវបានគេចាប់ខ្លួន ហើយដាក់គុកនៅកន្លែងដែលសាក្សីនេះត្រូវបានគេចាត់ឲ្យយាមរូបគាត់[350]។

## សក្ខីកម្មមុនៗ

11. សាក្សីនេះបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់ យ៉ែម យាន ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជាចុះថ្ងៃទី 9 ខែមិថុនា ឆ្នាំ2002, D59, ERN 00057010-00057052 (ភាសាខ្មែរ)។

## ឯកសារពាក់ព័ន្ធដទៃទៀត

12. មានវត្ថុតាងជាក់លាក់មួយសម្រាប់យោងទៅនឹងចម្លើយរបស់សាក្សីរូបនេះ :

(1) ប្រវត្តិរូបរបស់ យ៉ែម យាន ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៧, ERN 00062418-0006242 (ភាសាខ្មែរ)។

## 17. យិន ឡុញ

## ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីរូបនេះផ្តល់ភស្តុតាងអំពីគោលនយោបាយ និងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ចំពោះមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161)*, ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធ សិទ្ធិអំណាច*(20-25)* និងការធ្វើឱ្យទៅជាទាសករ ការទទួលរងការឈឺចាប់ធ្ងន់ធ្ងរ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)*។ ភស្តុតាងរបស់គាត់ទាក់ទិនទៅនឹងបទចោទទី១, ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ដូចខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីនេះមានអាយុប្រហែល ១៧-១៨ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភេទប្រុស ជនជាតិខ្មែរ កើតនៅភូមិព្រៃជ្រៅ ខេត្តកំពង់ឆ្នាំង។ គាត់បានចូលបដិវត្តន៍ក្នុងឆ្នាំ១៩៧១ បម្រើការក្នុងអង្គភាពកុមារ។ បន្ទាប់ពីខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីនេះត្រូវបានគេបញ្ជូនទៅទីក្រុងភ្នំពេញ ហើយត្រូវបានគេចាត់តាំងឱ្យធ្វើការក្នុងភូមិបាគូ ស្ទឹងព្រែកត្នោត ដែលជាជំរុំរងរបស់មន្ទីរ ស-២១។ មួយខែក្រោយមក សាក្សីនេះត្រូវបានគេបញ្ជូនទៅចោមចៅ ដើម្បីជីកប្រឡាយ និងធ្វើស្រែ។ ក្នុងឆ្នាំ១៩៧៧ សាក្សីនេះត្រូវបានគេចាត់តាំងឱ្យធ្វើជាអ្នកយាមនៅមន្ទីរ ស-២១ ដែលគាត់នៅទីនោះរហូតដល់ការរំដោះទីក្រុងភ្នំពេញនៅខែមករា ឆ្នាំ១៩៧៩[351]។

## រចនាសម្ព័ន្ធ និងគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ

3. សាក្សីនេះផ្តល់ភស្តុតាងថា តាពិន គឺជាមេបញ្ជាការនៃកងពលធំ៧០៣[352]។

## តួនាទីរបស់ជនជាប់ចោទ

4. ជាអ្នកយាមនៅខាងក្រៅ និងជាអ្នកនាំសារនៅមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងថា **ឌុច** គឺជាប្រធានមន្ទីរ ស-២១ ហើយថា គាត់បានឃើញ **ឌុច** ចាប់អ្នកធ្វើការនៅបាគូ ដោយខ្លួនគាត់ផ្ទាល់[353]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

5. សាក្សីនេះផ្តល់ភស្តុតាងថា មន្ទីរ ស-២១ បានបង្កើតឡើងតាំងពីឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។ ពីដំបូងសាក្សីមានភារកិច្ចដាំបន្លែជាមួយមនុស្ស ២០នាក់ផ្សេងទៀត បន្ទាប់មកគាត់ត្រូវបានគេចាត់តាំងឱ្យទៅយាមនៅខាងក្រៅមន្ទីរ ស-២១។ គាត់និយាយថា គាត់ត្រូវបានគេតែងតាំងតួនាទីនេះពីព្រោះគាត់គឺជាកសិករក្រីក្រ[354]។ មានអគារបួននៅមន្ទីរ ស-២១ ហើយកន្លែងនោះព័ទ្ធជុំវិញទៅដោយជញ្ជាំងស័ង្កសី មានកំពស់ ២ម ហើយមានបន្លាលួសនៅពីលើកំពស់ ៥០សង់ទីម៉ែត្រ[355]។ មានអ្នកយាមសរុបចំនួន ៥០០នាក់ នៅមន្ទីរ ស-២១ រួមទាំងអ្នកយាមខាងក្នុង និងខាងក្រៅកន្លែងនោះ[356]។

## រចនាសម្ព័ន្ធសិទ្ធិអំណាច

6. សាក្សីនេះផ្តល់ភស្តុតាងថា គាត់បានឃើញ **ឌុច** និង ហ៊ី ចាប់អ្នកធ្វើការនៅបាគូ[357]។ គាត់ត្រូវបានគេជ្រើសរើសឱ្យធ្វើជាអ្នកយាមនៅមន្ទីរ ស-២១ ដោយ ផល ដែលជាមេបញ្ជាការកងអនុសេនាធំ[358]។

## ការធ្វើឱ្យទៅជាទាសករ ការបង្អត់អាហារ ការបង្ករការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

7. សាក្សីនេះផ្តល់ភស្តុតាងថា នៅបាគូ ដែលជាជំរំរងរបស់មន្ទីរ ស-២១ អ្នកធ្វើការទាំងអស់ចាប់ផ្តើមការងារតាំងពីព្រឹកព្រលឹម រហូតដល់យប់ជ្រៅ ដោយជីកប្រឡាយ និងធ្វើស្រែ។ ស្ថានភាពរស់នៅលំបាកយ៉ាងខ្លាំង និងមិនមានអាហារហូបគ្រប់គ្រាន់ទេ[359]។

## សក្ខីកម្មមុនៗ

8. សាក្សីនេះបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា :

(1) បទសម្ភាសន៍របស់ ឃិន ឡាញ ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី 12 ខែឧសភា ឆ្នាំ2005, ERN 00060031-00060035 (ភាសាខ្មែរ)-បកប្រែជាភាសាអង់គ្លេស; អត្ថបទសង្ខេប ជាភាសា អង់គ្លេស (ERN 00060031-00060060)។

## ឯកសារពាក់ព័ន្ធដទៃទៀត

9. មានវត្ថុតាងជាក់លាក់មួយសម្រាប់យោងទៅនឹងចម្លើយរបស់សាក្សីរូបនេះ :

(1) ប្រវត្តិរូបរបស់ យិន ឡុញ ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា, DCCN K05512, ***បច្ចុប្បន្នការិយាល័យ សហព្រះរាជអាជ្ញាពុំមានសំណៅឯកសារនេះទេ។**

## III. ជនជាប់ឃុំឃាំងស-២១

## 18. ហ៊ុយ ប៉ាន់ ហៅ កាំង ប៉ាន់

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីផ្តល់ភស្តុតាងអំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* និងរចនាសម្ព័ន្ធ និងគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ទាក់ទងនឹងមន្ទីរ ស-២១ សាក្សីនេះបានផ្តល់ភស្តុតាងអំពីតួនាទីនៃជនត្រូវចោទ *(55-59, 90-99 107-111 & 153 [ថ្មី]-161)*ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរមួយនេះ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច *(20-25)* ការដាក់មនុស្សក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងមនុស្សដោយខុសច្បាប់ កង្វះការកាត់សេចក្តីដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឱ្យទៅជាទាសករ ការរងការឈឺចាប់ធ្ងន់ធ្ងរ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* និងការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបបែបអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល មនុស្សឃាត មនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់នាងពាក់ព័ន្ធនឹងបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទស្រី ជនជាតិខ្មែរ កើតក្នុងខ្ទង់ឆ្នាំ១៩៥៤ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានអាយុខ្ទង់២១ឆ្នាំ។ មុនចូលបដិវត្តន៍ឆ្នាំ១៩៧៤ ជាកសិករ។ ក្រោយចូលទ័ព នាងរៀនសូត្រច្បាប់ ហ្វឹកហ្វឺនផ្នែកទ័ពចំនួន១ឆ្នាំ នៅកោះខ្សាច់ជន្លា។ សាក្សីត្រូវបានជម្លៀសទៅកាន់កងពលធំ១២ នៅកំពង់ព្រីង និងក្រោយមកទៀតនៅសមរភូមិខាងត្បូងតាខ្មៅ។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីស្ថិតនៅក្បែរទួលក្រសាំង។ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីឈរជើងនៅមន្ទីរ ខេត្តកណ្តាលតាខ្មៅ។ ចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ នាងបានត្រូវគេឱ្យផ្លាស់ទៅស្ទឹងបាគូ ទល់ពេលវៀតណាមចូលឆ្នាំ១៩៧៩។ កាលនៅស្ទឹងបាគូ សាក្សីជាប្រធានក្រុមមួយមានសមាជិក ១២នាក់ ក្រោយមកត្រូវបានចាត់តាំងឱ្យទៅមើលក្មេងកំព្រា។

## ជម្លោះប្រដាប់អាវុធ

3. សាក្សីផ្ដល់ភស្តុតាងថាមានការខូចខាតវត្តអារាម និងចេតិយ គ្រប់ទីកន្លែងបណ្ដាលមកពីការទម្លាក់គ្រាប់បែកក្នុងអំឡុងសង្គ្រាម[360]។ ប៉ុន្តែសាក្សីនឹងធ្វើសក្ខីកម្មថាវត្តដែលនៅសេសសល់ មិនបានត្រូវខ្មែរក្រហមកម្ទេចចោលទេ។ សាក្សីផ្ដល់ភស្តុតាងថា គ្មានឡើយការគោរពប្រណិប័តន៍សាសនា[361]។

## វចនាសម្ព័ន្ធ និងគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ

4. សាក្សីផ្ដល់ភស្តុតាងថាឌុច ជាអ្នកកាន់ក្ដាប់ស្ទឹងបាគូ [362]។ សាក្សីបានជួបឌុច កាលនាងរៀនសូត្រនៅមន្ទីរទួលស្លែង[363]។ សាក្សីផ្ដល់ភស្តុតាងថាស្ទឹងបាគូជាផ្នែកមួយនៃមន្ទីរ ស-២១ និងក៏ជាកន្លែងលត់ដំដែរ[364]។

## តួនាទីរបស់ជនជាប់ចោទ

5. សាក្សីនឹងចំណាំថាឌុច ជាប្រធានមន្ទីរឃុំឃាំង ស-២១[365]។ សាក្សីផ្ដល់ភស្តុតាងថា កាលណោះស្ទឹងបាគូស្ថិតក្រោមការគ្រប់គ្រងរបស់ឌុច។ សាក្សីនឹងបញ្ជាក់ថាខ្លួនធ្លាប់បានឃើញឌុច ក្បែរមន្ទីរ ស-២១ ទីដែលសាក្សីទៅរៀនសូត្រ[366]។ សាក្សីបញ្ជាក់ថាជួនកាល **ឌុច**មកបង្រៀននៅមន្ទីរដែលនាងរៀនសូត្រ ប៉ុន្តែភាគច្រើនគ្រូផ្សេងជាអ្នកបង្រៀន[367]។

6. សាក្សីផ្ដល់ភស្តុតាងថា **ឌុច**កម្រមកស្ទឹងបាគូណាស់ ទុកឱ្យសាក្សីរៀនសូត្រជាមួយគ្រូផ្សេងវិញ[368]។ ឆ្នាំ១៩៧៨សាក្សីបានឃើញ**ឌុច** មកស្ទឹងបាគូចំនួន២លើកជាមួយនឹងនារសាម្នាក់ ប៉ុន្តែគ្រាន់តែមកជួប ឈ្មោះហ៊ុយប៉ុណ្ណោះ[369]។ សាក្សីអាចចំណាំមុខឌុចបានព្រោះធ្លាប់ជួបឌុច កាលខ្លួននៅរៀនសូត្រនៅទួល ស្លែង[370]។ សាក្សីផ្ដល់ភស្តុតាងថាឈ្មោះហ៊ុយ ជាអ្នកកាន់ក្ដាប់ស្ទឹងបាគូក្រោមការគ្រប់គ្រងរបស់ ឌុច[371]។ សាក្សីនឹងធ្វើសក្ខីកម្មថាហ៊ុយ គ្រាន់តែជាអ្នកធ្វើតាមបញ្ជារបស់មន្ទីរស-២១តែប៉ុណ្ណោះ ហើយ គឺមន្ទីរស-២១នេះឯងគឺជាអ្នកចេញបទបញ្ជាឱ្យដក និងឱ្យផ្ទេរមនុស្សទៅស្ទឹងបាគូ[372]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

7. សាក្សីផ្ដល់ភស្តុតាងថា ខ្លួនជាប្រធានក្រុមមួយដែលមានមនុស្សចំនួន១២នាក់ នៅស្ទឹងបាគូចាប់ពីចុងឆ្នាំ១៩៧៥ ឬ១៩៧៦ មកទល់ថ្ងៃវៀតណាមវាយលុកឆ្នាំ១៩៧៩[373]។ ក្នុងក្រុមមានឈ្មោះ ថា ប្រាក់

និងខែម[374]។ សាក្សីបញ្ជាក់ថា កិច្ចការសំខាន់នៅស្ទឹងបាគូ គឺធ្វើស្រែចម្ការ និងជីកប្រឡាយ[375]។ សាក្សីក៏មានភារកិច្ចត្រូវមើលកុមារដែលបែកពីឪពុកម្ដាយ[376]។

## រចនាសម្ព័ន្ធសិទ្ធិអំណាច

8. សាក្សីផ្ដល់ភស្តុតាងថា **ឌុច** ជាប្រធានមន្ទីរឃុំឃាំងស-២១។ សាក្សីនឹងបញ្ជាក់ថាហ៊ុយ ជាសមាជិកកម្មាភិបាលឈានមុខនៅស្ទឹងបាគូ ប៉ុន្តែបានបាត់ខ្លួនមុនពេលវៀតណាមចូលឈ្លានពាន[377]។ សាក្សីផ្ដល់ភស្តុតាងថាប្រពន្ធហ៊ុយ ឈ្មោះឃឿន ដែលជាប្រធានកងរយរបស់ខ្លួនក៏បានបាត់ខ្លួនដែរ[378]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្ដីដោយយុត្តិធម៌

9. សាក្សីនឹងបញ្ជាក់ថាមានកម្មករពី២ ទៅ៣នាក់ ត្រូវផ្ទេរទៅកាន់មន្ទីរ ស-២១ ជារៀងរាល់យប់ [379]។

10. សាក្សីផ្ដល់ភស្តុតាងថា នាងបានឃើញកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ ចាប់ខ្លួនមនុស្សនៅស្ទឹងបាគូ និងដាក់តាមរថយន្តទៅទួលស្លែង នៅម៉ោងប្រមាណ៥ ឬ៦ល្ងាច រៀងរាល់សប្ដាហ៍ ឬដប់ថ្ងៃម្ដង[380]។ សាក្សីបានចំណាំរថយន្តដឹកអ្នកទោសនោះច្បាស់ ពេលនាងមករៀនសូត្រនៅទួលស្លែង[381]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

11. សាក្សីផ្ដល់ភស្តុតាងថា នៅឯស្ទឹងបាគូ ខ្លួនធ្វើស្រែ និងត្រូវបានខ្មែរក្រហមបង្ខំឱ្យជីកប្រឡាយ[382]។ សាក្សីនឹងបញ្ជាក់ថាការងារនៅស្ទឹងបាគូ ត្រូវចាប់ផ្ដើមនៅម៉ោង៦ព្រឹករហូតទល់យប់ជ្រៅ[383]។ សាក្សីនឹងអះអាងថាកុមារក្មេងៗ អាយុពី៨ ទៅ១០ឆ្នាំ បានត្រូវបង្ខំឱ្យច្រូតកាត់[384]។ សាក្សីនិយាយថាស្ទឹងបាគូរបបអាហារហូបចុកគ្រប់គ្រាន់ ហើយអ្នកធ្វើការនៅទីនោះ ទទួលបានអាហារ៣ពេល មួយថ្ងៃមានបាយ និងសាច់[385]។

## ការធ្វើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

12. សាក្សីផ្ដល់ភស្តុតាងថា ខ្លួនមិនបានឃើញការធ្វើទារុណកម្ម នៅស្ទឹងបាគូទេ[386]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

13. សាក្សីផ្ដល់ភស្តុតាងថាឥតគ្មានកាប់សម្លាប់មនុស្សនៅស្ទឹងបាគូ ប៉ុន្តែមានមនុស្សបាត់ខ្លួន[387]។ សាក្សីនឹងបញ្ជាក់ថាមានមនុស្សត្រូវបាននាំខ្លួនពីស្ទឹងបាគូ ទៅកាន់មន្ទីរ ស-២១ បើទោះបីជាខ្លួនមិនដឹងថាមានអ្វីកើតឡើងចំពោះពួកគេ[388]។ សាក្សីផ្ដល់ភស្តុតាងថា ក្នុងចំណោមអ្នកបាត់ខ្លួនពីស្ទឹងបាគូក្នុងនោះមាន

កុមារ។ ក៏បានបាត់ខ្លួនពីស្នឹងបាត្តដែរ[389]។ សាក្សីនិយាយថាខ្លួនមិនគិតថា កុមារទាំងនោះមិនត្រូវបានខ្មែរក្រហមនាំយកទៅកាន់មន្ទីរ ស-២១ទេ[390]។ សាក្សីផ្តល់ភស្តុតាងថាការរៀបអាពាហ៍ពិពាហ៍រួម ជាច្រើនគូរសម្រាប់ពេទ្យទាហាន និងកងទ័ព មួយលើកមានរហូតដល់សាមសិបនាក់[391]។

## សក្ខីកម្មមុនៗ

14. សាក្សីនេះបានផ្តល់ចម្លើយមុនពីរ តាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ ហ៊ុយ ប៉ាន់ ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី 12 ខែតុលា ឆ្នាំ2003, D.59, ឧបសម្ព័ន្ធ លេខ 00009, ERN 00052417-00052440 (ភាសាខ្មែរ) [អត្ថបទសង្ខេប ជាភាសាអង់គ្លេស – គ្មាន ERN]។

(2) បទសម្ភាសន៍របស់ កាំង ប៉ាន់ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 31 ខែមីនា ឆ្នាំ2008, នៅ ERN 00195380, D78/3, ERN 00195378-00195386 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

15. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយនៅក្នុងចម្លើយរបស់សាក្សី។

## 19. លោក ម៉េងស៊ាន

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទងនឹងមន្ទីរ ស-២១ សាក្សីផ្តល់ភស្តុតាងអំពីការបង្កើត ថេរៈវេលា និងប្រតិបត្តិការនៃ មន្ទីរសន្តិសុខមួយនេះ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច *(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំខ្លួនមនុស្សដោយខុសច្បាប់ ការកង្វះការជំនុំជម្រះក្តីដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឱ្យទៅជាទាសករ ការរងការឈឺចាប់ធ្ងន់ធ្ងរ ទង្វើអមនុស្សធម៌ *(62-71, 135, 143 & 148)* និងការសម្លាប់រង្គាល មនុស្សឃាត មនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ ទាក់ទងនឹងបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទប្រុស ជនជាតិខ្មែរ កើតនៅក្នុងខ្ទង់ឆ្នាំ១៩៦២ មានអាយុប្រហែល១៣ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ សាក្សីជាបងប្អូនប្រុសឈ្មោះ ស្រ៊ុន សុង បានចូលទ័ពកម្ពុជា ប្រជាធិបតេយ្យ ប្រហែលពីរទៅបីខែនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ចុងឆ្នាំ១៩៧៥ សាក្សី ត្រូវបានចាប់ខ្លួនបញ្ជូនទៅធ្វើការនៅព្រៃស។ សាក្សីជាអ្នកទោសនៅព្រៃស មកទល់ថ្ងៃរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ក្នុងឆ្នាំ១៩៧៩[392]។

### ការបង្កើត រយៈពេល និងប្រតិបត្តិការ

3. សាក្សីផ្តល់ភស្តុតាងថាខ្លួនត្រូវបានឃុំខ្លួននៅព្រៃស ពីចុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ អំឡុងពេលបួនឆ្នាំនៅព្រៃស ពេលថ្ងៃសាក្សីត្រូវធ្វើស្រែ និងជីកប្រឡាយ ពេលយប់ចាក់សោរមិនឱ្យចេញក្រៅ។ គេប្រាប់សាក្សីថាខ្លួនបានរួចជីវិត ដោយសារបងប្អូនប្រុសម្នាក់ឈ្មោះស្រ៊ុន សុន ធ្វើការនៅទួលស្លែង[393]។

### រចនាសម្ព័ន្ធសិទ្ធិអំណាច

4. សាក្សីផ្តល់ភស្តុតាងថាឈ្មោះស្រ៊ូ ជា"ប្រធានព្រៃស"[394]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

5. សាក្សីផ្តល់ភស្តុតាងថា នៅព្រៃសមានអ្នកទោសជាច្រើនរយនាក់ ដែលសុទ្ធតែជាមនុស្សប្រុសទាំងអស់[395]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

6. សាក្សីផ្តល់ភស្តុតាងថានៅពេលយប់អ្នកទោសត្រូវបានដាក់ខ្នោះ[396]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

7. សាក្សីផ្តល់ភស្តុតាងថា ខ្លួនតែងឃើញគេយកអ្នកទោសដឹកចេញទៅតាមរថយន្ត ហើយតាមប្រជាជនដឹងគឺថា អ្នកទោសដែលគេដឹកយកចេញទៅ គឺយកទៅសម្លាប់ចោលនៅជើងឯក[397]។

## សក្ខីកម្មមុនៗ

8. សាក្សីនេះបានផ្តល់ចម្លើយមុនមួយ តាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ លក ម៉េងស៊ាន ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 7 ខែកុម្ភៈ ឆ្នាំ2008 2008, D51/3, ERN 00164458-00164460 (ភាសាអង់គ្លេស), [ERN 00164456-00164457 (ភាសាខ្មែរ)]។

## ឯកសារពាក់ព័ន្ធដទៃទៀត

9. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយ នៅក្នុងចម្លើយរបស់សាក្សី។

# 20. ណាំ សុខា

## ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទងនឹងមន្ទីរ ស-២១ សាក្សីផ្តល់ភស្តុតាងអំពីការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខមួយនេះ *(20-42)* វចនាសម្ព័ន្ធសិទ្ធិអំណាច *(20-25)* ការធ្វើទារុណកម្ម និងការធ្វើបាបបែបអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])*, និងការសម្លាប់រង្គាល មនុស្សឃាត និងមនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់សាក្សីរូបនេះ ពាក់ព័ន្ធដល់បទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទស្រី ជនជាតិខ្មែរ កើតខ្ទង់ឆ្នាំ១៩៦០ មានអាយុប្រហែល១៥ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីធ្វើការជាអ្នកជញ្ជូនស្បៀង និងគ្រាប់ឱ្យកងទ័ពខ្មែរក្រហម ក្រុម៤១ តាំងនៅចន្លោះទន្លេមេគង្គ និងកោះអន្លង់ចិន។ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យបានក្តោបក្តាប់អំណាច សាក្សីបានត្រូវផ្ទេរទៅព្រៃស។ នៅទីនោះ ខ្លួនត្រូវបានអង្គការបញ្ជាឱ្យធ្វើស្រែ និងលើកទំនប់។ សាក្សីធ្វើការនៅព្រៃស រហូតដល់ថ្ងៃរបបអាវខ្មៅដួលរលំ។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

3. សាក្សីផ្តល់ភស្តុតាងថា ខ្លួនបានត្រូវយកមកលត់ដំ នៅព្រៃស ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ សាក្សីបញ្ជាក់ថាក្នុងមួយសប្តាហ៍ ជាទៀងទាត់ត្រូវប្រជុំម្តង។ ក្នុងអង្គប្រជុំ មនុស្សដែលគេយកមក លត់ដំត្រូវបានខ្មែរក្រហមជម្រុញឱ្យខំប្រឹងធ្វើការ ដើម្បីជៀសផុតពីការយកទៅប្រហារជីវិត[398]។ សាក្សីផ្តល់ភស្តុតាងថាបានស្គាល់មន្ទីរ ស-២១ មកពីមន្ទីរនេះជាកន្លែងសំខាន់មួយរបស់ខ្លួន[399]។

## វចនាសម្ព័ន្ធសិទ្ធិអំណាច

4. សាក្សីផ្តល់ភស្តុតាងថា ប្រធានកងរយ ឈ្មោះហ៊ុយ (ស្រែ) ជាប្រធានព្រៃស ជាអ្នកកាន់ក្តាប់កិច្ចការទូទៅ។ ហ៊ុយ (ស្រែ) មានសម្បុរខ្មៅ ខ្ពស់[400]។

## ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

5. សាក្សីផ្តល់ភស្តុតាងថា ខ្លួនបានឃើញខ្មែរក្រហមដាក់ខ្នោះស្ត្រីបីនាក់ រួចវាយដំពួកគេវាយទាល់តែលេចនោមដាក់ខោ ដើម្បីជាគម្រូដល់អ្នកឯទៀត កុំឱ្យយកតម្រាប់តាម[401]។ ម្តងនោះ ពេលសាក្សីចូលមកហ្វឹកហ្វឺនរៀនសូត្រនៅភ្នំពេញ ខ្លួនបានឮសម្រែកឈឺចាប់ ចេញពីរបងស័ង្កសី[402]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

6. សាក្សីផ្តល់ភស្តុតាងថា ស្ត្រីបីនាក់ដែលខ្មែរក្រហមបានវាយដំនោះ ត្រូវបានយកទៅ សម្លាប់ចោលនៅពេលយប់។ សាក្សីបញ្ជាក់ថារៀងរាល់យប់អ្នកទោសត្រូវបានដឹក តាមរថយន្តយកទៅសម្លាប់ មានទាំងប្រធានកងហា និងប្រធានក្រុមប្រហែលជាដប់នាក់ផង[403]។

## សក្ខីកម្មមុនៗ

7. សាក្សីបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ ណាំ សុខា ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី 18 ខែកក្កដា ឆ្នាំ2002, ថ្ងៃទី10 ខែកក្កដា ឆ្នាំ2002 និង ថ្ងៃទី26 ខែកុម្ភៈ ឆ្នាំ2003, D59, ឯកសារដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ 00017, ERN 00067908-00067914, 00067914-00067931, 00067932-000679956 (ភាសាខ្មែរ)។

## ឯកសារពាក់ព័ន្ធដទៃទៀត

8. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយ នៅក្នុងចម្លើយរបស់សាក្សី។

## 21. សោម ម៉ុន

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីផ្តល់ភស្តុតាងអំពីរចនាសម្ព័ន្ធ និងគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ទាក់ទងនឹងមន្ទីរ ស-២១ សាក្សីរូបនេះបានផ្តល់ភស្តុតាងអំពីតួនាទីជនត្រូវចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខនេះ *(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច *(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំខ្លួនខុសច្បាប់ កង្វះការជំនុំជម្រះក្តីដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឲ្យទៅជាទាសករ ការរងការឈឺចាប់ធ្ងន់ធ្ងរ ទង្វើអមនុស្សធម៌ *(62-71, 135, 143 & 148)*, ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបបែបអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល មនុស្សឃាត និងមនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់សាក្សីពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូន រឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមាន ប៉ុន្តែមិនមែនមានត្រឹមតែ អង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទស្រី ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៥០ មានអាយុប្រហែល២៥ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សីរៀនបានថ្នាក់ទី១០ រួចឈប់រៀនដើម្បីជួយឪពុកម្តាយធ្វើស្រែ។ សាក្សីបានចូលខ្មែរក្រហម ហើយបានត្រូវចាត់តាំងទៅនៅកងកសិកម្មនៅស្រុកព្រៃឈរ បន្ទាប់មកទៀតនៅកងវរៈសេនាតូច៣០៥ ភូមិភាគឧត្តរមានភារៈសែងអ្នករបួសក្នុងសមរភូមិកំពង់ស្ពឺ អំឡុងពេលវាយភ្នំពេញ។ ក្រោយបែកភ្នំពេញ នាងមាននាទីសម្អាតផ្ទះនៅភ្នំពេញ។ ប្រធានអង្គភាពឈ្មោះឡុញ បានឲ្យនាងរៀបការជាមួយឈ្មោះធឿន។ ក្រោយមកឈ្មោះធឿនជាប្តី ត្រូវបានចាប់ខ្លួន ដោយត្រូវបានចោទថាក្បត់ ហើយនៅខែ ឧសភា ឆ្នាំ ១៩៧៧[404] នាងបានត្រូវបញ្ជូនទៅព្រៃស កងពល ក១២ នៅទីនោះទល់ថ្ងៃរំដោះភ្នំពេញ។

### តួនាទីរបស់ជនជាប់ចោទ

3. សាក្សីបានផ្តល់ភស្តុតាងថាខ្លួនមិនស្គាល់ឈ្មោះប្រធានព្រៃសទេ ប៉ុន្តែបានឮប្រធានឈ្មោះសឿង ហៅ**ឌុច** ថាឮ[405]។ ជិតពេលវៀតណាមចូល និរសាររបស់**ឌុច** បានមកប្រាប់គេឯងឲ្យរត់ ភៀសខ្លួន ហើយបានជួបប្រពន្ធឌុច ឈ្មោះ ហេង ពេលរត់គេចវៀតណាម[406]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

4. សាក្សីផ្តល់ភស្តុតាងថា ខ្លួនបានត្រូវបញ្ជូនទៅនៅព្រៃស អង្គភាព ក១២ អស់ជិតបួនខែ។ ខ្លួនបានត្រូវផ្ទេរទៅព្រៃស រួមជាមួយស្ត្រីម្ភៃនាក់ផ្សេងទៀត និងកុមារមួយចំនួន តាមរថយន្ត[407]។ ឡានទាំងបីសុទ្ធតែផ្ទុកពេញទៅដោយស្ត្រី។ នាងគឺជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីដែលគេចោទថាក្បត់ ដែលប្តីត្រូវបានចាប់ខ្លួន[408]។ នាងរស់នៅកន្លែងផ្ទះដែលគេបោះបង់ចោល វាលស្រែព័ទ្ធជុំវិញខាងកើត អតីតគុកព្រៃស[409]។ សាក្សីនឹងធ្វើសក្ខីកម្មថាឈ្មោះ សឹង និងគ្រី ជាអ្នកដឹកនាំអង្គប្រជុំ បង្រៀនណែនាំដល់អង្គភាព[410]។

## រចនាសម្ព័ន្ធសិទ្ធិអំណាច

5. សាក្សីផ្តល់ភស្តុតាងថា ប្រធានអង្គភាពរបស់នាងឈ្មោះ សឿង អនុប្រធានឈ្មោះតៃគ្រី[411]។ នាងធ្លាប់ឮ ឈ្មោះ សឿង ហៅឌុច ថា"ពូ"[412]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

6. សាក្សីផ្តល់ភស្តុតាងថាក្នុងអង្គភាពរបស់នាងនៅព្រៃស មានមនុស្សប្រុសប្រហែលមួយរយនាក់ ស្រីមួយរយនាក់ ហើយក៏មានស្ត្រីចាស់ៗ និងកុមារទៀតផង[413]។ សាក្សីបញ្ជាក់ថាស្ត្រីត្រូវបាន បញ្ជូនទៅព្រៃសដោយសារក្បត់ ឬដោយសារប្តីត្រូវបានអង្គការចាប់ខ្លួន[414]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

7. សាក្សីផ្តល់ភស្តុតាងថាពួកគេធ្វើការពីព្រលឹម ទល់ព្រលប់ដល់ម៉ោង១០យប់។ មួយថ្ងៃឱ្យហូបពីរពេល ថ្ងៃត្រង់ និងពេលល្ងាច[415]។ បបរមួយវែកសម្រាប់មួយពេល ហើយបើមានបាយ បានមួយវែកគ្មានអ្វីបន្ថែមទេ។ មានកុមារបី ឬបួននាក់ស្លាប់ដោយអត់អាហារ និងទឹកដោះ[416]។

## ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

8. សាក្សីផ្តល់ភស្តុតាងថាតៃគ្រី បានវាយធំប្រំធាក់ អ្នកជម្ងឺដោយចោទថាខ្ជិល[417]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

9. សាក្សីផ្តល់ភស្តុតាងថា មានការបាត់ខ្លួនមនុស្សមួយចំនួន ក្នុងចំណោមមនុស្សទាំងម្ភៃនាក់ ដែលនៅអង្គភាព ក១២ នៅព្រៃស ជាមួយខ្លួន។ នាងបានឮថាអ្នកណាដែល ធ្វើការងារ ស្ពឹកទម្រន់យឺតយ៉ាវត្រូវបានចាត់ទុកថាជាខ្មាំង ឬជនក្បត់ ហើយពេលយប់ត្រូវដឹកតាមឡានយកទៅប្រហារជីវិត[418]។ កុមារបី ទៅបួននាក់ស្លាប់ដោយអត់អាហារ[419]។

## សក្ខីកម្មមុនៗ

10. សាក្សីនេះបានផ្តល់ចម្លើយមុនមួយ តាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ សោម ម៉ុន ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 15 ខែមករា ឆ្នាំ2008, D28/11, ERN 00163769-00163774 (ភាសាអង់គ្លេស)។

(2) បទសម្ភាសន៍របស់ សោម ម៉ុន ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី 13 ខែសីហា ឆ្នាំ2003, ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, ERN 00053936-0053961 (ភាសាខ្មែរ); អត្ថបទសង្ខេប ជាភាសាអង់គ្លេស (00184086-00184087)។

## ឯកសារពាក់ព័ន្ធដទៃទៀត

11. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយ នៅក្នុងចម្លើយរបស់សាក្សី។

# IV. គងការពារ ឬបុគ្គលិកស-២៤

## 22. ហាម សេង

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីផ្តល់ភស្តុតាងអំពីជម្លោះប្រដាប់អាវុធ*(16-18 & 144-145)* រចនាសម្ព័ន្ធ និងគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)* តួនាទីជនត្រូវចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខនេះ*(20-42)*និង រចនាសម្ព័ន្ធសិទ្ធិអំណាច *(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងដោយខុសច្បាប់ កង្វះ ការកាត់សេចក្តីដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឲ្យទៅជាទាសករ ការរងការឈឺចាប់ធ្ងន់ធ្ងរ ទង្វើអមនុស្សធម៌ *(62-71, 135, 143 & 148)*, និងការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់អ្នកជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ពាក់ព័ន្ធនឹងបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូន រឿងទៅជំនុំ ជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូច ដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទប្រុស ជនជាតិខ្មែរ កើតឆ្នាំ១៩៥៥ មានអាយុប្រហែល២០ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពោលគឺចាប់ពីឆ្នាំ១៩៧៣ បានចូលធ្វើទ័ព តែមិនមែនតាមការស្ម័គ្រចិត្តទេ។ សមាជិកទាំងអស់នៃសមាគមយុវជនឃុំ ត្រូវបានកោះហៅឲ្យហ្វឹកហ្វឺនរៀនសូត្រនយោបាយនៅស្រុកកោះធំ[420]។ សាក្សីបានឈប់ធ្វើទ័ពក្នុងឆ្នាំ១៩៧៤ ប៉ុន្តែត្រូវបានកេណ្ឌឲ្យចូលទ័ពវិញនៅខេត្តកំពត (មិនចាំខែឆ្នាំច្បាស់)។ ក្នុងឆ្នាំ១៩៧៥ សាក្សីបានមកដល់ភ្នំពេញ ក្រោយជម្លៀស។ ក្រោយមកត្រូវបានបញ្ជូនទៅកាន់ព្រៃស នៅទីនោះរហូតដល់ឆ្នាំ១៩៧៩។ ដំបូង សាក្សីស្ថិតក្នុងកងអង្គភាពបី បន្ទាប់មកទៀតបានត្រូវដំឡើងតួនាទីជាច្រើនដង រហូតចុងក្រោយក្នុងឆ្នាំ១៩៧៨ បានធ្វើជាប្រធានក្រុម។

### ជម្លោះប្រដាប់អាវុធ

3. សាក្សីផ្តល់ភស្តុតាងអំពីការដែលខ្លួនត្រូវបានបង្ខំឲ្យចូលកងទ័ពបដិវត្តន៍កម្ពុជាជាញយដង រួមទាំងការកេណ្ឌឲ្យចូលធ្វើទ័ពទាំងបង្ខំ ក្នុងឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤ និងក្នុងឆ្នាំ១៩៧៧ ពេលគាត់នៅព្រៃស។ កាលនៅព្រៃស គាត់ និងអ្នកទោសឯទៀតត្រូវបានខ្មែរក្រហមប្រមែប្រមូល បញ្ជូនទៅ

ច្បាំងវៀតណាម នៅព្រៃវែង និងស្វាយរៀង[421]។ គ្រូណែនាំក្នុងអង្គភាពរបស់គាត់ មានអំណាចសម្លាប់អ្នកណាដែលមិនគោរពបញ្ជា[422]។ សាក្សីផ្តល់ភស្តុតាងថា គាត់បានចូលហ្វឹកហ្វឺននយោបាយរបស់ឌុច និងសុន សេន ក្នុងនោះវៀតណាម និងថៃ ត្រូវបានចាត់ទុកថាជាសត្រូវខាងក្រៅ[423]។ សាក្សីអាចផ្តល់ភស្តុតាងអំពីការជម្លៀសមនុស្សជាប្រព័ន្ធចេញពីភ្នំពេញ។ ពេលខ្មែរក្រហមបញ្ជូនខ្លួនទៅភ្នំពេញ ឃើញថាភ្នំពេញគ្មានមនុស្សរស់នៅ[424]។

## រចនាសម្ព័ន្ធ និងគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ

4. ទាំងកាលនៅធ្វើទ័ព និងនៅព្រៃស សាក្សីបានចូលរៀនវគ្គហ្វឹកហ្វឺននយោបាយ ក្នុងនោះអ្នកចូលរួមទាំងអស់ត្រូវបានប្រាប់ឲ្យដឹងអំពី ភាពចាំបាច់នៃការចាប់ខ្លួនខ្មាំងផ្ទៃក្នុង និងខ្មាំងបរទេស[425]។

## តួនាទីរបស់ជនជាប់ចោទ

5. សាក្សីក្នុងនាមជាអ្នកជាប់ឃុំឃាំងនៅព្រៃស ផ្តល់ភស្តុតាងថា**ឌុច** មានសិទ្ធិអំណាចទូទៅនៅតំបន់នោះ ហើយកម្មាភិបាលឈានមុខនៅព្រៃស ឈ្មោះហ៊ុយ ជាអ្នកឆ្លើយទៅ**ឌុច**[426]។ ក្រោយពីត្រូវបានតែងតាំងជាប្រធានក្រុមនៅព្រៃស ក្នុងឆ្នាំ១៩៧៨ សាក្សីបានរៀនសូត្រនយោបាយ នៅមន្ទីរ ស-២១ ចំនួនមួយសប្តាហ៍នៅសាលាមួយក្នុងបរិវេណមន្ទីរ ស-២១ មានឌុចជាគ្រូណែនាំ[427]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

6. សាក្សីផ្តល់ភស្តុតាងថាខ្លួនបានជាប់ឃុំឃាំងនៅមន្ទីរកសាងព្រៃស ដែលជាសាខាមន្ទីរស២១ ពីឆ្នាំ ១៩៧៥ ដល់១៩៧៩[428]។ ពេលទៅដល់ព្រៃស ដំបូង សាក្សីនៅវត្តព្រែកឬស្សី(ខាងត្បូងតាខ្មៅ) ក្រោយមកត្រូវផ្ទេរទៅនៅបឹងជើងឯក និងបន្ទាប់មកទៀតត្រូវបានបញ្ជូនទៅនៅវត្តក្តុល។ នៅព្រៃស អ្នកជាប់ឃុំឃាំងមានបីក្រុម។ ក្រុមទីមួយ បានអាហារហូបចុកច្រើនជាងគេការងារស្រាល ដូចជាមើលគោជាដើម។ ក្រុមទីពីរ អាហារហូបចុកមធ្យម និងធ្វើការធ្ងររាស់។ ក្រុមទីបី ជាក្រុមត្រូវការ ការលត់ដំ អាហារហូបចុកតិចតួច ដាក់ខ្នោះពេលយប់ និងកាប់ឆ្ការ។ ដំបូងសាក្សីនៅ ក្នុង ក្រុមទីបី លើកទំនប់ ទប់ប្រឡាយ និងកាប់ឆ្ការ ប៉ុន្តែតមកទៀត ត្រូវបានចាត់តាំងឲ្យ ធ្វើការងារ ស្រាល ៗក្រោយពីក្លាយជាអ្នកធ្វើការគម្រូ។ សាក្សីផ្តល់ភស្តុតាងថាមានការប្រជុំតិះទៀនជាច្រើន ដែលក្នុងអង្គប្រជុំនោះកម្មាភិបាលត្រូវតិះទៀនខ្លួនឯង[429]។ សាក្សីបានចូលរៀននយោបាយ ខាងក្រៅរបងមន្ទីរ ស-២១[430]។

## វចនាសម្ព័ន្ធសិទ្ធិអំណាច

7. សាក្សីផ្តល់ភស្តុតាងថាឌុច ជាប្រធានមន្ទីរ ស-២១ និងព្រៃស ហើយថា ហ៊ុយជាអ្នកធំជាងគេនៅព្រៃស។ សាក្សីនឹងធ្វើសក្ខីកម្មថាឌុច ជាអ្នកបង្រៀនវគ្គរៀនសូត្រនយោបាយមួយអាទិត្យ ក្នុងនោះក៏មាន សុន សេនបង្រៀនដែរ[431]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

8. សាក្សីបញ្ជាក់ថាពេលខ្លួនមកដល់ព្រៃស មានកងហា បីកង និងអ្នកទោសស្ត្រីពីររយ ទៅបីរយនាក់[432]។

## ការធ្វើឲ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

9. សាក្សីផ្តល់ភស្តុតាងថាអ្នកនៅក្រុមទីបី ដែលគេចាត់ទុកថាត្រូវការ ការលត់ដំ បានអាហារហូបចុកតិចតួច និងត្រូវជាប់ខ្នោះនៅពេលយប់[433]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

10. សាក្សីផ្តល់ភស្តុតាងថាអ្នកជាប់ឃុំនៅព្រៃស ជាច្រើននាក់ ត្រូវបានបញ្ជូនទៅប្រហារជីវិតនៅឯមន្ទីរ ស-២១ [434]។

## សក្ខីកម្មមុនៗ

11. សាក្សីនេះបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ ហាម សេង ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី 14 ខែមីនា ឆ្នាំ2003, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, 19.43, ERN 00056885-00056920 (ភាសាខ្មែរ); អត្ថបទសង្ខេប ជាភាសាអង់គ្លេស (ERN 00184207-00184209)។

## ឯកសារពាក់ព័ន្ធដទៃទៀត

12. មិនមានឯកសារពាក់ព័ន្ធជាក់លាក់ផ្សេងទៀតដែលមាននិយាយយោងនៅក្នុងចម្លើយរបស់សាក្សីនេះឡើយ។

# V. អ្នកជាប់ឃុំឃាំងម-១៣

## 23. BIZOT FRANÇOIS

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីបានផ្តល់ភស្តុតាងអំពីតួនាទីជនត្រូវចោទនៅមន្ទីរ ស-២១ *(55-59, 90-99, 107-111 & 153 [ថ្មី]-161),* ជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* និងរចនាសម្ព័ន្ធ និងគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ភស្តុតាងរបស់គាត់ពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទប្រុស អាយុ៦៨ឆ្នាំ កើតនៅស្រុកបារាំង មានសញ្ជាតិបារាំង (ជនជាតិបារាំងពីកំណើត)។ សាក្សីបានមកសិក្សាពុទ្ធសាសនា និងធ្វើកិច្ចការសហគមន៍ ក្នុងតំបន់ខេត្តសៀមរាប ប្រទេសកម្ពុជា ដំបូងក្នុងឆ្នាំ១៩៦៥[435]។ អំឡុងពេលរៀនសូត្រនៅវត្តមួយ នៅឧត្តុង្គ ក្នុងខែតុលា ឆ្នាំ១៩៧១ ខ្មែរក្រហមបានចាប់ខ្លួន និងសហជីវិនខ្មែរពីររូបទៀត[436]។ សាក្សីត្រូវបានឃុំខ្លួន និងសួរចម្លើយបីខែនៅមន្ទីរ ម-១៣[437]។ តាមផ្លូវពីឧត្តុង្គ ទៅ ម-១៣ សាក្សីត្រូវបានសួរចម្លើយ និងចោទថាខ្លួន និងមិត្តជនជាតិខ្មែរពីរនាក់ទៀត ជាគិញសេអ៊ីអា រួចគេដាក់ខ្នោះ និងស្ថិតក្រោមការ ប្រហារជីវិត[438]។ អំឡុងជាប់ឃុំនៅមន្ទីរម-១៣ សាក្សីមានទំនាក់ទំនងជាមួយ **ឌុច** ទើប**ឌុច**ដោះលែងក្នុងចុងឆ្នាំ ១៩៧១[439]។មិត្តជនជាតិខ្មែររបស់គាត់ពីរនាក់នោះមិនត្រូវបានដោះលែងទេ ហើយក្រោយមកត្រូវបានសម្លាប់ចោលមិនដឹងថ្ងៃខែច្បាស់[440]។ សាក្សីបានជួបប្រទះដោយខ្លួនឯងផ្ទាល់ នូវជម្លោះប្រដាប់អាវុធដែលឆាបឆេះចូលមកដល់កម្ពុជាក្នុងដើមទសវត្សរ៍ឆ្នាំ៧០ រួមទាំងព័ត៌មានលម្អិត អំពីការឡោមព័ទ្ធ និងការចូលកាន់កាប់ទីក្រុងភ្នំពេញ របស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ក្នុងឆ្នាំ១៩៧៥។ ក្រោយថ្ងៃបែកភ្នំពេញ សាក្សីត្រូវបាននិរទេសចេញពីកម្ពុជា ឆ្លងចូលទឹកដីថៃ[441]។

### ជម្លោះប្រដាប់អាវុធ

3. សាក្សីអាចធ្វើសក្ខីកម្មចំពោះហេតុការណ៍នានាទាក់ទងនឹងជម្លោះប្រដាប់អាវុធនៅកម្ពុជាពីឆ្នាំ១៩៦៥ ទៅឆ្នាំ១៩៧៥ អំឡុងពេលសាក្សីកំពុងបំពេញការងារក្នុងទឹកដីខេត្តសៀមរាប។ ជាពិសេសសាក្សី

បានដឹងអំពីជម្លោះប្រដាប់អាវុធ ជុំវិញការបែកភ្នំពេញឆ្នាំ១៩៧៥ (សម្រាប់ចេតនាប្រវត្តិសាស្ត្រ មិនមែនសម្រាប់យុត្តាធិការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ)។

## វចនាសម្ព័ន្ធ និងគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ

4. សាក្សីបានជួបឌុច ខណៈពេលឌុច នៅក្នុងគុក ហើយបានដឹងអំពីព្រឹត្តិការណ៍ ជុំវិញការដោះលែងសាក្សីពីមន្ទីរ ម-១៣។ ក្រោយពីសួរចម្លើយរួច ឌុច បានធ្វើរបាយការណ៍សន្និដ្ឋានថា សាក្សីមិនមែនជាគិញសេអ៊ីអា ទេ និងគួរត្រូវបានដោះលែង[442]។ ចៅហ្វាយឌុច ឈ្មោះតា ម៉ុក និងវន វ៉េត ពុំឯកភាពទៅលើការសន្និដ្ឋានរបស់ឌុចទេ ពីព្រោះតាមគោលនយោបាយកម្ពុជា ប្រជាធិបតេយ្យឆ្នាំ១៩៧១បានកំណត់ថាពេលអ្នកទោសណាម្នាក់ត្រូវបានគេធ្វើរបាយការណ៍រួចរាល់ អ្នកទោសនោះឯងនឹងត្រូវគេកម្ទេចចោល។ ដូច្នេះតាម៉ុក បានបញ្ជាឱ្យគេសម្លាប់សាក្សី[443]។ ឌុច បានបញ្ចុះបញ្ចូល វន វ៉េត ប្រាប់ថាសាក្សីគ្មានកំហុសទេ ហើយការប្រហារជីវិតសាក្សីត្រូវបានលើកពេល ដើម្បីទុកឱ្យប៉ុល ពតជាអ្នកដោះស្រាយ[444]។ អំឡុងពេលរង់ចាំការសម្រេចពីប៉ុល ពត តាម៉ុក បានបញ្ជាឱ្យប្រហារជីវិតសាក្សីម្តងទៀត ប៉ុន្តែឌុច និងវន វ៉េត ពុំព្រមធ្វើតាម[445]។ ប៉ុល ពតឯក ភាពតាមសំណើរបស់ឌុច ក្នុងការដោះលែងសាក្សី ប៉ុន្តែតា ម៉ុក នៅតែបន្តបញ្ចុះបញ្ចូល ឌុច វន វ៉េតឱ្យសម្លាប់សាក្សីចោល។ ទោះយ៉ាងណាអ្នកទាំងពីរប្រកែក ហើយទីបំផុតទៅសាក្សីត្រូវបានដោះ លែងឱ្យមានសេរីភាពវិញ[446]។

## តួនាទីរបស់ជនជាប់ចោទ

5. សាក្សីបញ្ជាក់ថាឌុច ជាប្រធានមន្ទីរ ម-១៣[447]។ សាក្សីជឿជាក់ថាឌុច កាន់កាប់មន្ទីរ ម-១៣ ទាំងស្រុងប៉ុន្តែឌុចគ្មានសិទ្ធិសម្រេចថាអ្នកទោសណាត្រូវសម្លាប់ ឬត្រូវទុកជីវិតនោះទេ[448]។ ពេលអ្នកទោសមកដល់មន្ទីរ ម-១៣ គឺថ្នាក់លើសម្រេចរួចហើយថាអ្នកទោសនោះនឹងត្រូវកម្ទេចចោល ហើយការដោះលែងសាក្សីរូបនេះក៏ព្រោះតែមកពីរបាយការណ៍របស់ឌុចស្នើសុំឱ្យដោះលែងតែប៉ុណ្ណោះ[449]។ សាក្សីអះអាងថានៅមន្ទីរ ម-១៣ ឌុច ឬអ្នកផ្សេងមិនដែលធ្វើទារុណកម្ម ឬធ្វើបាបខ្លួននោះទេ ហើយខ្លួនក៏មិនដែលធ្លាប់បានឃើញឌុច ឬបុគ្គលិកណាមួយនៃមន្ទីរ ម-១៣ វាយធ្វើបាបអ្នកទោស ណាម្នាក់ដែរ។ ប៉ុន្តែឌុច ធ្លាប់បានប្រាប់សាក្សីថាឌុច វាយដំធ្វើបាបអ្នកទោសពេលសួរចម្លើយ ហើយសាក្សីខ្លួនឯងផ្ទាល់ក៏មានជំនឿថាការធ្វើបាប ការធ្វើទារុណកម្មអ្នកទោស ពិតជាមាននៅមន្ទីរ ម-១៣នេះពិតមែន[450]។ តួនាទីរបស់ឌុច ក្នុងការប្រហារជីវិតអ្នកទោសនៅមន្ទីរ ម-១៣ ត្រូវបានបញ្ជាក់ឱ្យឃើញច្បាស់នៅពេល សាក្សីធ្វើដំណើរមកមើលមន្ទីរ ម-១៣ មានគេប្រាប់សាក្សី ថាសាក្សីគឺជាមនុស្សតែម្នាក់គត់ដែលគេចផុតពីស្លាប់នៅមន្ទីរម-១៣[451]។

## សក្ខីកម្មមុនៗ

6. សាក្សីនេះបានផ្តល់ចម្លើយមុនពីរ តាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ Francois BIZOT ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 22 ខែមករា ឆ្នាំ2008 នៅ ERN 00160496, D/40, ERN 00160491-00160497 (ភាសាអង់គ្លេស);

(2) បទសម្ភាសន៍របស់ Francois BIZOT ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 22 ខែមករា ឆ្នាំ2008 ERN 00233535-00233538, D/68 (ភាសាអង់គ្លេស);

(3) ARTE "Pol Pot et les Khmers Rouges," V00172512 at 00:49:18 to 00:50:04 (ភាសាបារាំង)។

## ឯកសារពាក់ព័ន្ធដទៃទៀត

7. មានឯកសារពាក់ព័ន្ធជាក់លាក់ផ្សេងទៀតចំនួនពីរ ដែលមានយោងនៅក្នុងចម្លើយសាក្សី។

(1) កម្មវិធីនយោបាយរបស់រណសិរ្សសាមគ្គីជាតិកម្ពុជា(មិនដឹងប្រភព);

(2) "Le Portail" (The Gate) by Francois Bizot, ចុះថ្ងៃទី... ឆ្នាំ2000។

# VI. កន្លែងកើតហេតុនៅមន្ទីរ ស-២១

## 24. LESIC ZORAN

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីផ្តល់ភស្តុតាងអំពីការបង្កើត ថេរៈវេលា និងប្រតិបត្តិការនៃមន្ទីរសន្តិសុខមួយនេះ*(20-42)* រចនាសម្ព័ន្ធសិទ្ធិអំណាច *(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំខ្លួនដោយខុសច្បាប់ កង្វះការកាត់សេចក្តីដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឱ្យទៅជាទាសករ ការរងការឈឺចាប់ធ្ងន់ធ្ងរ ទង្វើអមនុស្សធម៌ *(62-71, 135, 143 & 148)* និងការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបបែបអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល មនុស្សឃាត និងមនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងសាក្សីពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូន រឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមានប៉ុន្តែមិនមែនមានត្រឹមតែ អង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីគឺជាអ្នកជំនាញសោតទស្សន៍ និងជាអ្នកថតរូបបែបស៊ើបអង្កេត មានបទពិសោធន៍ទូលំទូលាយក្នុងវិស័យសំណុំរឿងព្រហ្មទណ្ឌអន្តរជាតិ។ ចាប់តាំងពីឆ្នាំ១៩៩៧មក គាត់បានរៀបចំបទបង្ហាញសោតទស្សន៍ នៅឯសាលាក្តីព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី (ICTY) នូវសំណុំរឿងព្រហ្មទណ្ឌអន្តរជាតិដូចខាងក្រោម (ការងារពាក់ព័ន្ធរបស់គាត់ ត្រូវបានរៀបរាប់ក្នុងរឿងក្តីរបស់ *Galić* និង *Limaj*):

- Sarajevo I - ការបាញ់ចេញពីកន្លែងលាក់ខ្លួន និង ការបាញ់ផ្លោង (*Galić*, IT-98-29)
- Lapusnik – ពន្ធនាគារ និង ទីចាត់ការ (*Limaj et al.*, IT-03-66)
- Stupni Do – កន្លែងកើតហេតុ និង ការចុះទៅពិនិត្យដល់កន្លែងកើតហេតុ (*Rajić*, IT-95-12)
- Mostar – ការបាញ់ចេញពីកន្លែងលាក់ខ្លួន (*Prlić et al.*, IT-04-74)
- Scorpions Killing Video – ការចុះពិនិត្យដល់កន្លែងកើតហេតុ និង ការពិនិត្យបញ្ជាក់ (*Milosević*, IT-02-54)
- Ljuboten – ការចុះពិនិត្យដល់កន្លែងកើតហេតុ (*Boskoski and Tarculovski*, IT-04-82)
- Sarajevo II - ការបាញ់ចេញពីកន្លែងលាក់ខ្លួន និង ការបាញ់ផ្លោង (*Milosević*, IT-98-29/1)

- Srebrenica – Petrovic Video (*Krstic*, IT-98-33 "Srebrenica-Drina Corps")
- Kninska Krajina – (*Gotovina*, IT-01-45 "Operation Storm")
- Lake Radonjic – **កន្លែងកើតហេតុនិងពន្ធនាគារ** (*Haradinaj et al.*, IT-04-84)

## ទិដ្ឋភាពទូទៅនៃភស្តុតាង

3. សាក្សីត្រូវបានសហចៅក្រមស៊ើបអង្កេតតែងតាំងធ្វើជាអ្នកជំនាញការ អនុលោមទៅតាមវិធាន៣១ នៃវិធានផ្ទៃក្នុង។ ដីកាចាត់អ្នកជំនាញទាក់ទងនឹងការងាររបស់គាត់ បង្ហាញថាគាត់នឹង "ផ្តល់បទបង្ហាញរូបថតឌីជីថលមួយស្តីពីតំបន់ទួលស្លែង និងជើងឯក ព្រមទាំងផែនទី និងរូបថតឌីជីថល នៃកន្លែងនានាជុំ វិញតំបន់ទាំងពីររាប់ទាំងផ្លូវទៅមកនៃតំបន់ទាំងពីរផង"[452]។ បទបង្ហាញនេះនឹងជួយបង្កើតឲ្យមានរចនាសម្ព័ន្ធរូប នៃមន្ទីរសន្តិសុខ ស-២១ និងជើងឯក។ វានឹងអនុញ្ញាតឲ្យចៅក្រមមើលឃើញនូវអគារផ្សេងៗ កន្លែងរបស់ឧុចក្នុងមន្ទីរនោះ កន្លែងសម្លាប់មនុស្សរួមទាំងបន្ទប់សួរចម្លើយនិងធ្វើទារុណកម្ម។ វានឹងផ្តល់ភស្តុតាងអំពីល័ក្ខខណ្ឌរស់នៅនៃអ្នកជាប់ឃុំឃាំង និងអនុញ្ញាតឲ្យសាក្សីកំណត់តំបន់សំខាន់ៗ។ លោក Lesic បានអមដំណើរសហចៅក្រមស៊ើបអង្កេតទៅកាន់មន្ទីរ ស-២១ និងជើងឯកអំឡុងពេលមានការចង្អុលបង្ហាញហេតុការណ៍ឡើងវិញ នៅថ្ងៃទី ២៦-២៧ ខែកុម្ភៈឆ្នាំ២០០៨ ហើយបានដាក់របាយការណ៍ជូន នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០០៨[453]។

## 25. ប៉ែន អេន

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទិននឹងមន្ទីរ ស-២១ សាក្សីផ្តល់ភស្តុតាងអំពីការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំខ្លួនដោយខុសច្បាប់ កង្វះការកាត់សេចក្តីដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឲ្យទៅជាទាសករ ការទទួលរងការឈឺចាប់ធ្ងន់ធ្ងរ ទង្វើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់អ្នកជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់នាងពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទស្រីជនជាតិខ្មែរ បានចាកចេញពីកម្ពុជាពេលទាហានវៀតណាមចូល ហើយត្រឡប់មកវិញ ក្រោយថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។ ក្នុងឆ្នាំ១៩៧៩ សាក្សីមានអាយុ៣៥ឆ្នាំ ធ្វើការជាអ្នកនាំភ្ញៀវ និងអ្នកបកប្រែនៅសារមន្ទីរទួលស្លែង[454]។

### ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

3. សាក្សីផ្តល់ភស្តុតាងថាក្នុងឆ្នាំ១៩៧៩ ខ្លួនបានប្រទះឃើញលិខិតឆ្លងដែនជាច្រើន ដែលខ្លួន "គិតថាជាលិខិតឆ្លងដែនរបស់អ្នកទោសខ្មែរជំនាន់លន់ នុល និងសីហនុ" ក្នុងផ្ទះមួយ នៅផ្លូវ៣៥០ ខាងលិចល្វូទឹកស្អុយនិងខាងកើតសារមន្ទីរទួលស្លែង[455]។ សាក្សីផ្តល់ភស្តុតាងថាខ្លួន បានឲ្យកូនអ្នកទោសទាំងនោះស្នាក់នៅក្នុងផ្ទះរបស់ខ្លួន។ កុមារទាំងនោះបីនាក់មានអាយុពីប្រាំពីរទៅប្រាំបីឆ្នាំ និងម្នាក់ទៀតអាយុបួនឆ្នាំ[456]។

### ការធ្វើឲ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

4. សាក្សីផ្តល់ភស្តុតាងថាពេលខ្លួនមកដល់មន្ទីរ ស-២១ ស្រុកខ្មែរឆ្នាំ១៩៧៩ បានឃើញខ្នោះ កន្ទេល រូបថត ខ្សែព្លួរ និងពាងទឹកធំមួយ[457]។ នៅកណ្តាលអគារមន្ទីរ ស-២១ សាក្សីបានឃើញស្នាមឈាមដែលគេសម្អាតនៅសល់ខ្លះៗ[458]។ សាក្សីក៏បានឃើញឈាមកក សក់ក្បាលមនុស្ស និងធ្មេញក្នុងអគារ ក[459]។ ក្នុងអគារមួយទៀត សាក្សីបានឃើញកេះគ្រាប់ និងច្រវាក់[460]។

## ការសួរចម្លើយ

5. សាក្សីផ្តល់ភស្តុតាងថានៅ មន្ទីរស-២១ នាងបានឃើញនៅក្តារខៀនមានសរសេរវិធីសួរចម្លើយអ្នកទោស។ អ្នកទោសមន្ទីរ ស-២១ដែលនៅរស់ អះអាងថាសំណេរនៅលើក្តាខៀន មិនមែនជារបស់ពួកគេទេ ប៉ុន្តែវាប្រហែលជារបស់ពួកខ្មែរក្រហម[461]។

## ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

6. សាក្សីផ្តល់ភស្តុតាងថាខាងក្នុងមន្ទីរ ស-២១ មានខ្នោះ ពូថៅ ដំបង និង "របស់ដែលគិតថាជាឧបករណ៍ធ្វើទារុណកម្ម"[462]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

7. សាក្សីផ្តល់ភស្តុតាងថាមានរណ្តៅជាច្រើននៅខាងឆ្វេងច្រកផ្លូវចូល ពីមុនគ្រាន់តែជាដំបូកធម្មតា។ សាក្សីជឿជាក់រណ្តៅទាំងនេះតំណាងឱ្យ"អ្នកចុងក្រោយដែលបានស្លាប់នៅទីនោះ"[463]។ សាក្សីផ្តល់ភស្តុតាងថា លលាដ៍ក្បាលត្រូវបានជីកយកមកពីគុំទូលស្លែង ប៉ុន្តែត្រូវគេបទុកចោលពីព្រោះមានសាច់ជាច្រើនជាប់នឹងលលាដ៍ក្បាលទាំងនោះ[464]។ សាក្សីផ្តល់ភស្តុតាងថានៅភាគនិរតី នៃសារមន្ទីរក្បែរផ្ទះស៊ីផល សាក្សីបានប្រទះឃើញសាកសពមនុស្សចំនួនប្រហែលម្ភៃនាក់ ម្នាក់ស្លៀកខោខ្លីនីឡុង និងមានសាកសពមនុស្សប្រាំពីរនាក់ទៀត នៅប្រមាណដប់ម៉ែត្រពីផ្ទះ[465]។

## សក្ខីកម្មមុនៗ

8. សាក្សីនេះបានផ្តល់ចម្លើយមុន មួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ ប៉ែន អេន ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ 2008, D49/12, ERN 00186520-00186523 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

9. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយនៅក្នុងចម្លើយសាក្សី។

# VII. អ្នកតាំងលំនៅនៅមន្ទីរ ស-២១

## 26. អាយ ស៊ីមលី

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីផ្តល់ភស្តុតាងអំពីការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់ អ្នកជាប់ឃុំឃាំងដោយខុសច្បាប់ *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់នាងពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទស្រី ជនជាតិខ្មែរ កើតនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៥៥[466]។ នាងផ្តល់ភស្តុតាងថា ក្រោយខ្មែរក្រហមក្តោបក្តាប់អំណាចឆ្នាំ១៩៧៥ នាងបានធ្វើដំណើរចាកចេញពីផ្ទះ នៅផ្លូវ២៧៦ ទួលស្លែង ក្រុងភ្នំពេញហើយវិលត្រឡប់វិញក្នុងឆ្នាំ១៩៨០-១៩៨១[467]។ នាងផ្តល់ភស្តុតាងអំពីអ្វីដែលនាងបានឃើញម្តុំទួលស្លែងអំឡុងពេលនាងត្រឡប់មកភ្នំពេញវិញ ជាពិសេសភស្តុតាងអំពីរណ្តៅសាក សពរួម និងសាកសព។

### ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

3. សាក្សីផ្តល់ភស្តុតាងថានៅក្នុងរណ្តៅមួយក្បែរផ្ទះលេខ២៨ CE1 ផ្លូវ២៧៦ សង្កាត់អូឡាំពិក ខណ្ឌចម្ការមន ក្រុងភ្នំពេញ នាងបានឃើញឧបករណ៍មួយចំនួន ដែលនាង "បានគិតថាជាឧបករណ៍ធ្វើទារុណកម្ម" រួមមានទាំងពួចៅដៃ និងប្រដាប់ដកក្រចកផង[468]។

### ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

4. សាក្សីផ្តល់ភស្តុតាងថានៅមិនឆ្ងាយពីផ្ទះឪពុកម្តាយនាងនៅផ្លូវ២៧៦ មានរណ្តៅសាកសពរួមមួយមានផ្ទៃក្រឡាពីរម៉ែត្រការេ។ សាក្សីផ្តល់ភស្តុតាងថា មានមនុស្សមួយចំនួនបានមកពិនិត្យឆ្អឹងទាំង នោះហើយពួកគេគិតថាឆ្អឹងដែលនៅសេសសល់ ជារបស់ជនបរទេស[469]។ សាក្សីនឹងធ្វើសក្ខីកម្មថា នាងបានឃើញសាកសពមនុស្សចំនួនជាងដប់នាក់។ លលាដ៍ក្បាលខ្លះមានក្រណាត់ខ្មៅចងមុខ[470]។ មានតែឆ្អឹងប៉ុណ្ណោះដែលនៅសេសសល់ គ្មានសាច់នៅសេសសល់ទេ ប៉ុន្តែមានសាកសពមួយមាន សក់វែង

ដែលសាក្សីជឿថាជាស្ត្រី[471]។ សាក្សីនឹងធ្វើសក្ខីកម្មថា នៅខាងត្បូងផ្ទះនាង នាងបានប្រទះឃើញរណ្តៅសាកសពរួមមួយទៀតដែលមានជម្រៅពីពីរ ទៅបីម៉ែត្រ[472]។ នាងមិនបានដឹងថា ក្នុងរណ្តៅនោះមានសាកសពមនុស្សប៉ុន្មាននាក់ទេ[473]។

## សក្ខីកម្មមុនៗ

5. សាក្សីនេះបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ អាយ ស៊ីមីលី ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី11 ខែកុម្ភៈ ឆ្នាំ 2008, D49/7, ERN 00186495-00186496 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

6. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយ នៅក្នុងចម្លើយរបស់សាក្សី។

## 27. ជេត សុខា

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទិននឹង មន្ទីរស-២១ សាក្សីផ្តល់ភស្តុតាងអំពីការធ្វើឲ្យទៅជាទាសករ ការរងការឈឺចាប់ធ្ងន់ធ្ងរ ទង្វើអមនុស្សធម៌ *(62-71, 135, 143 & 148)* និងការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់អ្នកជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140 & 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ពាក់ព័ន្ធនឹងបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាង ដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះ ទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទស្រី ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៤៨។ សាក្សីផ្តល់ភស្តុតាងថាខ្លួន បានវិលត្រឡប់មកផ្ទះខ្លួនលេខ ២ E0 ផ្លូវ៣៦០ ភ្នំពេញ ក្បែរទួលស្លែង ជាលើកដំបូងក្នុងឆ្នាំ១៩៨០[474]។ នាងផ្តល់ភស្តុតាងអំពីអ្វីដែលខ្លួនបានឃើញម្តុំតំបន់ទួលស្លែង អំឡុងត្រឡប់មកលំនៅដ្ឋានវិញ ជាពិសេសខ្នោះដៃ ខ្នោះជើង និងគ្រាប់កាំភ្លើង។

3. សាក្សីផ្តល់ភស្តុតាងថា ពេលខ្លួនមកដល់ផ្ទះក្នុងឆ្នាំ១៩៨០ គ្មាននរណារស់នៅទីនោះមុននេះទេ[475]។ នាងបានផ្តល់ភស្តុតាងថាបានឃើញខ្នោះដៃ ខ្នោះជើងជាច្រើន[476]។

### ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

4. សាក្សីផ្តល់ភស្តុតាងថា ខ្លួនបានឃើញកេសគ្រាប់ សំបកគ្រាប់ និងច្រវាក់ក្នុងផ្ទះនោះ[477]។ នាងនឹងធ្វើសក្ខីកម្មថានៅក្នុងផ្ទះនោះមានរណ្តៅ[478]។ ហើយនាងបានចាក់ដីសង់ផ្ទះ [479]។ ប៉ុន្តែពុំបានប្រទះឃើញអ្វីនៅក្នុងរណ្តៅនោះទេ[480]។

### សក្ខីកម្មមុនៗ

5. សាក្សីនេះបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា
   (1) បទសម្ភាសន៍របស់ ជេត សុខា ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ2008, D49/9, ERN 00186506-00186507 (ភាសាអង់គ្លេស)។

### ឯកសារពាក់ព័ន្ធដទៃទៀត

6. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយនៅក្នុងចម្លើយសាក្សី។

## 28. ឆាយ ស្រៀវ

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទិននឹងមន្ទីរ ស-២១ សាក្សីផ្ដល់ភស្តុតាងអំពីការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់អ្នកជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ពាក់ព័ន្ធនឹងបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្ដល់ដោយសាក្សីរូបនេះរួមមានប៉ុន្តែ មិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទប្រុស ជនជាតិខ្មែរ កើតឆ្នាំ១៩៥០ និងជាកម្មករសំណង់[481]។ គាត់ផ្ដល់ភស្តុតាងអំពីអ្វី ដែលគាត់បានឃើញក្បែរផ្ទះគាត់នៅម្ដុំទួលស្លែង ជាពិសេសភស្តុតាងនៃរណ្ដៅសាកសពរួម និងសាកសពមនុស្ស។

### ការធ្វើឱ្យទៅជាទាសករ ការបង្ខាំងការឃើចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

3. សាក្សីផ្ដល់ភស្តុតាងថាក្នុងឆ្នាំ១៩៨២ គាត់បានចូលទៅនៅដីមួយកន្លែង ខាងកើតផ្ទះសាក្សីឈ្មោះ ទេស សំបុន ចំនួន ពីរច្រក[482]។ សាក្សីផ្ដល់ភស្តុតាងថាពេលកំពុងជីកដីដាំចេក គាត់ក៏បានធុំក្លិនស្អុយ ហើយជីកឃើញអាវពណ៌ក្រហមក្រមៅ[483]។ គាត់ជីកបន្តរួចបានប្រទះ ឃើញសាកសពដែលត្រូវគេកប់ចោលមិនដឹងចំនួនប៉ុន្មាននាក់[484]។ សាក្សីក៏បានធុំក្លិនស្អុយភាយចេញ ពីម្ដុំដីទំហំក្បាល១៧ម៉ែត្រ ជម្រៅ៣០ម៉ែត្រ ខាងមុខផ្ទះគាត់[485]។ មានរណ្ដៅមួយទៀតជម្រៅប្រ ហែលពី១៥ ទៅ២០ម៉ែត្រ ដែលបានជះក្លិនមកក្រៅ ទោះជាយ៉ាងណាអ្នកមកទើបមកនៅថ្មីបាន សាងសង់ផ្ទះនៅលើដីនោះ[486]។ សាក្សីនិយាយថា រណ្ដៅសាកសពមាន ចាប់ពីខាងលិចទួលស្លែងរហូតដល់ផ្លូវ១៦៣[487]។

### សក្ខីកម្មមុនៗ

4. សាក្សីនេះបានផ្ដល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

   (1) បទសម្ភាសន៍របស់ ឆាយ ស្រៀវ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 18 ខែកញ្ញា ឆ្នាំ2007, D49/1, ERN 00186449-00186451 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

5. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយ នៅក្នុងចម្លើយសាក្សី។

## 29. មុំ ទៃ

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីផ្តល់ភស្តុតាងអំពីការធ្វើឱ្យទៅជាទាសករ ការរងការឈឺចាប់ធ្ងន់ធ្ងរ និងទង្វើអមនុស្សធម៌ *(62-71, 135, 143 & 148)* នៅមន្ទីរ ស-២១។ ភស្តុតាងរបស់នាងពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទស្រី ជនជាតិខ្មែរ កើតថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩៥២[488]។ ក្នុងឆ្នាំ១៩៨២ នាងបានចូលទៅនៅផ្ទះដែលនាងកំពុងស្នាក់នៅបច្ចុប្បន្ន លេខ៦៤ ផ្លូវ១១៣ សង្កាត់បឹងកេងកង៣ ខណ្ឌចម្ការមន ក្រុងភ្នំពេញ។ ផ្ទះនេះត្រូវបានសារមន្ទីរទួលស្លែងប្រគល់ឱ្យនាង ក្នុងនាមនាងជាបុគ្គលិកសារមន្ទីរ[489]។

### ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

3. សាក្សីផ្តល់ភស្តុតាងថានាងធ្លាប់ត្រូវបានអតីតអ្នកទោសមន្ទីរ ស-២១ ឈ្មោះវ៉ាន់ ណាត អ៊ឹង ប៉ិច និងប៊ូ ម៉េង ប្រាប់ថាផ្ទះនេះកាលពីដើមជាកន្លែងសួរចម្លើយ[490]។ ពេលនាងមកចូលស្នាក់នៅក្នុង ឆ្នាំ១៩៨២ សាក្សីបានឃើញក្រណាត់តូចវែង សំពត់ចម្រុះពណ៌ខាងក្រោមផ្ទះ[491]។ នាងបញ្ជាក់ថាពេលនោះអ្វីៗដែលនៅក្នុងផ្ទះ ត្រូវបានរៀបចំយកទៅតម្កល់ទុកនៅឯសារមន្ទីរទួលស្លែង[492]។

### សក្ខីកម្មមុនៗ

4. សាក្សីនេះបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ មុំ ទៃ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ2008, D49/10, ERN 00186510-00186511 (ភាសាអង់គ្លេស)។

### ឯកសារពាក់ព័ន្ធដទៃទៀត

5. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយនៅក្នុងចម្លើយសាក្សី។

## 30. ង៉ែត ប៊ុនថា

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទិននឹងមន្ទីរ ស-២១ សាក្សីផ្តល់ភស្តុតាងអំពីការបង្កើត ការរងការឈឺចាប់ធ្ងន់ធ្ងរ ទង្វើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងមនុស្សដោយខុសច្បាប់ កង្វះការកាត់សេចក្តីដោយយុត្តិធម៌*(47-54, 60-61, 134, 146, 147)* និងការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់អ្នកជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីអាយុ២០ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជនជាតិខ្មែរ កើតឆ្នាំ១៩៥៥ មិនចាំថ្ងៃខែច្បាស់[493]។ បច្ចុប្បន្នជាមន្ត្រីរាជការ[494]។ គាត់បានចូលមកស្នាក់នៅផ្ទះបច្ចុប្បន្ន ក្នុងឆ្នាំ១៩៨០[495]។ ផ្ទះលេខ២០T ផ្លូវ៣៤៨ ភ្នំពេញ[496]។ គាត់បានឃើញរបងលួសបន្លាជុំវិញបរិវេណផ្លូវ១១៣ និង៣១០[497]។ ក្នុងឆ្នាំ ១៩៨៤ ពេលកំពុងជីកដីចាក់គ្រឹះផ្ទះ គាត់បានប្រទះឃើញសាកសពមនុស្សចំនួន៣៦នាក់ ដែលជាប់ចំណង[498] រួមទាំងរបស់របរប្រើប្រាស់ផ្ទាល់ខ្លួនក្នុងរណ្តៅក្បែរផ្ទះគាត់[499]។

### ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

3. សាក្សីផ្តល់ភស្តុតាងថាក្នុងឆ្នាំ១៩៨៤ គាត់បានប្រទះឃើញ សាកសពមនុស្សចំនួន៣៦នាក់ ដែលជាប់ចំណង[500] ក្នុងរណ្តៅមួយក្បែរផ្ទះ[501]។ ក្រៅពីមានសាកសពមនុស្ស ក្នុងរណ្តៅនោះក៏មាន ខ្សែនីឡុង ខ្សែពួរ ក្រណាត់ ខ្នោះជើង ក្រណាត់ចងមុខ ស្បង់លោក ខោអាវខ្មៅ ក្រណាត់ម៉ុងតេហ្គុយ សម្លៀកបំពាក់ចម្រុះពណ៌ ឯកសណ្ឋានកងទ័ព បំណែកលលាដ៍ក្បាល និងលលាដ៍ក្បាលប្រេះ[502]។

### ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

4. សាក្សីផ្តល់ភស្តុតាងថាពេលត្រឡប់មកដល់ផ្ទះវិញក្នុងឆ្នាំ១៩៨០ អ្នករស់នៅទីនោះមុនៗ បានប្រាប់គាត់អំពីសាកសពមនុស្សចំនួន៣នាក់ដែលគេបានប្រទះឃើញនៅក្នុងបរិវេណផ្ទះ[503]។ គាត់ក៏បានឃើញរបងលួសបន្លាជុំវិញបរិវេណផ្លូវ១១៣ និងផ្លូវ៣១០[504]។ របងនោះកាត់ផ្លូវ៣៥០ ទៅទិសខាងកើត ហើយបត់ទៅទិសខាងជើង កាត់ផ្លូវថ្មើរជើងមួយ ឆ្ពោះទៅផ្លូវ៣២០[505]។

5. សាក្សីផ្ដល់ភស្ដុតាងថាក្នុងឆ្នាំ១៩៩៤ គាត់បានប្រទះឃើញសាកសពមនុស្សចំនួន៣៦នាក់ ដែលជាប់ចំណង[506] ក្នុងរណ្ដៅមួយក្បែរផ្ទះ[507]។ ក្រៅពីនោះ ក៏បានប្រទះឃើញខ្សែនីឡុង ខ្សែពួរ ក្រណាត់ ខ្នោះជើង ក្រណាត់ចងមុខ ស្បង់លោក ខោអាវខ្មៅ ក្រណាត់ម៉ុងតេហ្គុយ ខោអាវចម្រុះពណ៌ ឯកសណ្ឋានកងទ័ព បំណែកលលាដ៍ក្បាល និងលលាដ៍ក្បាលប្រេះ[508]។ ឆ្អឹងខ្មោចក្នុងរណ្ដៅនោះ មិនមានរបៀបរៀបរយទេ ហើយសាកសពត្រូវបានទម្លាក់គរលើគ្នា[509]។អ្នកជិតខាងក៏បានប្រទះឃើញសាកសពមនុស្សប្រាំមួយនាក់នៅក្បែរនោះដែរ[510]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

6. សាក្សីផ្ដល់ភស្ដុតាងថាគ្រាត្រឡប់មករស់នៅផ្ទះខ្លួនក្នុងឆ្នាំ១៩៨០ អ្នករស់នៅទីនោះមុនៗ បានប្រាប់គាត់អំពីសាក្សីមនុស្សបីនាក់ដែលគេបានប្រទះឃើញក្នុងបរិវេណផ្ទះ[511]។ ក្នុងឆ្នាំ១៩៩៤ គាត់បានប្រទះឃើញសាកសពមនុស្សចំនួន៣៦នាក់ ដែលជាប់ចំណង[512] ក្នុងរណ្ដៅមួយក្បែរផ្ទះ[513]។ នៅក្នុងរណ្ដៅគាត់ក៏បានប្រទះឃើញផងដែរនូវខ្សែនីឡុង ខ្សែពួរ ក្រណាត់ ខ្នោះជើង ក្រណាត់រុំមុខ ស្បង់លោក ខោអាវខ្មៅ ក្រណាត់ម៉ុងតេហ្គុយ ខោអាវចម្រុះពណ៌ ឯកសណ្ឋានកងទ័ព បំណែកលលាដ៍ក្បាល និងលលាដ៍ក្បាលស្រាំ[514]។ អ្នកជិតខាងក៏បានប្រទះឃើញសាកសពមនុស្ស ចំនួន៦នាក់ក្បែរៗនោះ[515]។

## សក្ខីកម្មមុនៗ

7. សាក្សីបានផ្ដល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ ង៉ែត ប៊ុនថា ដោយ ក.ស.ច.ស- អ.វ.ត.ក ចុះថ្ងៃទី 8 ខែកុម្ភៈ ឆ្នាំ2008 D49/2, ERN 00186456-00186458 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

8. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយនៅក្នុងចម្លើយរបស់សាក្សី។

## 31. ប៉ែន ផល្លា

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីផ្តល់ភស្តុតាងអំពីការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងមនុស្សដោយខុសច្បាប់ កង្វះខាតការកាត់សេចក្តីដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* និងការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់ អ្នកជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*នៅមន្ទីរ ស-២១។ ភស្តុតាងដែលផ្តល់ដោយសាក្សីរូបនេះពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាង ក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទស្រី ជនជាតិខ្មែរ កើតថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៥៧ និងបច្ចុប្បន្នជាបុគ្គលិកសារមន្ទីរទួលស្លែង[516]។ សព្វថ្ងៃស្នាក់នៅផ្ទះលេខ២៦ Z ផ្លូវ៣៦០ សង្កាត់បឹងកេងកងបី ខណ្ឌចម្ការមន ក្រុងភ្នំពេញ[517]។

### ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

3. សាក្សីផ្តល់ភស្តុតាងថា ក្នុងផ្ទះលេខ២០ B ដែលនាងរស់នៅក្នុងឆ្នាំ១៩៧៩ ទល់មុខផ្ទះរបស់ឈ្មោះជ័យ សុភារា សព្វថ្ងៃ[518] មានខ្មោះ ច្រវាក់ និងឯកសារ។ នាងដឹងដោយសារប្តីនាងធ្វើការនៅផ្នែកប្រមូលភស្តុតាងនៃសារមន្ទីរទួលស្លែងជាអ្នកប្រាប់[519]។

### ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

4. សាក្សីផ្តល់ភស្តុតាងថានៅខាងលិច ផ្ទះនាងរស់នៅបច្ចុប្បន្ន (ផ្ទះលេខ ២៦Z ផ្លូវ៣៦០ សង្កាត់បឹងកេងកងបី ខណ្ឌចម្ការមន ភ្នំពេញ) "ត្រង់មុំផ្ទះឈ្មោះស៊ីផល គេប្រទះឃើញរណ្តៅសាកសពរួមមួយមានសាកសពចំនួន៣០"[520]។ លើសពីនេះ សាក្សីផ្តល់ភស្តុតាងថាក្រោយមានការជីកដីមួយក្នុងឆ្នាំ១៩៨៧ ខាងក្រោយសារមន្ទីរទួល ស្លែង នាងបានឃើញគេ "សែងឆ្អឹង"កាត់ផ្ទះនាង[521]។

### សក្ខីកម្មមុនៗ

5. សាក្សីបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ ប៉ែន ផល្លា ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ2008, D49/11, ERN 00186514-00186515 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

6. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រោងយោងផ្សេងទៀតឡើយ នៅក្នុងចម្លើយសាក្សី។

## 32. អ៊ុំង សារឿន

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទិននឹងមន្ទីរ ស-២១ សាក្សីផ្តល់ភស្តុតាងអំពីការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខមួយនេះ *(20-42)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងដោយខុសច្បាប់ កង្វះខាតការកាត់សេចក្តីដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឱ្យទៅជាទាសករ ការរងការឈឺចាប់ធ្ងន់ធ្ងរ ទង្វើអមនុស្សធម៌ *(62-71, 135, 143 & 148)* និងការសម្លាប់រង្គាល មនុស្សឃាត និងមនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ ពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមានប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីកើតនៅខេត្តកណ្តាល ថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៤៨។ ក្នុងខែមេសា ឆ្នាំ១៩៨៤ គាត់បានចូលមកនៅភ្នំពេញ មុខងារជាសន្តិសុខសារមន្ទីរទួលស្លែង។ គាត់ និងបុគ្គលិកផ្សេងទៀតត្រូវបានគេប្រគល់ផ្ទះមួយឱ្យស្នាក់នៅក្នុងបរិវេណនោះ។ គាត់បានចូលមកស្នាក់នៅផ្ទះលេខ៨៣ EoZ ផ្លូវ៣៦០[522]។

### ការបង្កើត រយៈពេល និងប្រតិបត្តិការ

3. នៅមុំផ្ទះគាត់ មានផ្ទះបេតុងចំនួន១០ល្វែង និងផ្ទះឈើជាច្រើន។ ទីបញ្ជាការយោធា តាំងនៅទិសខាងលិច។ ផ្ទះទាំង១០ ស្ថិតនៅ៖
   - ផ្លូវ១១៣ ក្បែរកាច់ជ្រុងផ្លូវ៣៥០ ម្ចាស់ឈ្មោះអ៊ុក ជា។
   - ខាងត្បូងផ្ទះសាក្សី តាមបណ្តោយផ្លូវ៣៦០ ម្ចាស់ឈ្មោះហ៊ីង សារិន។
   - ផ្ទះ៦ច្រក ខាងលិចផ្ទះសាក្សី ម្ចាស់មានឈ្មោះពេជ្រ ណាង ណោត ជឹម ភួ ទិប សេក ស៊ុន្នី ទួន ដោក និងច្រកទី៦ ជាទីស្នាក់ការសង្កាត់បឹងកេងកងបី។
   - ផ្លូវលេខ៣៥០ ម្ចាស់ឈ្មោះសេង ដារី និងជា សំអូន[523]។

*4.* សាក្សីផ្តល់ភស្តុតាងថាផ្ទះបេតុង និងផ្ទះឈើ ត្រូវបានខ្មែរក្រហមប្រើប្រាស់ជាមន្ទីរឃុំឃាំង និងសួរចម្លើយអ្នកទោស។ នេះបើផ្អែកតាមការដែលគាត់ប្រទះឃើញខ្នោះដៃ ខ្នោះជើងនៅក្នុងផ្ទះ[524]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

5. សាក្សីបានប្រទះឃើញក្រណាត់ចងមុខ ខ្នោះដៃពីរបីគូ នៅក្នុងអាងទឹកផ្ទះ[525]។ សាក្សីបានឃើញច្រវាក់ ខ្នោះដៃ ខ្នោះជើងជាច្រើន មានទាំងកេសគ្រាប់ប្រាំ ប្រាំមួយកេស និងចានបួនដប់ នៅជាន់ខាងលើផ្ទះ[526]។ ក្នុងផ្ទះទាំងអស់ នៅម្តុំនេះសុទ្ធតែមានខ្នោះដៃ ខ្នោះជើង[527]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

6. ក្រៅពីមានខ្នោះជើង និងក្រណាត់ចងមុខ នៅខាងក្នុងផ្ទះគាត់ មានស្នាមឈាម នៅលើកម្រាលឈើ[528]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

7. សាក្សីបានប្រទះឃើញអាងទឹកមួយ បួនម៉ែត្របួនជ្រុង ពេលត្រឡប់មកដល់ផ្ទះ។ គាត់បានឃើញឆ្អឹងមនុស្ស ៥នាក់ ក្នុងអាងទឹកនោះ ដែលបានជះក្លិនស្អុយពិបាកទ្រាំ[529]។ ខាងលិចផ្ទះគាត់ ក្នុងគ្រានោះមានស្រះមួយទំហំ១០ម៉ែត្រការេ មានសុទ្ធតែឆ្អឹង[530]។

## សក្ខីកម្មមុនៗ

8. សាក្សីបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

   (1) បទសម្ភាសន៍របស់ អ៊ុង សាមឿន ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 11 ខែកុម្ភៈ ឆ្នាំ2008, D49/6, ERN 00186486-00186488 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

9. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយនៅក្នុងចម្លើយសាក្សី។

សំណុំរឿងលេខ ០១/១៨-០៧-២០០៧-អវតក/អជសដ

## 33. សៀង ដានី

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីផ្តល់ភស្តុតាងអំពីការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងមនុស្សដោយខុសច្បាប់ និងកង្វះខាតការកាត់សេចក្តីដោយយុត្តិធម៌ *(47-54, 60-61, 134, 146 & 147)* និងការធ្វើជាទាសករ ការរងការឈឺចាប់ធ្ងន់ធ្ងរ និងទង្វើអមនុស្សធម៌ *(62-71, 135, 143 & 148)*។ ភស្តុតាងរបស់នាងពាក់ព័ន្ធបទចោទទី១ ទី២ ទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទស្រី ជនជាតិខ្មែរ កើតថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៧៧[531]។ សាក្សីរស់នៅផ្ទះលេខ១២ ផ្លូវ៣៤៨ សង្កាត់បឹងកេងកងបី ខណ្ឌចម្ការមន ក្រុងភ្នំពេញ[532]។ ផ្ទះនេះត្រូវបានរដ្ឋប្រគល់ឲ្យសាក្សីនិងម្តាយ ក្នុងនាមម្តាយនាងជានិយោជិតរោងចក្រវាយនភណ្ឌ ត៤ នៅចាក់អង្រែលើ[533]។

### ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

3. សាក្សីផ្តល់ភស្តុតាងថាពេលមកដល់ផ្ទះ នាងបានប្រទះឃើញទូដាក់ឯកសារពីបី ដែលមានឯកសារជាច្រើននៅខាងក្នុង ហើយមានស្នាមផ្តិតមេដៃ និងរូបថតពាក់កណ្តាលខ្លួន ជារបៀបអ្នកទោស និងឃើញរូបថតស្ត្រី បុរស និងទាហាន និងមនុស្សស៊ីវិលធម្មតាជាច្រើនទៀត[534]។ សាក្សីក៏បានប្រទះឃើញក្រដាសកាបូនសម្រាប់ចម្លង និងម៉ាស៊ីនអង្គលីលេខ[535]។ សាក្សីបញ្ជាក់ថាកាលនាងមិនទាន់មកនៅផ្ទះនេះ មិនឃើញមាននរណាម្នាក់រស់នៅក្នុងផ្ទះនេះមុននាងទេ[536]។ ក្នុងចម្លើយរបស់ខ្លួនសាក្សីបានលើកឡើងថា នាងដឹងថា ខាងក្នុងផ្ទះពីរច្រកជាប់គ្នា ជាប់នឹងល្វទឹកស្អុយ មានដាក់សុទ្ធតែឯកសារ[537]។

### ការធ្វើឲ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

4. សាក្សីផ្តល់ភស្តុតាងថាពេលចូលមកស្នាក់នៅផ្ទះ នាងបានឃើញពាងទឹកទទេរប្រាំ ប្រាំមួយ[538]។ នាងមិនបានឃើញអ្នឹង ឬឈាមទេ[539]។

### សក្ខីកម្មមុនៗ

5. សាក្សីបានផ្តល់ចម្លើយមុន មួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ សៀង ដានី ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ2008, D 49/8, ERN 00186502-00186503 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

6. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយ នៅក្នុងចម្លើយសាក្សី។

# 34. ទេស សំបុន

## ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីផ្តល់ភស្តុតាងអំពីការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់អ្នកជាប់ឃុំឃាំងដោយខុសច្បាប់ *(107-128, 138, 139-140 151 & 152 [ថ្មី])* នៅមន្ទីរ ស-២១។ ភស្តុតាងដែលផ្តល់ដោយសាក្សី ពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទស្រី ជនជាតិខ្មែរ កើតឆ្នាំ១៩៥២ នៅសង្កាត់លេខ៥ ភ្នំពេញ[540]។ សាក្សីបច្ចុប្បន្នរស់នៅផ្ទះលេខ៤១ BC សង្កាត់បឹងកេងកងបី ខណ្ឌចម្ការមន ភ្នំពេញ ចាប់តាំងពីឆ្នាំ១៩៨០[541]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

3. សាក្សីផ្តល់ភស្តុតាងថានាងបានជីកសាកសពមនុស្សចំនួន២១នាក់[542] ក្នុងនោះមានសាកសពស្ត្រីម្នាក់ផង[543]។ សាកសពទាំងនោះត្រូវគេចងមុខកប់ជាមួយទុយោទឹក និងច្រវាក់ ប៉ុន្តែសាក្សីមិនបានឃើញខ្នោះដែរទេ[544]។

## សក្ខីកម្មមុនៗ

4. សាក្សីបានផ្តល់ចម្លើយមុនមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ ទេស សំបុន ដោយក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 8 ខែកុម្ភៈ ឆ្នាំ2008, D49/4, ERN 00186470-00186471 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

5. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយ នៅក្នុងចម្លើយសាក្សី។

# 35. វណ្ណ សុភា

## ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីផ្តល់ភស្តុតាងអំពីការធ្វើឱ្យជាទាសករ ការរងការឈឺចាប់ធ្ងន់ធ្ងរ និងទង្វើអមនុស្សធម៌ *(62-71, 135, 143 & 148)* និងការសម្លាប់រង្គាល មនុស្សឃាត និងមនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])* នៅមន្ទីរ ស-២១។ ភស្តុតាងដែលសាក្សីផ្តល់ ពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមាន ប៉ុន្តែមិនមែនមាន ត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទប្រុស ជនជាតិខ្មែរ កើតឆ្នាំ១៩៥៤។ គាត់បានមកទស្សនកិច្ចមន្ទីរ ស-២១ ក្នុងខែកញ្ញា ឆ្នាំ១៩៧៩[545]។ ក្នុងឆ្នាំ១៩៩០ គាត់បានចូលមកនៅផ្ទះបច្ចុប្បន្ន លេខ១៣១ សង្កាត់បឹងកេងកងបី ខណ្ឌចម្ការមន ភ្នំពេញ ដែលពីមុនគ្រប់គ្រងដោយបុគ្គលិកមន្ទីរ ស-២១[546]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

3. សាក្សីផ្តល់ភស្តុតាងថាអំឡុងពេលទស្សនកិច្ចនៅមន្ទីរ ស-២១ ក្នុងខែកញ្ញា ឆ្នាំ១៩៧៩ គាត់អាចមើលឃើញផ្ទះដែលគាត់កំពុងរស់នៅសព្វថ្ងៃ ប៉ុន្តែមិនអាចចូលទៅដល់ពីព្រោះមានរបងលួសបន្លាព័ទ្ធជុំវិញផ្លូវ៣៦០ ផ្លូវ១១៣ ផ្លូវ៣១០ និងផ្លូវ១៤៣[547]។ អំឡុងពេលទស្សនកិច្ចនោះ សាក្សី បានឃើញគ្រែនៅជាន់ផ្ទាល់ដី នៃអគារខាងលិច ដែលខាងក្រោមអគារមានស្នាមឈាមកកក្រហម មានក្លិនចម្លែក[548]។ គាត់បានឃើញ កេសគ្រាប់សម្រាប់ឱ្យអ្នកទោសបន្ទោរបង់ និងពាងទឹក សរសេរ និងខ្សែពួរក្នុងបរិវេណនោះ[549]។ ពេលគាត់ចូលទៅស្នាក់នៅក្នុងផ្ទះបច្ចុប្បន្នក្នុងឆ្នាំ១៩៩០គាត់បានឃើញខ្នោះជើងមួយចំនួនក្នុងបន្ទប់ក្រោមជណ្តើរផ្ទះ។ ក្រោយមកខ្នោះជើងទាំងនោះ ត្រូវបានយកចេញដោយសាក្សី មិនបាន ដឹង[550]។ ពេលគាត់ចូលដល់ផ្ទះ មានស្នាមដែរនៅលើជញ្ជាំងនៃជាន់ផ្ទាល់ដី រួមនិងកេស គ្រាប់[551]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

4. សាក្សីបញ្ជាក់ថានៅខាងលិចសារមន្ទីរ នៅមន្ទីរ ស-២១ មានវាលមួយដែលមានសុទ្ធតែរណ្តៅ[552]។

## សក្ខីកម្មមុនៗ

5. សាក្សីបានផ្តល់ចម្លើយមុន មួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ វណ្ណ សុភា ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 8 ខែកុម្ភៈ ឆ្នាំ2008, D49/3, ERN 00186463-00186465 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

6. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយ នៅក្នុងចម្លើយសាក្សី។

## 36. មាស យ៉េម

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទិននឹងមន្ទីរ ស-២១ សាក្សីផ្តល់ភស្តុតាងអំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* ការបង្កើត ថេរៈវេលា និងប្រតិបត្តិការនៃមន្ទីរសន្តិសុខមួយនេះ *(20-42)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងមនុស្សដោយខុសច្បាប់ កង្វះខាតការកាត់សេចក្តីដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)*, ការធ្វើឱ្យទៅជាទាសករ ការរងការឈឺចាប់ធ្ងន់ធ្ងរ ទង្វើអមនុស្សធម៌ *(62-71, 135, 143 & 148)*, និងការសម្លាប់រង្គាល មនុស្សឃាត និងមនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់នាងពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមានប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីកើតនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៤៩ ក្នុងខេត្តស្វាយរៀង[553]។ ក្នុងខែកក្កដា ឆ្នាំ១៩៧៩ នាងបានចាកចេញពីខេត្តពោធិសាត់ មកនៅភ្នំពេញធ្វើការនៅរោងចក្រ ត៤។ រដ្ឋបានប្រគល់ផ្ទះមួយឱ្យនាងលេខ៨ E1 ផ្លូវ៣៣០ ដែលមានផ្ទះ៣ច្រក កំពស់២ជាន់[554]។

### ជម្លោះប្រដាប់អាវុធ

3. សាក្សីផ្តល់ភស្តុតាងថាពេលនាងចូលមកស្នាក់នៅក្នុងផ្ទះនោះ នាងបានឃើញខោអាវខ្មៅ និងគគីរ រួមទាំងឯកសណ្ឋាននៅរាយប៉ាយពេញផ្ទះ។ នាងមិនអាចបញ្ជាក់អំពីប្រភពនៃឯកសណ្ឋាន កងទ័ពនោះបានទេ[555]។

### ការបង្កើត រយៈពេល និងប្រតិបត្តិការ

4. សាក្សីផ្តល់ភស្តុតាងថា នាងបានប្រទះឃើញ "ច្រវាក់ ខ្នោះជើង និងរនុកខ្នោះដែក" នៅជាន់លើ និងជាន់ផ្ទាល់ដី។ លើសពីនេះ មានឯកសារវាយអង្គុលីលេខជាច្រើន នៅរាយប៉ាយនៅជាន់ខាងលើ[556]។

5. សាក្សីផ្តល់ភស្តុតាងថា កាលណោះ មានខ្នោះជើងនៅពាសពេញផ្ទះឯទៀត ដែលនៅតាមបណ្តោយផ្លូវផ្ទះនាង[557]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

6. សាក្សីបានឃើញច្រវាក់ និងខ្នោះជើង ក្នុងផ្ទះនាង និងផ្ទះឯទៀត តាមបណ្តោយផ្លូវផ្ទះនាង[558]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

7. ក្រៅពីច្រវាក់ និងខ្នោះជើងនៅមាន "ឈាម លាមក និងទឹកនោមជាច្រើន" ពាសពេញផ្ទះ ហើយនៅក្នុងផ្ទះឯទៀតតាមផ្លូវផ្ទះរបស់នាង ក៏មានលាមក និងខ្នោះជើងដែរ[559]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

8. មានដើមត្នោតទើបនឹងដាំថ្មីៗ ក្នុងបរិវេណផ្ទះដែលសាក្សីគិតថាមានអាយុពីរ បីឆ្នាំ បើគិតតាមទំហំរបស់វា។ ពេលដកដើមត្នោតនោះ នាងបានប្រទះឃើញឆ្អឹងកប់នៅខាងក្រោម និងមានក្លិនស្អុយម៉្លោះហើយទើបនាងសុខចិត្តទុកទាំងដើមត្នោត ទាំងឆ្អឹងទាំងនោះទៅក្នុងដីវិញ[560]។

## សក្ខីកម្មមុនៗ

9. សាក្សីបានផ្តល់ចម្លើយមុន មួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ មាស យ៉េម ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 11 ខែកុម្ភៈ ឆ្នាំ2008, D49/5, ERN 00186477- 00186479 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

10. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រោងយោងផ្សេងទៀតឡើយ នៅក្នុងចម្លើយសាក្សី។

# VIII. ការវិភាគឯកសារមន្ទីរ ស-២១

## 37. ឆាំង យុ

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

*សង្ខេបភស្តុតាងនៅកំពុងដំណើរការនៅឡើយ*

## 38. ឃួយ វិសាលមុនី

## ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទិននឹងមន្ទីរ ស-២១ សាក្សីផ្តល់ភស្តុតាងអំពីការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់អ្នកជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមានប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទប្រុសជនជាតិខ្មែរ មានអាយុ៧២ឆ្នាំ គិតត្រឹមខែឧសភា ឆ្នាំ២០០៨។ គាត់សព្វថ្ងៃធ្វើការឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ជាសមាជិកផ្នែកគ្រប់គ្រងទិន្នន័យ[561]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

3. សាក្សីផ្តល់ភស្តុតាងអំពីវិធីដែលគាត់បានចងក្រងបញ្ជីអ្នកទោស ដែលខ្មែរក្រហមបានប្រហារជីវិត។ សាក្សីផ្តល់ភស្តុតាងថាគាត់បានបង្កើតឯកសារទាំងនេះឡើង ដោយសហការណ៍ជាមួយក្នុងឆ្នាំ២០០៦ ផ្អែកតាមព័ត៌មានក្នុងសៀវភៅខ្មៅ[562]។

4. សាក្សីផ្តល់ភស្តុតាងថា គាត់ពុំបានដឹងថាសៀវភៅទាំងអស់នោះ មានប្រភពមកពីណានោះទេ[563]។

5. សាក្សីផ្តល់ភស្តុតាងថា ការសរសេរឡើងវិញនៃបញ្ជី គឺចម្លងទាំងស្រុងពីបញ្ជីដើមនៅក្នុងសៀវភៅខ្មៅទាំងអស់នោះ[564]។

6. ទាក់ទងនឹងសៀវភៅទាំងនោះ សាក្សីលើកឡើងថា គាត់ពុំបានដឹងចំណាងជើងដើមរបស់វាទេ[565]។

## សក្ខីកម្មមុនៗ

7. សាក្សីបានផ្តល់ចម្លើយមុន មួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។
   (1) បទសម្ភាសន៍របស់ ឃួយ វិសាលមុនី ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 28 ខែមីនា ឆ្នាំ2008, D77/5, ERN 00186692-00186698 (ភាសាខ្មែរ), 00194949-00194954 (ភាសាបារាំង)។

## ឯកសារពាក់ព័ន្ធដទៃទៀត

8. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយ នៅក្នុងចម្លើយរបស់សាក្សី។

## 39. គិត សេរី

## ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទិននឹងមន្ទីរ ស-២១ សាក្សីផ្តល់ភស្តុតាងអំពីការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់អ្នកជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុ ដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទប្រុស ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៨០ មានអាយុ២៨ឆ្នាំ គិតត្រឹមថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៨។ សាក្សីបច្ចុប្បន្នធ្វើការឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងមុខងារជាសមាជិកផ្នែកគ្រប់គ្រងទិន្នន័យ[566]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

3. សាក្សីផ្តល់ភស្តុតាងទាក់ទងនឹងវិធីដែលគាត់បានចងក្រងបញ្ជីអ្នកទោសដែលត្រូវប្រហារជីវិត នៅឆ្នាំ២០០៦[567]។ ការពន្យល់របស់សាក្សីទាក់ទងនឹងបញ្ជីអ្នកទោសដែលត្រូវប្រហារជីវិត គឺមានពាក់ព័ន្ធនឹងការប្រហារជីវិតធ្វើឡើងក្នុងមន្ទីរ ស-២១។ ការងាររបស់គាត់ក្នុងនោះ មានការសរសេរឡើងវិញនូវបញ្ជីឈ្មោះ និងបញ្ចូលបញ្ជីទាំងនេះក្នុងប្រព័ន្ធទិន្នន័យពីសៀវភៅខ្មៅ[568]។

4. សាក្សីផ្តល់ភស្តុតាងថាការសរសេរឡើងវិញ គឺដូចទាំងស្រុងទៅនឹងបញ្ជីដើមដែលមានក្នុងសៀវភៅទាំងអស់នោះ[569]។

5. សាក្សីផ្តល់ភស្តុតាងថាក្នុងបញ្ជីនីមួយៗ មានពីឈ្មោះមនុស្សម្នាក់ ដល់មួយរយនាក់[570]។

## សក្ខីកម្មមុនៗ

6. សាក្សីបានផ្តល់ចម្លើយមុន មួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ គិត សេរី ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 10 ខែមេសា ឆ្នាំ2008, D77/4, ERN 00186685-00186691 (ភាសាខ្មែរ)។

## ឯកសារពាក់ព័ន្ធដទៃទៀត

7. មិនមានឯកសារពាក់ព័ន្ធជាក់លាក់ សម្រាប់យោងផ្សេងទៀតឡើយ ក្នុងចម្លើយសាក្សី។

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

## 40. ឡាច វរល័ក្ខកល្យាណ

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. សាក្សីផ្តល់ភស្តុតាងអំពីតួនាទីនៃជនត្រូវចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161)* រចនាសម្ព័ន្ធសិទ្ធិអំណាច *(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងមនុស្សដោយខុសច្បាប់ កង្វះខាតការកាត់សេចក្តីដោយយុត្តិធម៌*(47-54, 60-61, 134, 146, 147)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការធ្វើបាបបែបអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់អ្នកជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])* នៅមន្ទីរ ស-២១។ ភស្តុតាងដែលផ្តល់ឲ្យពាក់ព័ន្ធនឹងបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទស្រី ជនជាតិខ្មែរ កើតថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៥៥ នៅភ្នំពេញ បច្ចុប្បន្នជាអនុប្រធានផ្នែកឯកសារនៃសារមន្ទីរទួលស្លែង[571]។ សាក្សីធ្វើការនៅសារមន្ទីរទួលស្លែងក្នុងឆ្នាំ ១៩៨៤ ទទួលបន្ទុកផ្នែកឯកសារ[572]។ ដំបូង ភារកិច្ចមានដូចជាការប្រមែប្រមូល និងរៀបចំឯកសារនានា ដែលប្រមូលបានពីខាងក្នុងសារមន្ទីរ និងពីផ្ទះស្ថិតនៅជុំវិញបរិវេណទួលស្លែង[573]។ ឯកសារដែលប្រមែប្រមូលបានរួមមានចម្លើយសារភាពអ្នកទោស បញ្ជីឈ្មោះអ្នកទោសចូលមន្ទីរ ស-២១ បញ្ជីអ្នកទោសត្រូវកម្ទេចចោលកំណត់ហេតុនៃអង្គប្រជុំរៀនសូត្រខ្មែរក្រហម សៀវភៅទង់បដិវត្តន៍សៀវភៅរៀនសូត្រអំពីយុទ្ធសាស្ត្រកងទ័ព និងសៀវភៅពេទ្យ ព្រមទាំងរូបថតអ្នកទោស ហ្វីល ប្រវត្តិរូបអ្នកទោស និងរូបថតប៉ុល ពត[574]។

### តួនាទីរបស់ជនជាប់ចោទ

3. សាក្សីផ្តល់ភស្តុតាងថា ឯកសារខ្លះបានប្រមែប្រមូលបាន មានឈ្មោះ និងហត្ថលេខា**ឌុច**[575]។

### រចនាសម្ព័ន្ធសិទ្ធិអំណាច

4. សាក្សីផ្តល់ភស្តុតាងថា ឯកសារមួយចំនួនមានឈ្មោះ និងហត្ថលេខា**ឌុច** ប៊ុន ម៉ម ណៃ ហៅចាន់ និងហ៊ា[576]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

5. សាក្សីផ្តល់ភស្តុតាងថា ឯកសារដែលនាងបានប្រមែប្រមូល រួមមានបញ្ជីអ្នកទោសចូល បញ្ជីអ្នកទោសដែលត្រូវបានកម្ទេចចោល និងចម្លើយសារភាពអ្នកទោស[577]។ សាក្សីក៏បានផ្តល់ភស្តុតាងថា ប្រវត្តិរូបអ្នកទោស ដែលខ្លះមានរូបថតភ្ជាប់មកជាមួយផង ត្រូវបានប្រទះឃើញនៅទួលស្លែង[578]។

## ការសួរចម្លើយ

6. សាក្សីផ្តល់ភស្តុតាងថា នាងបានប្រទះឃើញចម្លើយសារភាពអ្នកទោស[579]។

## ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

7. សាក្សីផ្តល់ភស្តុតាងថានាងបានប្រទះឃើញឧបករណ៍ធ្វើទារុណកម្ម ដែលរួមមាន ខ្សែភ្លើងស្រោត (សម្រាប់វាយអ្នកទោស) ពាងទឹកសម្រាប់ធ្វើទារុណកម្ម ធុងដាក់ទឹកទុកធ្វើទារុណកម្មអ្នកទោស ខ្នោះជើង រនុកដែក ខ្នះគ្នោត និងចានបាយ[580]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

8. សាក្សីផ្តល់ភស្តុតាងថាមានបញ្ជីអ្នកទោសដែលត្រូវកម្ទេច[581]។

## សក្ខីកម្មមុនៗ

9. សាក្សីនេះបានផ្តល់ភស្តុតាងមុន មួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ ឡាច វល័ក្ខកល្យាណ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 26 ខែមីនា ឆ្នាំ2008, D77/2, ERN 00186674-00186677 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

10. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយ នៅក្នុងចម្លើយរបស់សាក្សី។

## 41. អ៊ិច ប៊ុន

## ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទិននឹងមន្ទីរ ស-២១ សាក្សីផ្តល់ភស្តុតាងអំពីការបង្កើត ថេរៈវេលា និងប្រតិបត្តិការនៃមន្ទីរសន្តិសុខមួយនេះ *(20-42)*។ ភស្តុតាងរបស់គាត់ពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ មិនមែនមានត្រឹមតែអង្គហេតុ ដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទប្រុស ជនជាតិខ្មែរ កើតនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៧៥ ខេត្តកណ្តាល បម្រើការងារជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា[582]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

*3.* សាក្សីផ្តល់ភស្តុតាងថា គាត់បានចងក្រងមួយផ្នែកនៃបញ្ជីអ្នកទោសដែលត្រូវបានបញ្ជូនទៅកាន់មន្ទីរ ស-២១។ គាត់ពុំបានដឹងទេថាសៀវភៅដែលគាត់បានចម្លងចេញមកនោះមានប្រភពមកពីណា ប៉ុន្តែឯកសារដើមជាក្រដាសវែង ចាស់ មានប្រហោង ដូចជាចេញមកពីសៀវភៅចោះកង។ ឯកសារនេះត្រូវបានឈ្មោះ មុន្នី (ខួយ វិសាលមុន្នី) ជាអ្នកប្រគល់ឱ្យគាត់។ អ្វីដែលគាត់ បានសរសេរឡើងវិញ គឺដូចទៅនឹងឯកសារដើមមួយរយភាគរយ ហើយត្រូវបានឈ្មោះ ពៅ (រស់ សមពៅ) ជាអ្នកអានផ្ទៀងផ្ទាត់[583]។

*4.* សាក្សីពុំបានដឹងទេអំពីប្រភពនៃឯកសារដើម ហើយថាតើសព្វថ្ងៃឯកសារនេះនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជា ឬយ៉ាងណា សាក្សីមិនអាចនិយាយបានទេ[584]។

## សក្ខីកម្មមុនៗ

5. សាក្សីបានផ្តល់ចម្លើយមុន មួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ អ៊ិច ប៊ុន ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 24 ខែមេសា ឆ្នាំ2008, ERN 00212280-00212287, ឯកសារ D77/7 (ភាសាអង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

6. សាក្សីនេះបានអះអាងថា បញ្ជីអ្នកទោសដែលមានលេខ ERN 00161071-00161348 គឺជាឯកសារដែលគាត់បានធ្វើវិភាគទាន។ ផ្នែកនៃបញ្ជីអ្នកទោសដែលគាត់បានសរសេរឡើងវិញត្រូវបានភ្ជាប់ជាមួយនឹង D77/7 ជាឧបសម្ព័ន្ធ ក ដែលមានលេខ ERN 00212283-00212287។

## 42. តាត លក្ខិណា

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទិននឹងមន្ទីរ ស-២១ សាក្សីផ្តល់ភស្តុតាងអំពីការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងមនុស្សដោយខុសច្បាប់ កង្វះខាតការកាត់សេចក្តីជនជាប់ឃុំឃាំងដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)*។ ភស្តុតាងរបស់នាងពាក់ព័ន្ធនឹងបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលសាក្សីរូបនេះផ្តល់ឱ្យរួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុ ដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទស្រី ជនជាតិខ្មែរ កើតថ្ងៃទី០៥ មិថុនា ឆ្នាំ១៩៨៣ ជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។ សាក្សីផ្តល់ភស្តុតាងអំពីបញ្ជីអ្នកទោសមន្ទីរ ស-២១[585]។

### ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

3. សាក្សីផ្តល់ភស្តុតាងថានាងបានវាយអត្ថបទប្រហែលចិតសិបទំព័រ ចេញពីសៀវភៅសរសេរដោយដៃ ដែលមានឈ្មោះ និងទិន្នន័យ [586]។ សាក្សីបាននិយាយថា សំណៅដែលនាងវាយដោយកុំព្យូទ័រនោះ គឺដូចទាំងស្រុងនៅនឹងសំណៅឯកសារដើម[587]។ សាក្សីមិនបានដឹងអំពីប្រភពនៃសៀវភៅដើម ហើយក៏ពុំបានដឹងថាតើសៀវភៅនេះចេញពីប្រភពណាដែរ[588]។ នាងពុំបានដឹងអំពីមាតិកានៃសៀវភៅ ឆ្នាំសរសេរ ឬនរណាជាអ្នកសរសេរនោះទេ[589]។

### សក្ខីកម្មមុនៗ

4. សាក្សីបានផ្តល់ចម្លើយមុន មួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ តាត លក្ខិណា ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី24 ខែមេសា ឆ្នាំ2008, D77/8, ERN 00212288-00212290 (ភាសាអង់គ្លេស)។

### ឯកសារពាក់ព័ន្ធដទៃទៀត

5. មិនមានឯកសារពាក់ព័ន្ធជាក់លាក់សម្រាប់យោងផ្សេងទៀតឡើយ នៅក្នុងចម្លើយសាក្សី។

## 43. វ៉ាន់ថាន់ ពៅដារ៉ា

## ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទិននឹងមន្ទីរ ស-២១ សាក្សីផ្តល់ភស្តុតាងអំពីតួនាទីជនត្រូវចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)*ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខមួយនេះ *(20-42)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងមនុស្សដោយខុសច្បាប់ កង្វះខាតការកាត់សេចក្តីដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឲ្យទៅជាទាសករ ការរងការឈឺចាប់ធ្ងន់ធ្ងរ ទង្វើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការធ្វើទារុណកម្ម និងការធ្វើបាបបែបអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់អ្នកជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងដែលសាក្សីផ្តល់ឲ្យពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមានប៉ុន្តែមិនមែនមានត្រឹមតែ អង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទប្រុស ជនជាតិខ្មែរ កើតថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៣ នៅស្ទឹងត្រែង បម្រើការងារជាអនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា[590]។

## តួនាទីរបស់ជនជាប់ចោទ

3. សាក្សីផ្តល់ភស្តុតាងថា អតីតអ្នកជាប់ឃុំនៃមន្ទីរ ម-១៣ ឈ្មោះ ហាម អ៊ីន បាននិយាយថាឌុច បានក្លាយជាប្រធានគុក ម-១៣ ប្រហែលក្នុងឆ្នាំ១៩៧១[591]។ ឌុច ក៏មិនដែលធ្លាប់បានចាត់វិធានការណ៍ ណាមួយដើម្បីបញ្ឈប់ទង្វើកោងកាចរបស់កូនចៅខ្លួនទេ ដូចជាបាញ់ចំពោមដាក់អ្នកទោស ឬទាត់ធាក់អ្នកទោសជាល្បែងកំសាន្ត[592]។ សាក្សីក៏បានផ្តល់ភស្តុតាងថាមានឯកសារពីរ ដែលបង្ហាញថាឌុចបានចេញបញ្ជាឲ្យសួរចម្លើយ និងប្រហារជីវិតអ្នកទោសនៃមន្ទីរ ម-១៣[593]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះក្តីដោយយុត្តិធម៌

4. សាក្សីផ្តល់ភស្តុតាងថា ឯកសារដែលមានលេខ ERN00161072-00161384 គឺជាឯកសារមន្ទីរ ស-២១ ដើមដែលសរសេរដោយដៃ ហើយត្រូវបានបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ជាអ្នកវាយកុំព្យូទ័រឡើង

វិញ[594]។ ឯកសារដើម មានគ្របពណ៌ខ្មៅ វែង ដែលមានសៀវភៅពីរក្បាល[595]។ សាក្សីពុំបានដឹងថានរណាជាអ្នករៀបចំ ឬត្រូវបានរៀបចំតាំងពីពេលណាមកនោះទេ ហើយមិនដឹងថាតើឯកសារ នោះឥឡូវនេះនៅទីណាដែរ ប៉ុន្តែមជ្ឈមណ្ឌលឯកសារកម្ពុជា មានឯកសារចម្លងមួយច្បាប់[596]។

5. សាក្សីផ្តល់ភស្តុតាងថា អតីតអ្នកជាប់ឃុំឃាំងមន្ទីរ ម-១៣ម្នាក់ឈ្មោះ ហាម អ៊ីន បានបញ្ជាក់ថា**ឌុច** ប្រើអ្នកទោសឱ្យយកព័ត៌មានពីអ្នកទោសគ្នាឯង ហើយ**ឌុច** បានប្រាប់ហាម អ៊ីន ថា "អញនឹងដោះលែងឯងប្រសិនណាឯងធ្វើការជាតិញក្នុងគុកនេះឱ្យអញ"[597]។

## ការធ្វើឱ្យទៅជាទាសករ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា និងអំពើអមនុស្សធម៌ដទៃទៀត

6. សាក្សីផ្តល់ភស្តុតាងថាហាម អ៊ីន បានលើកឡើងថាក្រោយពីមានអ្នកទោសម្នាក់បានឆ្លើយសារភាព គាត់បានត្រូវគេដាក់ខ្នោះជើង ឱ្យក្មេងៗវាយគាត់[598]។

7. សាក្សីក៏បានផ្តល់ភស្តុតាងថា ហាម អ៊ីន បានបញ្ជាក់ថាអ្នកទោសនឹងត្រូវគេបញ្ជាឱ្យជីករណ្តៅកប់ខ្លួនឯងនៅមន្ទីរ ម-១៣[599]។

## ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌

8. សាក្សីផ្តល់ភស្តុតាងថា ហាម អ៊ីន អតីតអ្នកជាប់ឃុំឃាំងមន្ទីរ ម-១៣ បាននិយាយថាគាត់ធ្លាប់បានឃើញផ្ទាល់ភ្នែក ឬធ្លាប់ទទួលរងទារុណកម្ម ជាការពិន័យ មានដូចជា៖
   - ការចងដៃទាំងពីរទៅក្រោយខ្នងអ្នកទោស យកខ្សែពួរភ្ជាប់ទៅនឹងចំណង ហើយទាញខ្សែពួរឡើងលើ ទាល់តែជើងទាំងពីរ ផុតពីដីពីរបីសង់ទីម៉ែត។
   - ការបង្ខំឱ្យអ្នកទោសផឹកទឹកសាប៊ូ រហូតសន្លប់បាត់ស្មារតី។
   - យកចន្លុះដុតពោះអ្នកទោស និងទុកចន្លុះនៅទីនោះ រហូតទាល់តែសាច់ដែលដុតនោះ ប្រែពណ៌ជាស ព្រោះស្បែកកន្លែងនោះជាប់ជាមួយចុងចន្លុះទៅហើយ។
   - ដុតក្រណាត់មួយ ជុំវិញប្រឆេះចន្លុះ ហើយយកក្រណាត់ដែលឆេះនោះទៅដាក់លើរាងកាយអ្នកទោសពីក្បាល ដល់ចុងជើង ទល់តែរាងកាយអ្នកទោសនោះ ប្រែពណ៌ជា ស ដោយសារការដុត។
   - ការចងអ្នកទោសជាប់នឹងសសរ នៅចំពោះមុខអ្នកទោសឯទៀត ហើយបាញ់អ្នកទោសនោះត្រង់ក្បាលខ្ទាតឈាម និងគ្រឿងក្នុងពេញខ្លួនអ្នកទោសផ្សេងទៀត។

- ការចាក់ដែកស្រួច ចាក់ស្បែកក្រោមក្រចក ហើយយកម្រាមដៃដែលមានឈាមហូរនោះទៅជ្រលក់ក្នុងកន្ត្រាទឹកនោម[600]។

## ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

9. សាក្សីផ្ដល់ភស្តុតាងថា អតីតអ្នកជាប់ឃុំឃាំងមន្ទីរ ម-១៣ ឈ្មោះហម អ៊ីន បាននិយាយថា ខ្មែរក្រហមបានបញ្ជាឱ្យកុមារធ្វើការប្រហារជីវិតចំនួន២លើកក្នុងមួយថ្ងៃ នៅក្នុងគុកនោះ[601]។

## សក្ខីកម្មមុនៗ

10. សាក្សីបានផ្ដល់ចម្លើយមុន ប្រាំមួយតាមការដឹងរបស់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសន៍របស់ វ៉ាន់ថាន់ ពៅដារ៉ា ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី23 ខែមេសា ឆ្នាំ2008, D77/6, ERN 00194955-00194957 (ភាសាអង់គ្លេស)។

(2) លិខិតបញ្ជាក់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា អំពី វ៉ាន់ថាន់ ពៅដារ៉ា ចុះថ្ងៃទី26 ខែកុម្ភៈ ឆ្នាំ2007, គ្មានERN (ប៉ុន្តែនៅក្នុង Casemap)។

(3) វ៉ាន់ថាន់ ពៅដារ៉ា "មន្ទីរ ម 13 របស់ **ឌុច**," *ទស្សនាវដ្ដីស្វែងរកការពិត*, ចុះថ្ងៃទី22 ខែតុលា ឆ្នាំ2001, ERN 00079673-00079675 (ភាសាអង់គ្លេស)។

(4) របាយការណ៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា អំពី វ៉ាន់ថាន់ ពៅដារ៉ា: "ធ្វើផែនទីវាលពិឃាតកម្ពុជា" ចុះថ្ងៃទី 10 ខែមិថុនា ឆ្នាំ1999, ERN 00095650-00095659 (ភាសាអង់គ្លេស)។

(5) របាយការណ៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា អំពី វ៉ាន់ថាន់ ពៅដារ៉ា: "គុកសង់ សាក្សីរបស់គុកសង់ និងដំណើររឿងរបស់ពួកគេ" ចុះថ្ងៃទី 25 ខែសីហា ឆ្នាំ1998, ERN 00089398-000893402 (ភាសាអង់គ្លេស)។

(6) របាយការណ៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា អំពី វ៉ាន់ថាន់ ពៅដារ៉ា: "របាយការណ៍នៃការរៀបចំផែនទី ឆ្នាំ1999 ខេត្តកំពង់ឆ្នាំង" ចុះថ្ងៃទី 10 ខែមិថុនា ឆ្នាំ1999, ERN 00089803-00089813 (ភាសា អង់គ្លេស)។

## ឯកសារពាក់ព័ន្ធដទៃទៀត

11. មានវត្ថុតាងសក្ខានុពលមួយ នៃកំណត់ត្រាជាក់លាក់ដែលមានលេខ ERN00161072-00161384 ឯកសារចម្លងនៃបញ្ជីអ្នកទោសមន្ទីរ ស-២១ ដែលវាយដោយកុំព្យូទ័រ។ អត្ថបទដកស្រង់មួយត្រូវបានភ្ជាប់មកជាមួយ បទសម្ភាសន៍ ដោយ ក.ស.ច.ស , ERN 00194958-61។

សំណុំរឿងលេខ ០១/១៨-០៧-២០០៧-អវតក/អជសង

## 44. យិន នាន

### ចរិតលក្ខណៈ និងខ្លឹមសារនៃភស្តុតាង

1. ទាក់ទិននឹងមន្ទីរ ស-២១ សាក្សីផ្តល់ភស្តុតាងអំពីការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់អ្នកជាប់ឃុំឃាំងដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់ពាក់ព័ន្ធបទចោទទី១ ទី២ និងទី៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ភស្តុតាងដែលបានផ្តល់ដោយសាក្សីរូបនេះ រួមមាន ប៉ុន្តែមិនមែនមានត្រឹមតែអង្គហេតុដូចដែលបានរៀបរាប់ខាងក្រោមនេះទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីភេទប្រុស ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៦១។ ពីឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៨៦ គាត់បម្រើការងារជាសមាជិកផ្នែកថែទាំ និងសន្តិសុខ នៃសារមន្ទីរទួលស្លែង[602]។ ពីឆ្នាំ១៩៨៧ ដល់ឆ្នាំ១៩៩២ ជាសមាជិកផ្នែកសេដ្ឋកិច្ច[603]។ ចាប់ពីឆ្នាំ១៩៩២មក គាត់ជាសមាជិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា[604]។

### ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងមនុស្សឃាតដោយចេតនា

3. សាក្សីផ្តល់ភស្តុតាងទាក់ទិននឹងបញ្ជីអ្នកទោសត្រូវប្រហារជីវិតចំនួន២ នៃមន្ទីរ ស-២១។ ឯកសារទី១មានចំណងជើងថា "បញ្ជីឈ្មោះអ្នកទោសមន្ទីរ ស-២១ ដែលត្រូវប្រហារជីវិតចំនួន២ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា" និងឯកសារទីពីរមានចំណងជើងថា "មជ្ឈមណ្ឌលឯកសារកម្ពុជា" [605]។

4. សាក្សីផ្តល់ភស្តុតាងថា ឯកសារទីមួយ គឺជារៀបរៀងចងក្រងពីបញ្ជីដែលគាត់បានប្រទះឃើញនៅមន្ទីរ ស-២១ និងផ្ទះក្បែរនោះ។ បញ្ជីនោះស្តីពីអ្នកទោសដែលត្រូវបានប្រហារជីវិតនៅមន្ទីរ ស-២១។ ពេលស្តាប់ចម្លើយលើកទីពីរ សាក្សីបានផ្តល់ភស្តុតាងថា គាត់បានរៀបរៀងចងក្រងបញ្ជីអ្នកទោសដែលត្រូវប្រហារជីវិត តាមបញ្ជីដើមដែលមានឈ្មោះអ្នកទោសដែលត្រូវកម្ទេច[606]។

5. ទាក់ទិននឹងឯកសារទីពីរ សាក្សីផ្តល់ភស្តុតាងថា គាត់ពុំបានចូលរួមក្នុងការចងក្រងបញ្ជីទីពីរនោះទេ។ គាត់បានពន្យល់ប្រាប់ថាបញ្ជីទាំងអស់នោះ ចេញមកពីសៀវភៅពីរក្បាលដែលមានចម្លើយសារភាពអ្នកទោស[607]។

6. សាក្សីផ្តល់ភស្តុតាងថា គេអាចដឹងចំនួនអ្នកទោស ពិតប្រាកដ ដែលត្រូវបានប្រហារជីវិតនៅមន្ទីរ ស-២១ តាមការប្រៀបធៀបឈ្មោះដែលគេមានសរសេរនៅក្នុងឯកសារដែលប្រទះឃើញនៅមន្ទីរ ស-២១ ទៅនឹងឈ្មោះដែលគេសរសេរនៅក្នុងបញ្ជីទាំងពីរ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា ជាអ្នករៀបរៀងចងក្រង[608]។

7. សាក្សីផ្តល់ភស្តុតាងអំពីវិធីចាត់ថ្នាក់ឯកសារ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងអំពីចំនួនឯកសារនៅទីនោះ។ ឯកសារត្រូវបានបែងចែកជា៦ក្រុម មានឯកសារទាក់ទងចម្លើយសារភាពរបស់អ្នកទោស (៤១៦៨ ឯកសារ) ឯកសារទាក់ទងអ្នកទោស និងប្រវត្តិរូបអតីតកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ (៦២២៣ ឯកសារ) រូបថត (៥៨៤៧ឯកសារ) ហ្វីល (៥៨៤៧ ឯកសារ) មីក្រូហ្វីល (១២ ដុំ) និង ឯកសារផ្សេងៗ (៥១៣៦ ឯកសារ)[609]។

## សក្ខីកម្មមុនៗ

